ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ

## សាធារណៈ – កោសលុប

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី៣៣៤**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 23-Mar-2017, 14:53
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ជា ស៊ីវហ៉ាង

កញ្ញា រ៉ូប៊ីន្ទី ក្រូហ្វ៍ *(Ms. Robynne CROFT)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

កញ្ញា សុង ឆវ័ន្ត

លោក ឌេល លីសាក់ *(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

លោក លីវ សុវណ្ណា

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍ *(Ms.Marie GUIRAUD)*

លោក ឡៃ ជុនធី

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ឌុច ផារី | ខ្មែរ |
| លោកស្រី សុក សុជាតា | ខ្មែរ |
| លោក បាន សៀក (2-TCW-950) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷ លោក ឆាន សៀក ហៅ ហាន្ស ផុស ហៅ ហាន្ស ស៊ុនហូ** (2-TCW-950)

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................................................ទំព័រ ៣

សួរដោយលោក ឌេល លីសាក់ ផ្តើមពី ..................................................................ទំព័រ ៦

សួរដោយលោក ពេជ អង្គ ផ្តើមពី ........................................................................ទំព័រ ៦៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:០៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-950 ពាក់ព័ន្ធជាមួយនឹងអង្គហេតុចោទប្រកាន់ការប្រព្រឹត្តចំពោះគោលដៅជាក់លាក់ចំពោះជនជាតិចាម ហើយនិងមានសាក្សីបម្រុង 2-TCW-904 ហើយក៏សូមបញ្ជាក់ដែរ តាមកាលវិភាគដែលអង្គជំនុំជម្រះបានកំណត់រួចហើយ គឺការស្តាប់សក្ខីកម្មសាក្សី 2-TCW-950 យើងនឹងធ្វើពីរថ្ងៃ ដោយមួយភាគីម្ខាង គឺមានរយៈពេលមួយថ្ងៃក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី 950 នេះ។

ក្រឡាបញ្ជីសវនាការកញ្ញា ជា ស៊ីវហ័ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ។ លិខិតលះបង់សិទ្ធិរបស់ជាប់ចោទ នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មនៅថ្ងៃនេះមានរហស្សនាម 2-TCW-950។ សាក្សីបានបញ្ជាក់ថាតាមសមត្ថភាពដែលគាត់អាចដឹងគឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបគឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្តឹងដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវបានទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីរូបនេះបានធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែករួចហើយកាលពីព្រឹកមិញនេះ។ សាក្សីមានមេធាវីប្រឹក្សាគឺលោក ឌុច ផារី នៅពេលព្រឹកនេះ និងមេធាវី លោកស្រី សុក សុជាតា នៅពេលរសៀល។ សាក្សី និងមេធាវីប្រឹក្សាមានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

[០៩:០៥:៥០]

**ប្រធានអង្គជំនុំ៖**

អរគុណ កញ្ញា ជា ស៊ីវហ៊ាង។ ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ នៅក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥ ដែលបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធិភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥។ មេធាវីការពារក្តីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់ជនជាប់ចោទ នួន ជា នៅថ្ងៃនេះថាមាន មានអាការៈឈឺចង្កេះរ៉ាំរ៉ៃ អង្គុយយូរវិលមុខ និងបានផ្តល់អនុសាសន៍ថា សូមអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

[០៩:០៧:១៤]

ផ្អែកលើមូលដ្ឋាននេះ និងយោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥)នៃវិធានផ្ទៃក្នុងអ.វ.ត.ក អង្គជំនុំជម្រះ អនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទនួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ជាបន្តទៅនេះ បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី រួមទាំងមេធាវីប្រឹក្សាសាក្សីចូល

មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួរស្តីលោកសាក្សី។ តើលោកឈ្មោះអី?

**លោក បាន សៀក៖**

**ឆ៖** ខ្ញុំបាទឈ្មោះ បាន សៀក។

**ស៖** អរគុណលោក បាន សៀក។ តើលោកអាចប្រាប់ដល់អង្គជំនុំជម្រះបានដែរឬទេ ថាលោកកើតនៅថ្ងៃ ខែ ឆ្នាំណា?

**ឆ៖** ខ្ញុំ--

**ស៖** កុំអាលទាន់ៗ!

[០៩:១០:០០]

**ឆ៖** ខ្ញុំកើតនៅឆ្នាំ១៩៥៤។

**ស៖** អរគុណ។ តើលោកមានទីកន្លែងកំណើតនៅកន្លែងណា? កុំអាល់ទាន់!

**ឆ៖** ទីកន្លែងកំណើតនៅភូមិឫស្សីក្រោក ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ។

**ស៖** ចុះទីលំនៅសព្វថ្ងៃរបស់លោក តើលោករស់នៅទីកន្លែងណា?

**ឆ៖** នៅភូមិអូរចិញ្ចៀន ឃុំអន្លង់វែង ខេត្តឧត្តរមានជ័យ។

**ស៖** លោកប្រកបមុខរបររកស៊ីធ្វើអ្វីដែរ សព្វថ្ងៃនេះ?

**ឆ៖** សព្វថ្ងៃ ខ្ញុំឈប់ហើយ ឈប់ធ្វើអ្វីទាំងអស់។ មុននេះខ្ញុំធ្វើក្រុមប្រឹក្សាស្រុក។

**ស៖** ឪពុកបង្កើតរបស់លោកឈ្មោះអ្វី? ហើយម្តាយបង្កើតរបស់លោក គាត់ឈ្មោះអ្វី?

**ឆ៖** ឪពុកឈ្មោះ ហង្ស ហ៊ាង, ម្តាយឈ្មោះ ឡុង ពេញ។

**ស៖** អរគុណ។ ចុះប្រពន្ធរបស់លោកឈ្មោះអ្វី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធឈ្មោះ ហង្ស ផុន (ស្លាប់) មានកូន៩នាក់។

**ស៖** អរគុណលោក បាន សៀក។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ តាមសមត្ថភាពដែលលោកបានអាចដឹងបាន គឺលោកមិនមានជាប់ចំណងញាតិលោហិត ឬក៏ជាតិ

ពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូបគឺលោក នួន ជា និងលោក ខៀវ សំផន និងបុគ្គលទាំងឡាយដែលបានទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង០០២នេះ។ តើពិតមែនដែរទេ?

[០៩:១២:១៩]

**ឆ៖** បាទ លោកពិតមែន។

**ស៖** តើលោកបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែក នៅពីខាងកើតសាលសវនាការនេះហើយឬនៅ?

**ឆ៖** បាទ ខ្ញុំបានទៅស្បថហើយ។

**ស៖** តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងនាមលោកដែលចូលរួមនៅក្នុងកិច្ចដំណើរការសវនាការ ក្នុងឋានៈជាសាក្សី។ លោក បាន សៀក អំពីសិទ្ធិ លោក បាន សៀក ក្នុងឋានៈជាលោកសាក្សី នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកមានសិទ្ធិបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬក៏សុំឲ្យលោកធ្វើអត្ថាធិប្បាយណាមួយ ឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានន័យថា ដោយសារតែចម្លើយ ឬសេចក្ដីអត្ថាធិប្បាយរបស់លោកនោះ នាំឲ្យលោកប្រឈមនឹងការចោទប្រកាន់។

អំពីករណីយកិច្ច លោក បាន សៀក ក្នុងនាមជាលោកជា ក្នុងឋានៈជាលោកសាក្សី ត្រូវផ្ដល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយ ដែលភាគី ឬចៅក្រមដែលអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតប ឬក៏ការធ្វើអត្ថាធិប្បាយរបស់លោក ដែលនាំលោកដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិអម្បាញ់មិញនេះរួចហើយ។

[០៩:១៣:៤៣]

ហើយក្នុងនាមលោកជាសាក្សី ត្រូវតែឆ្លើយឲ្យការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

លោក បាន សៀក តើកន្លងមកនេះ លោកធ្លាប់បានផ្ដល់សក្ខីកម្ម ឬផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេ? ហើយប្រសិនបើធ្វើ ធ្វើប៉ុន្មានដង ធ្វើនៅទីកន្លែងណា នៅពេលណា?

**ឆ៖** បាទ ធ្វើនៅសាលាស្រុកពីរដង ធ្វើនៅផ្ទះបីដង ធ្វើនៅសាលាក្ដីម្ដង។

**ស៖** ធ្វើនៅសាលាស្រុកពីរដងហ្នឹង ធ្វើនៅទីសាលាស្រុកណាអ៊ីចេះ?

**ឆ៖** បាទ ធ្វើនៅសាលាស្រុកអន្លង់វែង។

**ស៖** លោកចាំកាលបរិច្ឆេទទេ គ្រប់លើកដែលបានធ្វើកិច្ចសម្ភាសន៍ជាមួយនឹងលោកចំនួនរៀបរាប់ទៅដូចជាប្រាំមួយដងហ្នឹង តើមានលោកចងចាំកាលបរិច្ឆេទទេ ពេលវេលាដែរទេ?

**ឆ៖** អត់បានចាំទេ។

**ស៖** បាទ អរគុណ។ ហើយនៅមុនពេលចូលមកដល់ចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ តើលោកបានពិនិត្យ ឬបានអានវន្ទូវកំណត់ហេតុដែលលោកបានផ្ដល់ចម្លើយកាលពីពេលមុនជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីរំឭកការចងចាំរបស់លោកដែរឬទេ?

**ឆ៖** បាទ យប់មិញមើលមួយយប់ហើយ ព្រឹកមិញមើលទៀត។

[០៩:១៥:៥០]

**ស៖** ហើយតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំបាន តើលោកអាចបញ្ជាក់បានដែរទេថាកំណត់ហេតុដែលលោកផ្ដល់ចម្លើយដែលលោកបានអាន ដើម្បីរំឭកការចងចាំនោះ គឺពិតជាត្រឹមត្រូវសមស្រប ស៊ីចង្វាក់គ្នាទៅនឹងចម្លើយដែលលោកបានផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុននោះដែរឬទេ?

**ឆ៖** បាទ ប៉ុន្តែពេលខ្លះលោកសួរ ថាសួរកន្លែងណា លោកសួរកន្លែងហ្នឹងទៀត។

**ស៖** យើងមិនចង់ដឹងអ៊ីចឹងទេ។ យើងគ្រាន់តែចង់សួរបញ្ជាក់ថា អ្វីដែលលោកបានឆ្លើយកាលពីពេលមុន ហើយនិងខ្លឹមសារនៃឯកសារនៃកំណត់ហេតុដែលលោកអានឡើងវិញដើម្បីរំឭកការចងចាំនោះ លោកទៅគិតទៅមើល អ្វីដែលលោកបានផ្ដល់សក្ខីកម្មកាលពីលើកមុននោះ វាស្របវាមានខ្លឹមសារស្របគ្នា ឬក៏ដូចគ្នាទៅនឹងខ្លឹមសារដែលលោកបាននិយាយពេលមុននោះដែរឬទេ? កំណត់ត្រាដែលលោកអានហ្នឹងណ៎ា វាប្រហាក់ប្រហែលគ្នា ឬដូចគ្នាដែរឬទេ?

**ឆ៖** បាទ ដូចគ្នា។

**ប្រធានអង្គជំនុំ៖**

ហើយនៅពេលនេះ លោក បាន សៀក លោកបានទទួលជំនួយមេធាវីប្រឹក្សាសាក្សីដែលអង្គជំនុំជម្រះផ្ដល់ឲ្យតាមរយៈអង្គភាពគាំពារសាក្សី និងអ្នកជំនាញ តាមសំណើរបស់លោក ហើយមេធាវី

ប្រឹក្សាសាក្សីនៅព្រឹកនេះ គឺលោក ឌុច ផារី ហើយនិងនៅរសៀលនេះគឺលោកស្រី សុក សុជាតា។

ហើយក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាសួរដេញដោលសាក្សី បាន សៀក មុនភាគីដទៃទៀតនៃរឿងក្តី។ សូមបញ្ជាក់ថា សហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានរយៈពេលមួយថ្ងៃក្នុងការសួរសាក្សីរូបនេះ។ សូមអញ្ជើញ!

[០៩:១៨:០៣]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម សហការីទាំងអស់។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ជម្រាបសួរលោកសាក្សី! ខ្ញុំឈ្មោះ ឌេល លីសាក់ នឹងសួរសំណួរទៅកាន់លោកខ្លះៗ ក្នុងនាមឲ្យសហព្រះរាជអាជ្ញា។ ខ្ញុំសុំសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងប្រវត្តិរូបរបស់លោក ពីមុន<អង្គជំនុំជម្រះ>នេះ គឺយើងបានស្តាប់សក្ខីកម្មពី ស៊ូ សឿន ជាប្រពន្ធរបស់ កែ ពក ដែលជាមេភូមិភាគកណ្តាល។ ហើយថា តើលោកមានជាប់ជាសាច់ឈាមអីជាមួយ ស៊ូ សឿន ដែរទេ? <បើសិនជាមានតើលោកត្រូវជាអ្វីនឹង ស៊ូ សឿន ដែរ?>

**លោក បាន សៀក៖**

**ឆ៖** បាទ ត្រូវជាបងថ្លៃជីដូនមួយ។

**ស៖** ខ្ញុំសូមបញ្ជាក់ម្តងទៀត។ តើប្រពន្ធរបស់លោក ឬក៏ថាប្រពន្ធលោកដែលបានស្លាប់ទៅហើយនោះ ជាសាច់ឈាមរបស់ ស៊ូ សឿន ឬក៏អត់ទេ?

**ឆ៖** បាទ ប្រពន្ធរបស់ខ្ញុំបាទ។

**ស៖** អ៊ីចឹងប្រពន្ធលោក ហើយនិង ស៊ូ សឿន នេះជាប់សាច់ឈាមនឹងគ្នាយ៉ាងម៉េចដែរ? ត្រូវជាអ្វីនឹងគ្នា?

**ឆ៖** ត្រូវជាបងប្អូនជីដូនមួយ។ គាត់ត្រូវជាបង។

**ស៖** ប្រពន្ធលោក និងលោក រៀបការពីពេលណាដែរ?

**ឆ៖** ខ្ញុំមិនចាំ ប៉ុន្តែខ្ញុំរៀបការពីអាយុ១៨ឆ្នាំមកម្ល៉េះ។

[០៩:២០:៣២]

**ស៖** ហើយលោកបញ្ជាក់ថា លោកកើតនៅខែមីនា ១៩៥៤។ អ៊ីចឹងមានន័យថា លោករៀបការក្នុងអំឡុងឆ្នាំ<>១៩៧២ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ប្រហែលជាឆ្នាំ៧០ហើយ លោក ៧០ឆ្នាំហើយមើលទៅ ខ្ញុំមិនចាំដែរ។

**ស៖** នៅពេលដែលលោករៀបការ តើ ស៊ូ សឿន, ប្ដីរបស់គាត់ កែ ពក ហើយនិងប្អូនថ្លៃឈ្មោះ អឿន បានមកចូលរួមក្នុងពិធីការរបស់លោកទេ?

**ឆ៖** បាទ អត់ទេ។

**ស៖** តើលោកបានជួបសាច់ថ្លៃរបស់លោក ស៊ូ សឿន, អឿន និងប្ដីរបស់ ស៊ូ សឿន នេះគឺ កែ ពក តើលោកជួបអ្នកទាំងបីនេះ ជាលើកដំបូងនៅពេលណា?

**ឆ៖** បាទ ជួបកាលខ្ញុំនៅឡូត៍នេសាទ។

**ស៖** ឥឡូវខ្ញុំសូមចូលនិយាយអំឡុងពេលនេះតែម្ដង នៅក្នុងកិច្ចសម្ភាសន៍ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត លោកបានឆ្លើយថា លោកធ្វើការនៅតំបន់៤២ នៅកន្លែងឡូត៍នេសាទនៅ<> ស្រុកព្រែកប្រសប់ <ខេត្តកំពង់ចាម ចាប់ពីឆ្នាំ១៩៧៥ រហូតទៅដល់ដើម>ឆ្នាំ១៩៧៧។ តើលោកចាំទេ ស៊ូ សឿន ពេលនោះស្ថិតនៅស្រុកព្រែកប្រសប់ដែរឬក៏អត់ទេ នៅក្នុងឆ្នាំ១៩៧៥?

**ឆ៖** បាទ ខ្ញុំមិនដឹងទេ។

**ស៖** នៅពេលដែលលោកនៅក្នុងកងនេសាទនៅក្នុងស្រុកព្រែកប្រសប់ហ្នឹង <តើលោកធ្វើការនៅកន្លែងណា? តើ>លោកនៅ<លើ>ទន្លេមេគង្គ <ឬ>ជាកងនេសាទនៅ<ក្បែរ>ដងទន្លេមេគង្គ ឬក៏យ៉ាងណា?

[០៩:២៣:១៤]

**ឆ៖** បាទ ព្រែកទៅតាមដងទន្លេមេគង្គ ធ្វើផ្សស់។

**ស៖** ហើយនៅចុងឆ្នាំ១៩៧៥ គឺនៅពេលដែលលោកធ្វើការនៅអង្គភាពនេសាទនៅក្នុងស្រុកនោះ តើលោកមានបានដឹងថា ជនជាតិចាមដែលគេដឹកឆ្លងកាត់ទន្លេពីភូមិភាគបូព៌ាឆ្ពោះទៅកាន់ស្រុកព្រែកប្រសប់ដែរទេ?

**ឆ៖** បាទ ខ្ញុំបាទ អត់ដឹងទេ។

**ស៖** ប្រហែលជាខ្ញុំត្រូវការជួយរំឭកការចងចាំរបស់លោកបន្តិច គឺសុំអានឯកសារមួយនៅក្នុង

សំណុំរឿងនេះ គឺឯកសារ E3/154ៗ។ នេះជាសារទូរលេខមកពីភូមិភាគបូព៌ាដែលបានផ្ញើមកឲ្យ ប៉ុល ពត ចម្លងជូន នួន ជា នៅថ្ងៃទី៣០ ខែវិច្ឆិកា ១៩៧៥ ទាក់ទងក៏នឹងផ្លាស់ទីលំនៅប្រជាជនជនជាតិចាម ដែលកើតមានឡើងនៅក្នុងអំឡុងពេលនោះ។ ហើយសម្រង់ដែលខ្ញុំអានជូនលោកពីសារទូរលេខនេះ សូមដកស្រង់៖ "នៅថ្ងៃទី៣០ វិច្ឆិកា ភាគីទាំងពីរបានយល់ស្របថា ការប្រគល់ប្រជាជនដោយភូមិភាគបូព៌ាទៅភូមិភាគឧត្តរ គឺត្រូវធ្វើឡើងនៅស្រុកស្ទឹងត្រង់ និងស្រុកព្រែកប្រសប់។ នៅស្រុកព្រែកប្រសប់ ភូមិភាគឧត្តរត្រូវទទួលប្រជាជនទាំងនេះពីស្រុកឆ្លូង។ ឯនៅស្ទឹងត្រង់ត្រូវទទួលប្រជាជនពីស្រុកពាមជីលាំង និងស្រុកក្រូចឆ្មារ។ បន្ទាប់មកកថាខណ្ឌបន្ទាប់៖ កិច្ចប្រជុំត្រូវបាន<សម្រេច>ថា យើងមិនត្រូវឲ្យប្រជាជនចាមត្រឡប់ទៅក្រចេះវិញទេ។ ភូមិភាគពាយព្យ ហើយនិងភូមិភាគឧត្តរ គឺថាត្រូវទទួលជនជាតិចាមទាំងនេះដាច់ដោយឡែកពីគ្នានៅតាមដងទន្លេមេគង្គ ដើម្បី<បន្ធូរបន្ថយ>ភាពតានតឹង។"

លោកសាក្សី តើលោកមាននៅចាំអំពីការបញ្ជូនប្រជាជនចាម<ដែលមកពីស្រុកផ្សេងៗទៅ>ព្រែកប្រសប់ និងស្ទឹងត្រង់ឆ្លងកាត់ទន្លេ <នៅក្នុង>ភូមិភាគបូព៌ា<> ចុងឆ្នាំ១៩៧៥ ឬដើមឆ្នាំ១៩៧៦ ដែរទេ?

[០៩:២៦:៣៣]

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេលោក។

**ស៖** ប្រធាន<បទ>បន្ទាប់មកទៀត ដែលខ្ញុំចង់សួរលោកនៅថ្ងៃនេះគឺ នៅក្នុងកិច្ចសម្ភាសន៍របស់លោកបាននិយាយយ៉ាងច្រើនអំពីការបោសសម្អាត<កម្មាភិបាល>ភូមិភាគកណ្តាល ឬក៏ថាភូមិភាគឧត្តរចាស់។ នៅក្នុងកិច្ចសម្ភាសន៍របស់លោក លោកឆ្លើយថា នៅដើមឆ្នាំ១៩៧៧ នៅពេលដែលធ្វើការបោសសម្អាតនៅក្នុងភូមិភាគកណ្តាល ឬភូមិភាគឧត្តរចាស់ លោកចាកចេញពីស្រុកព្រែកប្រសប់ ហើយ<ដំបូង>លោកត្រូវបានតែងតាំងឲ្យធ្វើជាអនុប្រធាន<សាធារណការ>តំបន់៤២ ទទួលបន្ទុកក្នុងការជួសជុលផ្លូវ ហើយក្រោយមក<>ក្លាយទៅជាប្រធាន<ពាណិជ្ជកម្ម>តំបន់៤២។ ទី១ ខ្ញុំសួរលោកថា តើអ្នកណាជាអ្នកតែងតាំងលោកឲ្យចូលកាន់មុខតំណែងក្នុងកម្រិតតំបន់នេះ?

**ឆ៖** បាទ ពេលនោះប្អូន អឿន ដែលជាប្អូនជីដូនមួយថ្លៃហ្នឹង គាត់បានយកទៅ។ យកទៅក៏បានឲ្យធ្វើ មិនមែនអនុតំបន់ទេលោក ធ្វើអនុប្រធានហ្កាវ៉ាស ពីដើមហៅថាហ្កាវ៉ាសទេ ប៉ុន្តែគេហៅបច្ចុប្បន្នថាសាធារណការ។ ក្រោយមកបានឲ្យមកធ្វើប្រធានពាណិជ្ជកម្មប្រហែលជា៣ខែ ឡើងធ្វើប្រធានពាណិជ្ជកម្ម។

**ស៖** លោកបានឆ្លើយថា អឿន នេះជាសាច់ថ្លៃរបស់លោក។ តើគាត់ត្រូវជាបង ឬក៏ប្អូនប្រុសរបស់ ស៊្វ សឿន ដែរឬទេ?

**ឆ៖** ជាប្អូនប្រុសរបស់ ស៊្វ សឿន។

[០៩:២៨:៤៨]

**ស៖** ចុះនៅពេលនោះ តើ អឿន ហ្នឹងមានតួនាទីធ្វើអ្វីដែរ ដែលគាត់មានសិទ្ធិតែងតាំងលោកនេះ?

**ឆ៖** បាទ គាត់ធ្វើជាលេខាតំបន់៤២។

**ស៖** ខ្ញុំចង់សួរថាតើ អឿន ក្លាយជាលេខាតំបន់៤២ហ្នឹង<ដោយរបៀប>ណា? តើលោកអាចជម្រាបជូនតុលាការបានទេ ថាលោកចាំអ្វីបានខ្លះដែរ នៅពេលដែលកម្មាភិបាលមកពីភូមិភាគកណ្ដាល ឬក៏ភូមិភាគឧត្តរចាស់ត្រូវបានបោសសម្អាត និងដាក់ជំនួសមកវិញដោយកម្មាភិបាលផ្សេងនោះ? សូមលោករៀបរាប់ជូនអង្គជំនុំជម្រះជារួមនៅក្នុងអំឡុងពេលនោះតែម្ដង។

**ឆ៖** បាទ ពីឆ្នាំ១៩៧៥ ខ្ញុំជាយុទ្ធជនទេ ប៉ុនគេប្រាប់ថា ភូមិភាគកណ្ដាលគឺគេបោសសម្អាតតាំងពីលើដល់ក្រោយ។ ការពិតប្រធានឡូត៍នេសាទ និងកម្មាភិបាលឡូត៍នេសាទរបស់យើងខ្ញុំ គេយកទៅដែរ។ ប៉ុន្តែដឹងបោសមិនបោស បាត់អស់រលីងទាំងប្រពន្ធទាំងកូនន៉ុង។

**ស៖** សូមបញ្ជាក់បន្តិច ការបកប្រែ<ជាភាសាអង់គ្លេស>ថា មកពីភូមិភាគបូព៌ា។ លោកកំពុងតែនិយាយអំពី<>ភូមិភាគកណ្ដាល ឬភូមិភាគឧត្តរចាស់<>?

**ឆ៖** បាទ ខ្ញុំនិយាយអំពីភូមិភាគឧត្តរ ហៅថា ភូមិភាគកណ្ដាល។

**ស៖** នៅក្នុងពេលបោសសម្អាតនេះ តើកម្មាភិបាលភូមិភាគឧត្តរចាស់ប៉ុន្មាននាក់ត្រូវបានចាប់ខ្លួន?

**ឆ៖** បាទ តាមខ្ញុំមើលទៅ អស់ ទាំងអស់។ នៅសល់តែ ពក ហើយនិង អឿន ហ្នឹងដែលជាមេបក្ស ហើយនិងអ្នកតូចៗពីរបីនាក់នៅកន្លែងគាត់ ហើយអ្នកក្រោមៗ អត់មាននៅ អស់ទាំងអស់។

[០៩:៣១:៣៤]

**ស៖** តើលោកនៅចាំអ្វីខ្លះដែរ ថាតើកម្មាភិបាលទាំងអស់នេះ ត្រូវបានគេចាប់ខ្លួន ឬក៏បាត់ខ្លួនដោយរបៀបណាដែរ?

**ឆ៖** បាទ គេថា ពួក សេ.អ៊ី.អា។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** នៅពេលការចាប់ខ្លួននេះ បន្តធ្វើនៅពេលនោះ ហើយកម្មាភិបាលត្រូវបានគេចាប់ខ្លួននោះ តើមានកម្មាភិបាលណាព្យាយាមតដៃ ឬក៏ជំទាស់ ឬក៏តដៃអីទេ?

**ផៈ** បាទ ដូចអត់មានទេ។ គេហៅទៅរៀនៗ បាត់បណ្តោយ។

**សៈ** ហើយតើស្ថានភាពប្រែប្រួលយ៉ាងម៉េចដែរ នៅក្នុងតំបន់របស់លោក នៅពេលដែលកម្មា-ភិបាលចាស់ៗត្រូវបានគេចាប់ខ្លួន ហើយកម្មាភិបាលថ្មីមកពីភូមិភាគនិរតីក៏ត្រូវបានទៅដល់? តើនៅក្នុងតំបន់របស់លោកនោះ ស្ថានភាពប្រែប្រួលយ៉ាងម៉េចដែរ សូមលោកជម្រាបជូនតុលាការបន្តិចមើល៍?

**ផៈ** បាទ ពេលនោះ ពេលដែលបោសសម្អាតហើយ រៀបចំកម្មាភិបាលមកពីនិរតី ខ្ញុំបាទអត់បានដឹងទេ បញ្ហាការរៀបចំរចនាសម្ព័ន្ធ។

[០៩:៣៣:២៨]

**សៈ** តើកម្មាភិបាលភូមិភាគនិរតីប្រព្រឹត្តធ្វើបាបប្រជាជនដែរឬទេ នៅពេលដែលពួកគេទៅដល់តំបន់របស់លោក?

**ផៈ** បាទ ពេលនោះគឺបើសិនណាជាការពិត គ្រាន់តែខ្លាចៗអ៊ីចឹង ដូចថាបងៗមកពីខាងនោះស្រូវគេខ្លី ច្រូតស្រូវខ្លី ដល់យើងច្រូតស្រូវយើងអត់កើត គេថា ខ្មាំងអី គេអត់ជិះរទេះ គេនេះ -- យើងអ្នកជិះ អាហ្នឹងគេខ្មាំងដែរ អ៊ីចឹងពិបាកដែរកាលនោះ។ នេះខ្ញុំដឹងដែលថាតាមគេទេ ឯខ្ញុំមិនបានឃើញជាក់ស្តែងទេ។

**សៈ** ខ្ញុំសូមអានចម្លើយដែលឆ្លើយដោយ កែ ពក អតីតលេខាភូមិភាគដែលគាត់បានឆ្លើយក្នុងឆ្នាំ ២០០២ គឺឯកសារ E3/2782 ហើយឯកសារនេះ ក៏ជាឯកសារលេខ E3/2783 ដែរ។ ERN ជាភាសាអង់គ្លេស 00089714, ខ្មែរ 00095552, បារាំង 00596212។ នៅក្នុងកិច្ចសម្ភាសន៍នេះ កែ ពក បានចោទប្រកាន់កម្មាភិបាលមកពីភូមិភាគនិរតីថា "ធ្វើបាបប្រជាជនយ៉ាងធ្ងន់ធ្ងរ"។ គាត់បានលើកឧទាហរណ៍ដែលកម្មាភិបាលនិរតីដែលតែងតាំងឲ្យទៅ ចាត់តាំងឲ្យទៅធ្វើការនៅស្រុកសណ្តាន់ ហើយ <>បាន<ដុត>ប្រជាជន<ឲ្យ>ស្លាប់<នៅក្នុងឡឥដ្ឋ>យ៉ាងច្រើន។ <ហើយគាត់បានឆ្លើយថា> សូមដកស្រង់៖ "កម្មាភិបាលអាក្រក់ៗ កម្មាភិបាលបិសាចនេះមកពីភូមិភាគនិរតីនេះ គឺថាបានបង្កបញ្ហាយ៉ាងច្រើននៅក្នុងភូមិភាគរបស់ខ្ញុំ។" យោងទៅលើអ្វីដែលលោកបានឃើញនៅពេលនោះ តើថាលោកខ្លួនឯងផ្ទាល់នេះយល់ស្របជាមួយនឹងការរៀបរាប់របស់ កែ ពក អំពីការមកដល់របស់កម្មាភិបាលភូមិភាគនិរតី<ក្នុង>ភូមិ<ភាគរបស់លោក>ដែរទេ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់។

[០៩:៣៦:១៨]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! ចាំស្ដាប់ការជំទាស់របស់មេធាវីការពារ នួន ជា សិន។

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ និយាយសាឡើងវិញ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ទៅនឹងសំណួរនេះ សាក្សីបានឆ្លើយថាគាត់មិនបានឃើញអ្វីដោយផ្ទាល់ភ្នែកនោះទេ ពាក់ព័ន្ធទៅនឹងការប្រព្រឹត្ត ឬក៏ធ្វើបាបមកលើប្រជាជន<ដោយកម្មាភិបាលភូមិភាគនិរតីទេ>។ ការអានផ្នែកមួយនៃចម្លើយរបស់ កែ ពក គឺថាវានាំឲ្យសាក្សីឆ្លើយដោយស្មានៗទៅវិញទេ។ ដូច្នេះ ខ្ញុំសូមជំទាស់នឹងសំណួរនេះ។

**លោក ឌេល លីសាក់៖**

ខ្ញុំសូមឆ្លើយតបលោកប្រធាន។ ខ្ញុំបានអនុវត្តធ្វើរបៀបនេះនៅក្នុងកិច្ចដំណើរការនីតិវិធី<ដែលបានអនុវត្តដោយគ្រប់ភាគីទាំងអស់នៅក្នុងតុលាការនេះ> រួមទាំងមេធាវីការពារក្ដីខ្លួនឯងផ្ទាល់ផងដែរ។ <ខ្ញុំបានសួរសំណួរបើកជាមុន ហើយ>ឥឡូវនេះខ្ញុំអានភស្តុតាងមួយដែលមាននៅក្នុងសំណុំរឿងរួចទៅហើយ ហើយចង់ជួយរំឭកដល់ការចងចាំរបស់សាក្សី និងចង់ដឹងថាតើគាត់យល់ ឬក៏ថាមានប្រតិកម្មយ៉ាងម៉េចដែរចំពោះចម្លើយរបស់ កែ ពក នេះ? <គ្រប់ភាគីទាំងអស់នៅក្នុងតុលាការនេះបានធ្វើតាមការអនុវត្តបែបនេះ។>

**លោក បាន សៀក៖**

**ឆ៖** ខ្ញុំបាទអត់យល់។

[០៩:៣៧:៤០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៨:០០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចថា បដិសេធចោលនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក នួន

ជា ក្នុងការតាំងសំណួរចុងក្រោយរបស់ក្រុមសហព្រះរាជអាជ្ញារងអន្តរជាតិអម្បាញ់មិញនេះ។ ហើយសូមបញ្ជាក់ថា ទាំងសហព្រះរាជអាជ្ញា រួមទាំងមេធាវីពាក់ព័ន្ធផ្សេងទៀត ក៏គប្បីចៀសវាងក្នុងការប្រើពាក្យឲ្យសាក្សីផ្តល់នូវការពាក្យថា "យល់ឃើញ" ជាពាក្យបង្ហាញពីភាពអត្តនោម័តិរបស់ខ្លួនដែរ។ ដោយសារវាប្រតិកម្មទៅលើសក្ខីកម្មនោះ គឺវាយើងអាចទទួលយកបាន តែបើឲ្យគាត់បង្ហាញពីការយល់ គឺបង្ហាញពីការចាប់បញ្ចេញគំនិតអត្តនោម័តិនោះ គឺមិនអាចទទួលបានទេ។

សាក្សីឆ្លើយតបនឹងសំណួរចុងក្រោយដែលសំណួរអម្បាញ់មិញនេះ បើសិនជាលោកនៅចងចាំ។

**លោក បាន សៀក៖**

**ឆ៖** ខ្ញុំអត់បានដឹងផង។ ខ្ញុំនៅជាយុទ្ធជនឡូត៍នេសាទ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** តាមពិតទៅលោកសាក្សី ខ្ញុំឥឡូវនេះកំពុងសួរអំឡុងពេល<បន្ទាប់ពី>លោកធ្វើការនៅឡូត៍នេសាទ គឺក្នុងឆ្នាំ១៩៧៧ នៅពេលដំបូងលោកជាអនុ<ប្រធានសាធារណការ>តំបន់<> ហើយក្រោយមកក៏ក្លាយទៅជាប្រធានពាណិជ្ជកម្ម<តំបន់៤២>។ លោកសាក្សី តើលោកមានបានកត់សម្គាល់ឃើញថាមានការធ្វើបាបប្រជាជនពីសំណាក់កម្មាភិបាលនិរតី ដែលស្រដៀងគ្នា <>ទៅនឹងអ្វីដែលបានរៀបរាប់ដោយ កែ ពក នេះដែរឬទេ?

[០៩:៣៩:៥៨]

**ឆ៖** បាទ អត់បានដឹងទេលោក។

**ស៖** លោកសាក្សី តាមដែលលោកដឹង តើ កែ ពក ទុកចិត្តកម្មាភិបាលមកពីនិរតីដែរឬទេ? តើគាត់ចង់ឲ្យគេដក<>កម្មាភិបាលភូមិភាគឧត្តរចាស់ ហើយ<>ដាក់ជំនួសដោយដោយកម្មាភិបាលមកពីភូមិភាគនិរតីដែរទេ?

**ឆ៖** បាទ ខ្ញុំមិនយល់បញ្ហាហ្នឹងលោក។

**លោក ឌេល លីសាក់៖**

បាទ ឥឡូវនេះខ្ញុំសួរឲ្យបានលម្អិតបន្តិច។ នៅពេលនេះលោកប្រធាន យើងខ្ញុំសូមការអនុញ្ញាតផ្តល់ចម្លើយ<របស់គាត់ដែល>ឆ្លើយជូនការិយាល័យសហចៅក្រមស៊ើបអង្កេតមុនៗនេះ។ ខ្ញុំមានកំណត់ហេតុស្តាប់ចម្លើយនេះប្រាំ។ ដោយសារតែពេលវេលា ដូច្នេះយើងខ្ញុំសូមការអនុញ្ញាតផ្តល់កំណត់ហេតុស្តាប់ចម្លើយទាំងប្រាំនេះ។ ទាំងប្រាំនេះគឺមាន E3/5275 និង E3/375, E319/19.3.73,

E319.19.3.86, និង E319/28.3.1។ ដូច្នេះ យើងខ្ញុំសូមការអនុញ្ញាតផ្តល់កំណត់ហេតុស្តាប់ចម្លើយទាំងប្រាំជូនទៅសាក្សី លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

កំណត់ហេតុស្តាប់ចម្លើយបុគ្គលណាមួយទៅ?

**លោក ឌេល លីសាក់៖**

កំណត់ហេតុស្តាប់ចម្លើយទាំងប្រាំនេះ គឺជាកំណត់ហេតុស្តាប់ចម្លើយសាក្សីនេះ <គឺលោក បាន សៀក> តែម្តងលោកប្រធាន។

[០៩:៤២:២៥]

**លោក វ៉ិចទ័រ កូប៉េ៖**

<លោកប្រធាន។>

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំដឹងថា ការអនុវត្ត<នៃការ>តាំងសំណួរ<>បែបនេះ គឺថាធ្លាប់ធ្វើពីមុន <ដូច្នេះប្រហែលអង្គជំនុំជម្រះអាចនឹងផ្តល់ការអនុញ្ញាត>។ <ប៉ុន្តែ វាមិនសមហេតុផលទេដែល>ផ្តល់<ជូនសាក្សីនូវ>កំណត់ហេតុស្តាប់ចម្លើយ<របស់ខ្លួនគាត់ផ្ទាល់>ដែលគាត់បានឃើញ<ឯកសារនោះ>រួចមកហើយ<។ សាក្សីទើបតែ>ផ្តល់សក្ខីកម្មតាមរយៈការសួរសំណួរផ្ទាល់ៗតែម្តងទៅ។ ការអានសម្រង់មកឲ្យសាក្សីស្តាប់នេះ<មិនបានផ្តល់ផល>អ្វីនោះទេ បើទោះបីជាថាទម្លាប់នេះធ្លាប់<បានអនុញ្ញាតឲ្យ>អនុវត្តពីមុន តាំងពីមុនមកក្តី។ ហើយឥឡូវនេះ យើងខ្ញុំ<សូមជំទាស់ចំពោះការអនុវត្តលើសាក្សីរូបនេះ ហើយវាជាការរម្លឹកផងដែរថាយើង>ក៏កំពុងតែរង់ចាំ<>សេចក្តីសម្រេចពីអង្គជំនុំជម្រះយ៉ាងអន្ទះអន្ទែងពាក់ព័ន្ធទៅនឹង<សំណើរបស់យើងដែលថាមិនឲ្យ>ការផ្តល់<ឯកសារផ្សេងៗ ឬ>កំណត់ហេតុ<ស្តាប់ចម្លើយទៅសាក្សីដែលមកផ្តល់សក្ខីកម្ម>។

**លោក ឌេល លីសាក់៖**

សូមឆ្លើយតបសង្ខេបទេ លោកប្រធាន។ នេះគឺជាការអនុវត្តជាធម្មតាទៅហើយ<នៅក្នុងតុលាការ> ហើយវាត្រឹមត្រូវហើយក្នុងការអនុញ្ញាតឲ្យយើងខ្ញុំសួរទៅគាត់<អំពីចម្លើយតបជាក់លាក់

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នៅក្នុងកិច្ចសម្ភាសន៍>របស់គាត់ <ហើយគាត់មានចម្លើយតបសម្រាប់ពិនិត្យមើលដោយខ្លួនឯងបាន>។

[០៩:៤៤:០៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចបដិសេធចោលនូវសេចក្ដីជំទាស់របស់មេធាវី វ៉ិចទ័រ កូប៉េ មេធាវីការពារក្ដីលោក នួន ជា ហើយយើងអនុវត្តបន្តទៀតរបៀបនេះ ដោយសារយើងមានទម្លាប់អនុវត្តតាំងពីដើមមក ហើយចំពោះសេចក្ដីសុំឲ្យអង្គជំនុំជម្រះបញ្ជាក់នោះ គឺអង្គជំនុំជម្រះបានជម្រាបជូនកាលពីសប្ដាហ៍រួចហើយ អង្គជំនុំជម្រះបាននឹងកំពុងតែពិនិត្យចេញសេចក្ដីសម្រេចលើសំណើសុំបញ្ជាក់របស់មេធាវីការពារក្ដី នួន ជា ហើយអង្គជំនុំជម្រះនឹងផ្សព្វផ្សាយជូនម្ចាស់សំណើ និងភាគីក្នុងអំឡុងពេលឆាប់ៗខាងមុខនេះ។

ហើយមន្ត្រីរដ្ឋបាលតុលាការ អង្គជំនុំជម្រះអនុញ្ញាត ហើយនិងយកឯកសារពីសហព្រះរាជអាជ្ញារងអន្តរជាតិជូនទៅសាក្សី។

**លោក ឌេល លីសាក់៖**

បាទ សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី និងមេធាវីប្រឹក្សា <ចម្លើយដែលខ្ញុំចង់ឲ្យលោកយោងទៅរក នោះគឺ>ឯក-សារចុងក្រោយ គឺឯកសារ E319/28.3.1 ចម្លើយលេខ៣ នៅចុងបំផុតនៃចម្លើយ លោកបានឆ្លើយដូចតទៅ សូមដកស្រង់៖ "តាមខ្ញុំយល់ស្ថានភាពនៅពេលនោះ ខ្ញុំដឹងថា កែ ពក មិនមានទំនាក់ទំនងល្អជាមួយនឹង សុន សេន ទេ ហើយគាត់មិន<ទុក>ចិត្តលើ<កម្មាភិបាលភូមិភាគ>និរតីដែរ។" បញ្ចប់ការដកស្រង់។ តើធ្វើម៉េចទើបបានលោកដឹងថា កែ ពក មិនទុកចិត្តកម្មាភិបាលមកពីនិរតី?

[០៩:៤៥:៥៧]

**លោក បាន សៀក៖**

**ឆ៖** ខ្ញុំមិនយល់ទេ ព្រោះ សុន សេន គាត់ធំជាង កែ ពក អ៊ីចឹងហើយ កែ ពក គាត់អ្នកអត់ចេះអក្សរផង ចេះតិចៗ រួចចេះមិនដឹងជាយ៉ាងម៉េចគាត់ អ្នកនយោបាយខាងលើ ខ្ញុំអត់ដែល។

**ស៖** បាទ ឥឡូវនេះយើងកំពុងតែនិយាយគ្នាអំពីការបោសសម្អាតនៅក្នុងភូមិភាគរបស់លោក តើលោកដឹងថាអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការបញ្ជាឲ្យចាប់ខ្លួនកម្មាភិបាលភូមិភាគកណ្ដាល ឬក៏

ថាកម្មាភិបាលភូមិភាគឧត្តរចាស់នេះ? តើ<នេះជាអ្វីដែល> កែ ពក <បានសម្រេចចិត្តធ្វើដោយខ្លួនឯងមែនដែរឬទេ>?

**ឆ៖** បាទ តាមខ្ញុំជាយុទ្ធជនមើលទៅ មិនមែន កែ ពក ទេ ពីព្រោះពីខាងលើព្រោះយកទៅបាត់ៗយកទៅលើនោះ ឱ្យតែកម្មាភិបាល។ បើជាយុវជន កម្មាភិបាលតូចៗ ជាជនបង្គោលអីអាចខាងក្រោម ប៉ុនបើថាថ្នាក់តំបន់ ថ្នាក់ស្រុកអីហើយ អត់មាននៅនឹងកន្លែងទេ ភូមិភាគទេ ទៅដល់ភ្នំពេញហើយ។

**ស៖** ឥឡូវនេះ ខ្ញុំសូមអានសម្រង់ខ្លីដែលលោកបានឆ្លើយ គឺឯកសារ E319/19.3.86 ឯកសារ E319/19.3.86 ត្រង់ចម្លើយលេខ៦៤ លោកបានឆ្លើយថា សូមដកស្រង់៖ "តាមខ្ញុំដឹងសេចក្តីសម្រេច ឬបញ្ជាឱ្យធ្វើការបោសសម្អាត ឬសម្លាប់មនុស្សគឺចេញមកពីមន្ទីរ៨៧០ មិនមែន កែ ពក ឬតំបន់ជាអ្នកសម្រេចទេ។" បញ្ចប់ការដកស្រង់។ សំណួររបស់ខ្ញុំ សួរថាតើធ្វើម៉េចបានជាលោកដឹងថាការបញ្ជាឱ្យបោសសម្អាត ឬក៏សម្លាប់មនុស្សនោះ គឺថាចេញមកពីមន្ទីរ៨៧០?

[០៩:៤៨:២៧]

**ឆ៖** បាទ ពេលនោះ ខ្ញុំដឹងថាបងប្អូនរបស់ កែ ពក ជាកម្មាភិបាលហ្នឹង យល់ថាបើបាត់ កែ ពក យើងទាំងអស់គ្នាក៏អស់ទាំងអស់គ្នា ងាប់ទាំងអស់គ្នាដែរ។ អីចឹងបានមិនមែនរឿងរបស់ កែ ពក ទេ ជារឿងរបស់ខាងលើតែម្តង។ ដូច្នេះភូមិភាគគេបោសទាំងអស់ នៅតែនិរតីទេ។

**ស៖** លោកបានឆ្លើយថានៅដើមឆ្នាំ១៩៧៧ គឺជាពេលដែល អឿន បានក្លាយទៅជាលេខាតំបន់៤២ ហើយដំបូងឡើយ លោកក៏ត្រូវបានតែងតាំងឱ្យធ្វើការនៅក្នុងកងមួយចំណុះឱ្យតំបន់នេះទទួលបន្ទុកខាងផ្នែកសាងសង់ផ្លូវនេះ។ តើលោកចាំទេ នៅក្នុងឆ្នាំ<១៩៧៧>ហ្នឹង <តើ>លោកចាំខែទេ ខែអ្វីដែរ?

**ឆ៖** បាទ ខ្ញុំអត់ចាំទេលោក។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមការអនុញ្ញាតរំឭកការចងចាំរបស់សាក្សី និងដើម្បីចង់ដឹងអំពីការបាត់ខ្លួនរបស់កម្មាភិបាលមួយចំនួន<នៅពេលនោះ> ខ្ញុំចង់ផ្តល់ឱ្យ គឺឯកសារ E3/2956 ឯកសារនេះ គឺជាបញ្ជី<ស-២១ ដែលមានចំណងជើងថា "បញ្ជីឈ្មោះ>មនុស្សដែលបញ្ជូនមកពីភូមិភាគឧត្តរ ពីថ្ងៃទី០១ កុម្ភៈ ៧៧ ដល់២៧ មីនា ៧៧" ដែលសរុបទាំងអស់មានកម្មាភិបាល៩៤នាក់ មកពីភូមិភាគ<>ឧត្តរ<>នេះ ដែលត្រូវបានចាប់ខ្លួននៅក្នុងអំឡុងពេលនោះ ហើយបញ្ជូនមកស-២១។ បើអង្គជំនុំជម្រះអនុញ្ញាត ខ្ញុំសូមឱ្យប្រគល់ឯកសារនេះទៅសាក្សី ដើម្បី<ខ្ញុំអាចសួរ>គាត់<អំពី>កម្មាភិបាល<មួយ

ចំនួន>ដែល<មានឈ្មោះនៅក្នុងបញ្ជី>នោះ។

[០៩:៥០:៥២]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ដោយយោងទៅលើមូលដ្ឋានដូចមុនដែរ <គឺខ្ញុំតែងតែជំទាស់ទៅនឹងការអនុវត្តបែបនេះ>។ ដោយសារ គាត់មិនបានដឹង ឬជាប់ពាក់ព័ន្ធអីទៅនឹងឯកសារបញ្ជូនមកមន្ទីរសន្តិសុខ ស-២១ ទេ<។ គាត់មិនធ្លាប់ធ្វើការនៅស-២១ ហើយ>គាត់មិនពាក់ព័ន្ធក្នុងការចាប់ខ្លួនកម្មាភិបាលទាំងនេះទេ។ <ទោះបីជាដឹងថា>លោកប្រធាន<នឹង>សម្រេចបដិសេធទៅនឹងការជំទាស់របស់ខ្ញុំ<ក៏ដោយ ប៉ុន្តែសម្រាប់ជាផលប្រយោជន៍ដែលអាចមានបណ្ដឹងសាទុក្ខជាលើកទី២> ខ្ញុំ<សូមជំទាស់ចំពោះការអនុវត្តបែបនេះ>។

**លោក ឌេល លីសាក់៖**

<ខ្ញុំនឹងឆ្លើយតបខ្លីៗ>។ លោកប្រធាន <នេះជាអ្វីដែល>អង្គជំនុំជម្រះបានសម្រេចហើយ។ សាក្សីរូបនេះ គឺគាត់គឺជា<កម្មាភិបាល>ថ្នាក់តំបន់<ដែលអាចស្គាល់>មនុស្ស<មួយចំនួន>ដែលមាននៅក្នុងបញ្ជីនេះ។ <ហើយនេះជាមូលដ្ឋានគ្រឹះដែលត្រូវសួរសាក្សីអំពីបញ្ជីនេះ។>

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចបដិសេធនូវសេចក្ដីជំទាស់របស់លោកមេធាវី វ៉ិចទ័រ កូប៉េ មេធាវីការពារក្ដី នួន ជា ក្នុងការដាក់បង្ហាញឯកសារដែលស្នើឡើងដោយសហព្រះរាជអាជ្ញាចំពោះមុខសាក្សីរូបនេះ ដោយយកមូលហេតុ យើងគឺអនុវត្តដូចអ្វីដែលយើងបានទម្លាប់អនុវត្តពីមុនមក មិនទាន់មានការផ្លាស់ប្ដូរទេ។ អង្គជំនុំជម្រះក៏មិនទាន់បានចេញសេចក្ដីសម្រេចអ្វីដែលនាំឱ្យមានការផ្លាស់ប្ដូរទម្លាប់អនុវត្ត កាលពីធ្លាប់អនុវត្តតាំងទីកន្លងមក រហូតដល់ពេលនេះដែរ។

មន្ត្រីរដ្ឋបាលតុលាការទទួលយកឯកសារពីសហព្រះរាជអាជ្ញារងអន្តរជាតិជូនសាក្សីពិនិត្យ។

[០៩:៥២:៣៩]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី ឯកសារដែលលោកបានទទួល E3/2956 នេះ កំណត់អត្តសញ្ញាណឈ្មោះ

កម្មាភិបាល<មួយចំនួនមកពី>ភូមិភាគ<របស់លោកដែលត្រូវបានចាប់ខ្លួន ហើយបញ្ជូនមក ស-២១ នៅ>ចន្លោះ<ខែ>កុម្ភៈ ១៩៧៧ <ឬខែ>មីនា ៧៧។ <ដំបូង> ខ្ញុំសូមឲ្យលោកមើលត្រង់លេខរៀង ៤២នៅលើបញ្ជីនេះ<។ បើក្រឡេកមើលទៅលេខ៤២> ខ្ញុំក៏បាន<>គូសពណ៌ចំណាំនៅលើនេះ <អ្នកនោះ>ឈ្មោះ ចាន់ ម៉ុល ហៅ តុល ដែលគេស្គាល់ថាជាប្រធានតំបន់៤២ ហើយចូលមក ស-២១ នៅថ្ងៃទី១៩ កុម្ភៈ ១៩៧៧។ សំណួររបស់ខ្ញុំ លោកចាំថា តុល នោះជាលេខាតំបន់៤២ មុន អឿន ឬក៏យ៉ាងណា?

**លោក បាន សៀក៖**

**ឆ៖** គឺឈ្មោះ តុល មិនមែនឈ្មោះនេះទេ ឈ្មោះ តុល។ ឈ្មោះ តុល នៅបាក់ស្នាគាត់ បានខ្ញុំដឹង ព្រោះគាត់មកធ្វើជាលេខាតំបន់មុន អឿន ហ្នឹងយូរហើយ តាំងពីឆ្នាំយើងរំដោះមក តាំងពីមុនរំដោះគាត់ឈរនៅកន្លែងហ្នឹងយូរហើយ ប៉ុន្តែខ្ញុំអត់ស្គាល់មុខទេ ចាំតែគេហៅឈ្មោះ តុលៗ ពួកគេហៅពួកខ្មែរក្រហមចាស់។

[០៩:៥៤:៣០]

**ស៖** សូមទោសផងដែរលោកសាក្សី ចំពោះការអានឈ្មោះក្រែងលោវាមិនច្បាស់។ ឯកសារនេះបង្ហាញថានៅក្នុងខែកុម្ភៈ និងខែមីនា ១៩៧៧ ប្រធានតំបន់៤២ <ឈ្មោះ តុល> ហើយនិងកម្មាភិបាលថ្នាក់ស្រុក<, ថ្នាក់តំបន់ និងភូមិភាគផ្សេងទៀត>ហ្នឹងត្រូវបានគេបោសសម្អាត។ សំណួររបស់ខ្ញុំ តើវាពេលតែមួយឬ នៅក្នុងខែកុម្ភៈ និងខែមីនា ១៩៧៧ គឺជាពេលដែល អឿន ត្រូវបានតែងតាំងឲ្យធ្វើជាលេខា<ថ្មីនៅ>តំបន់៤២ ហើយលោកក៏ត្រូវបានតែងតាំងឲ្យធ្វើកិច្ចការ<>ខាងផ្នែកសាធារណការ។ តើអីចឹង ឬក៏យ៉ាងណា?

**ឆ៖** បាទ ខ្ញុំបាទមកនៅ អឿន មកយូរហើយ មកធ្វើប្រហែលជា គិតថាប្រហែលជាបួនប្រាំខែទៅ ប៉ុណ្ណឹង។ ឯមុននោះខ្ញុំនៅតែឡូត៍នេសាទ ខ្ញុំអត់ដឹងអីទេ ខ្ញុំជាយុទ្ធជន។ អឿន យកខ្ញុំមកហ្នឹង មកធ្វើអនុប្រធាន ហៅថាហ្គារ៉ាស។ ហ្គារ៉ាសហ្នឹងនៅថ្នល់បែកហ្នឹងធ្វើ បើយើងឥឡូវហៅថាសាធារណការ។ តែរឿងបោសសម្អាតអតីតកម្មាភិបាលរបស់តំបន់ និងភូមិភាគ ខ្ញុំបាទអត់ដឹងទេ ព្រោះយុទ្ធជន តែមេខ្លួនឯង គេយកមកបាត់ៗ ក៏មិនដឹងដែរបាទ។ អត់ដឹងផង។

**ស៖** បាទ ដូច្នេះសូមបញ្ជាក់បន្តិច <តើនេះ>គឺជាចម្លើយរបស់លោក<ដែល>ឆ្លើយថា បីបួនខែក្រោយពេល អឿន ក្លាយទៅជាលេខាតំបន់៤២ <>លោកក៏ត្រូវបានតែងតាំងឲ្យទៅធ្វើ<ការនៅ

កង>មួយ<ខាង>ផ្នែកសាធារណការដែរ។ បាទ ខ្ញុំយល់អ៊ីចឹងត្រឹមត្រូវដែរទេ?

[០៩:៥៦:៣៦]

**ឆ៖** បាទ ប្រហែលជា ខ្ញុំមិនដឹងជាគាត់ធ្វើថ្ងៃណា ប៉ុន្តែដូចជាគាត់ធ្វើ មុនដំបូងធ្វើចៅហ្វាយស្រុកស្ទឹងត្រង់ លេខាស្ទឹងត្រង់ ថាឮសួរដែរ ប៉ុន្តែខ្ញុំឮសួរថា អឿន ឥឡូវគាត់គេមកធ្វើលេខាស្រុកស្ទឹងត្រង់ គាត់មកពីសៀមរាបមក។ ដល់ក្រោយមកថា ឥឡូវឡើងលេខាតំបន់ហើយ។ ដល់ប្រហែលជាដល់ប្រហែលជាបួនប្រាំប្រាំមួយប្រាំពីរខែទៅ បានដើររកបងប្អូនហើយ យកមកធ្វើការ ព្រោះអស់ហើយកម្មាភិបាលភូមិភាគឧត្តរ ភូមិភាគកណ្ដាលអស់រលីងហើយ អត់មានសល់នរណាទេ។ តាំងពី -- ចង់និយាយថា សម្ព័ន្ធយុវជនទៅ ជនបង្គោលទៅ បក្ខជន ត្រៀមបក្ខជនពេញសិទ្ធិ អស់ទាំងអស់។ ឲ្យតែប្រធានកងអស់ អស់រលីងទាំងអស់ អត់មានសល់។

**ស៖** ឥឡូវនេះ ខ្ញុំសុំសួរលោកអំពីពេលវេលាដែលលោកត្រូវបានតែងតាំងឲ្យធ្វើជាអនុប្រធានសាធារណការទទួលបន្ទុកខាងជួសជុលផ្លូវ។ តើមន្ទីរសាធារណការហ្នឹងស្ថិតនៅកន្លែងណាដែរ? នៅពេលហ្នឹង លោកធ្វើការ កន្លែងលោកធ្វើការហ្នឹងមានទីតាំងនៅត្រង់កន្លែងណាដែរ?

**ឆ៖** បាទ ថ្នល់បំបែកនៅកន្លែងហ្កាវ៉ាសសាំងតែម្ដង អ៊ុំ នៅហ្កាវ៉ាសធ្វើឡានតែម្ដង នៅកន្លែងហ្នឹង ត្រង់ថ្នល់បំបែក ខាងណេះកន្លែងមន្ទីរតំបន់ ខាងមុខណេះកន្លែងសាធារណការ កន្លែងហ្កាវ៉ាស។ ដូចថាខែថ្ងៃដែលចូល ខ្ញុំមិនចាំទេ ព្រោះទៅហ្នឹងព្រលឹងចុងសក់ដែរ ព្រោះវាប្រវត្តិមិនល្អ។

[០៩:៥៨:២៣]

**ស៖** នៅពេលដែលលោកនិយាយត្រង់ផ្លូវបំបែកដែលជាមន្ទីរតំបន់ ដែលជាទីតាំងរបស់មន្ទីរតំបន់ តើស្ថិតនៅក្នុងស្រុកណាដែរ នៅក្នុងទឹកដីរបស់ស្រុកណាដែរ?

**ឆ៖** បាទ នៅក្នុងស្រុកចំការលើ ឃុំស្វាយទាប។

**ស៖** ហើយតើលោកធ្វើការនៅមន្ទីរសាធារណការនេះអស់រយៈពេលប៉ុន្មានដែរ មុននឹងលោកត្រូវបានតែងតាំងឲ្យធ្វើជាប្រធានពាណិជ្ជកម្មតំបន់<៤២>?

**ឆ៖** បាទ ប្រហែលជាបីទៅបួនខែ ទៅធ្វើជាប្រធានពាណិជ្ជកម្ម។

**ស៖** ក្នុងអំឡុងពេលដែលលោកធ្វើការជាអនុប្រធានតំបន់<៤២>ទទួលបន្ទុកកិច្ចការសាធារណការ លោកដឹងថាប្រធាន<សាធារណការភូមិភាគ>ជាអ្នកណាដែរពេលនោះ?

**ឆ៖** កាលខ្ញុំទៅធ្វើ អឿន ជាប្រធានតំបន់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** បាទ ខ្ញុំសូមសួរម្តងទៀតថា ចុះអ្នកណាជាប្រធានសាធារណការភូមិភាគ? គឺអំឡុងពេលដែលលោកធ្វើការនៅខាងផ្នែកអង្គភាព ឬក៏មន្ទីរសាធារណការតំបន់នេះ អ្នកណាជាប្រធានសាធាណ-ការថ្នាក់ភូមិភាគ?

**ឆ៖** កាលនោះតែខ្ញុំដឹងថា ប្អូនឆាំ ឥឡូវគាត់ស្លាប់បាត់ហើយ។ ប្អូនឆាំ ហ្នឹងគាត់ពីដើមនីរសាររបស់ កែ ពក ដល់ក្រោយមកអស់កម្មាភិបាលទៅ គាត់មកធ្វើសាធារណការ។ ពេលនោះសាធារណ-ការ ដូចជាងសំណង់ទេ ធ្វើទំនប់ធ្វើអីហ្នឹង តាមខ្ញុំដឹង ថាគាត់ពូកែខាងលាយស៊ីម៉ង់ត៍អី ធ្វើទំនប់ទេ ប៉ុន្តែគេដាក់សាធារណការទៅ។

[១០:០១:១៥]

**ស៖** តើលោកចាំកម្មាភិបាលឈ្មោះ សោ ដែរទេ ដែលជាប្រធានសាធារណការមុនឈ្មោះ ឆាំនេះ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ទេលោក។

**ស៖** ឥឡូវនេះ ខ្ញុំនិយាយអំពីរយៈពេលដែលលោកក្លាយជាប្រធានពាណិជ្ជកម្មតំបន់៤២។ ខ្ញុំចង់ដឹងថា តើមន្ទីរពាណិជ្ជកម្មតំបន់៤២ហ្នឹង មានទីតាំងស្ថិតនៅកន្លែងណា?

**ឆ៖** នៅក្នុងវត្តមួយ វត្តខ្ញុំមិនចាំទេ ដូចវត្តជយោ នៅស្តី នៅនឹងវត្ត ប៉ុន្តែអត់ចាំទេ ព្រោះតិចពេកអត់ចាំវត្តនឹងគេទេ។ នៅនឹងវត្ត បាទ នៅនឹងវត្ត នៅនឹងវត្តលោក។

**ស៖** <ដើម្បីឲ្យច្បាស់> មន្ទីរពាណិជ្ជកម្មតំបន់៤២ ដែលលោកធ្វើការនោះ គឺស្ថិតនៅក្នុងភូមិស្តី <ឃុំជយោ តើ>មែនទេ?

**ឆ៖** ភូមិស្តី ពីដើមឃុំជយោ។ ខ្ញុំមិនចាំទេ ភ្លេចហើយអាហ្នឹងនោះ ព្រោះថានៅក្នុងវត្ត បើនៅក្នុងទីប្រជុំ នៅទីប្រជុំ ហៅស្តី។

**ស៖** តើមន្ទីរតំបន់៤២ហ្នឹង បើធៀបទៅនឹងមន្ទីរ<តំបន់>ដែល អឿន ធ្វើការហ្នឹង តើចម្ងាយពីគ្នាប៉ុន្មានដែរ?

**ឆ៖** ប្រធានតំបន់៤២ អឿន នៅកន្លែងនឹងតំបន់៤២តែម្តង នៅកន្លែងមន្ទីរតំបន់ហ្នឹងឯង នៅផ្ទះនៅតំបន់។

**ស៖** អ្វីដែលខ្ញុំសួរហ្នឹង គឺខ្ញុំចង់ដឹងថា <មន្ទីរតំបន់ ដែលអឿន ធ្វើការនោះ គឺវាស្ថិតនៅទីតាំងតែមួយនឹង>មន្ទីរពាណិជ្ជកម្ម <ឬវានៅក្នុងភូមិ ឬឃុំផ្សេងគ្នា>?

**ឆ៖** មន្ទីរពាណិជ្ជកម្ម និងមន្ទីរតំបន់ឆ្ងាយគ្នា។ អំមិញខ្ញុំច្រឡំថាមន្ទីរ អឿន ធ្វើការ។ នៅឆ្ងាយពីគ្នាប្រហែលជា២គីឡូ។ ២ឡូ ព្រោះពីឃុំស្វាយទាប ទៅឃុំជយោហ្នឹង ប្រហែល២គីឡូ។

[១០:០៤:២៥]

**ស៖** តើលោកចាំទេ នៅពេលនោះអ្នកណាជាប្រធានពាណិជ្ជកម្មភូមិភាគហ្នឹង ពេលដែលលោកធ្វើជាប្រធានពាណិជ្ជកម្មតំបន់៤២ហ្នឹង អ្នកណាជាប្រធានពាណិជ្ជកម្មភូមិភាគ?

**ឆ៖** បាទ ប្រធានពាណិជ្ជកម្មភូមិភាគ ឈ្មោះ ◌ុ◌ុ◌ះ<ដៃ> កាលនោះ។

**ស៖** តើលោកចាំទេថា នៅឆ្នាំ១៩៧៧ តើមានរឿងអ្វីកើតឡើងចំពោះឈ្មោះ <ដៃ> ទេ?

**ឆ៖** ជ័យ ហ្នឹងចាប់ខ្លួនបាត់ហើយ។ ចាប់យកទៅភ្នំពេញតែម្តង ព្រោះប្អូនថ្លៃរបស់ អឿន ប្អូនថ្លៃរបស់ ពក។

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្តល់ជូនសាក្សីនូវបញ្ជី ស-២១ មួយទៀត គឺឯកសារ E3/2957 និង<E3/2166។> ឯកសារទាំង<ពីរ>នេះគឺជាឯកសារមកពីមន្ទីរ ស-២១ ដែល<ជាបញ្ជីឈ្មោះអ្នកទោសមកពីភូមិភាគកណ្តាល ដែលរួម>មានមនុស្សមួយចំនួន ដែលក្នុងនោះមានឈ្មោះ<មនុស្ស>ដែលខ្ញុំចង់ឲ្យគាត់សាក្សីរូបនេះ គាត់កំណត់អត្តសញ្ញាណលោកប្រធាន។

[១០:០៦:១២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី សូមមើលនៅឯកសារ E3/2166 គឺលេខរៀងទី៧ គឺកម្មាភិបាលភូមិភាគកណ្តាល ប្រធានពាណិជ្ជកម្មភូមិភាគ ផេង ស៊ន់ ហៅ <ដៃ> ដែលត្រូវបានចាប់នៅថ្ងៃទី០៣ ខែតុលា ឆ្នាំ១៩៧៧។ តើឈ្មោះហ្នឹងមែនទេ ដែលលោកនិយាយអម្បាញ់មិញថាជាប្រធានពាណិជ្ជកម្មភូមិភាគនោះ?

**លោក បាន សៀក៖**

**ឆ៖** ខ្ញុំអត់ស្គាល់ត្រកូលទេ ប៉ុន្តែថា ជ័យ ហ្នឹងជាប្អូនថ្លៃរបស់ កែ ពក ហើយជាប្រធានពាណិជ្ជកម្មភូមិភាគ ដែលចាប់យកទៅភ្នំពេញនោះ ហើយជាប្អូនថ្លៃរបស់ អឿន ដែរ។

**ស៖** <ដើម្បីបញ្ជាក់ពីពេលវេលានៅពេលនោះដល់អង្គជំនុំជម្រះ> ខ្ញុំចង់ដឹងថា តើលោក<ធ្វើជា>ប្រធានពាណិជ្ជកម្មតំបន់៤២ហ្នឹងរយៈពេលប៉ុន្មានដែរ មុនពេលដែល <ដៃ> ត្រូវបានគេចាប់ខ្លួនហ្នឹង?

**ឆ៖** ខ្ញុំកាលទៅធ្វើពាណិជ្ជកម្មដូចបានតែ១ខែហ្នឹង ស្រាប់តែថា ជ័យ ហ្នឹងជាខ្សែ សេ.អ៊ី.អា គេចាប់យកទៅភ្នំពេញបាត់ទៅ។ ប្រហែលទេ ប្រហែល១ខែ ទៅជួបគាត់តែម្តង ពេលមកវិញ ស្រាប់គេថាចាប់បាត់ហើយ។

**ស៖** <តើ>លោកចាំទេថា <បន្ទាប់ពី>ពេលដែលគេចាប់ខ្លួន <ដៃ> ហើយហ្នឹង លោកនៅបន្តធ្វើជាប្រធានមន្ទីរពាណិជ្ជកម្មតំបន់ហ្នឹងរហូតទៅដល់ពេលណាទេ?

**ឆ៖** បាទខ្ញុំធ្វើរយៈពេលប្រហែលជា៣ខែ អឿន ដកខ្ញុំមកធ្វើអនុស្រុកចំការលើ។

[១០:០៨:៥៨]

**ស៖** យើងបាននិយាយអំពីពេលដែលលោកធ្វើការ<ខាងផ្នែក>សាធារណការ<តំបន់ ហើយបន្ទាប់មកធ្វើខាង>ពាណិជ្ជកម្ម<តំបន់> តើលោកមានដឹងថាគេសាងសង់ទំនប់នៅបារាយណ៍ ស្រុកសន្ទុក ដែលគេហៅថាទំនប់១មករាទេ?

**ឆ៖** ខ្ញុំបានដឹង ប៉ុន្តែខ្ញុំមិនបានទៅធ្វើទេ គ្រាន់តែដឹងថាព្រោះថ្នល់តាមហ្នឹងឯង ទំនប់១មករា វាថ្នល់លេខ២១ យើងជិះម៉ូតូតាមហ្នឹងទៅ ឃើញទំនប់១មករា។

**ស៖** ខ្ញុំយល់ ថាលោកមិនធ្វើការនៅទីនៅហ្នឹងទេ តែខ្ញុំចង់ដឹងថា តើលោកធ្លាប់ទៅមើលការដ្ឋានសាងសង់ទំនប់១មករាហ្នឹងទេ?

**ឆ៖** បាទ អត់ដែលទេលោក។

**ស៖** តើលោកដឹងអំពីវត្តមួយ<នៅស្រុកបារាយណ៍>ដែលឈ្មោះថា វត្តបារាយណ៍ជាន់ដែក ដែលស្ថិតនៅជិតនឹងទំនប់១មករាហ្នឹងទេ?

**ឆ៖** វត្តហ្នឹងពីដើម ខ្ញុំក្មេង ខ្ញុំធ្លាប់ស្គាល់ ប៉ុន្តែដល់ក្រោយមក ខ្ញុំមិនដែលឃើញទេបាទ។

**ស៖** លោកដឹងថា នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ តើគេយកវត្តហ្នឹងទៅធ្វើជាកន្លែងអីទេ?

**ឆ៖** បាទ អត់ដឹងទេលោក។ អត់ដឹងទេ។

[១០:១០:៤៧]

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកជូនការិយាល័យសហចៅក្រមស៊ើបអង្កេត លោក<សាក្សី> គឺខ្ញុំនឹងអានសម្រង់មួយចេញពីឯកសារ <E3/375>, ERN ជាភាសាអង់គ្លេសគឺ 00360761 ខ្មែរគឺ 00348802, បារាំងគឺ00369924។ លោកបានឆ្លើយដូចតទៅ ខ្ញុំសូមដកស្រង់៖ "សួរ៖ តើលោកស្គាល់មន្ទីរសន្តិសុខនៅវត្តបារាយណ៍ជាន់ដែកដែរឬទេ? ឆ្លើយ៖ ប្រសិនជាលោកចង់ដឹងច្បាស់ គឺទៅសួរ បងប៉ូច ជាអ្នកទទួលខុសត្រូវនៅស្រុកបារាយណ៍។ នៅក្នុងមួយខែយ៉ាងហោចណាស់ក៏គាត់ទៅមើលម្តងដែរ។ ប្រសិនបើគាត់មិនបានទៅទេ ក៏គាត់បញ្ជូនដៃជើងរបស់គាត់ទៅមើល <ជំនួស>ដែរ។ ម្យ៉ាងវិញទៀត គាត់មិនអាចឆ្លើយថា គាត់មិនបានដឹងនោះទេ។ ក្នុងស្រុកមួយត្រូវមានសមាជិកយ៉ាងតិចបួន ឬប្រាំនាក់ ហើយត្រូវមាននារីម្នាក់<។> នៅពេលដែលមានការចាប់មនុស្សស្រុកតែងដឹងអំពីរឿងចាប់ខ្លួនមនុស្សនេះ។" សូមបញ្ចប់ការដកស្រង់។ ហើយលោកបានបន្ថែមផងដែរនៅក្នុង<បទសម្ភាសបន្ទាប់ គឺ>ឯកសារ E319/19.3.86 នៅចម្លើយទី៣៤ ខ្ញុំសូមកដកស្រង់៖ "ក្នុងនាមជាលេខាស្រុក គាត់ត្រូវតែដឹង<អំពី>មន្ទីរសន្តិសុខនៅក្នុងស្រុករបស់គាត់។" តើលោកអាចជម្រាបបានទេថា <តើ>លោកដឹងអំពីការទទួលខុសត្រូវរបស់ឈ្មោះ ប៉ូច នៅក្នុងមន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែកនុំង<ដោយរបៀបណា>?

**ឆ៖** បាទ បងប៉ូច គាត់ជាមកពីនិរតី ហើយគាត់មកទទួលយូរដែរហើយ នៅកាលពីអស់ភូមិភាគកណ្តាល គាត់មកទទួល។ ដូច្នេះគាត់អាចដឹងអំពីកម្មាភិបាលដែលត្រូវចាប់ត្រូវអីហ្នឹង អាចដឹងខ្លះៗដែរ ឬក៏គាត់បានស្គាល់កន្លែងដែរ។

**ស៖** តើនៅក្នុងឆ្នាំណាដែល ប៉ូច ឡើងក្លាយទៅជាលេខាស្រុកបារាយណ៍?

[១០:១៣:៣០]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនជំទាស់ទៅនឹងសំណួរជាក់លាក់នេះទេ ក៏ប៉ុន្តែខ្ញុំចង់<ធ្វើការកត់សម្គាល់>ថា យើងកំពុងតែស្ថិតនៅពាក់កណ្តាលវគ្គ <នៃការប្រព្រឹត្តទៅលើជនជាតិ>ចាម។ ដូច្នេះខ្ញុំ<មិនច្បាស់>ថា <តើ>វត្តមួយនេះ<មានជាប់>ពាក់ព័ន្ធទៅនឹងអ្វីដែលបានរៀបរាប់នៅក្នុងដីកា

ដំណោះស្រាយ ពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះជនជាតិចាម<ដែរឬ>ទេ។ សំណួរភាគច្រើនហ្នឹង គឺព្យាយាមចង់បង្ហាញឲ្យឃើញថាតើរចនាសម្ព័ន្ធតំបន់៤២<ហ្នឹង>យ៉ាងម៉េច។ <គួរឲ្យចាប់អារម្មណ៍ដែរប៉ុន្តែ>ខ្ញុំគិតថា ដូចជាអត់មានពាក់ព័ន្ធអីនឹងការប្រព្រឹត្តចំពោះជនជាតិចាមសោះ<>។

**លោក ឌេល លីសាក់៖**

លោកប្រធាន យើងត្រូវបានអនុញ្ញាតឲ្យសួរ<គ្រប់សាក្សីទាំងអស់>នូវប្រធានបទនានាពាក់ព័ន្ធទៅនឹងដីកាដំណោះស្រាយ ព្រោះថាយើងមិនអាចហៅសាក្សី<ទាំង>នេះមកវិញ<បាន>ទេ។ ខ្ញុំមានប្រធានបទជាច្រើនដែលចង់សួរគាត់ ជាពិសេស គឺពាក់ព័ន្ធទៅនឹងការបោសសម្អាតកម្មាភិបាលនៅភូមិកណ្តាល ហើយខ្ញុំនឹងសួរអំពីការប្រព្រឹត្តចំពោះជនជាតិចាមនៅក្នុង<ភូមិភាគ>នោះ។ ទោះជាយ៉ាងណាក៏វត្តបារាយណ៍ជាន់ដែកហ្នឹង គឺវាមានពាក់ព័ន្ធ<ជាពិសេស>ទៅនឹង<ការចោទប្រកាន់ពាក់ព័ន្ធនឹង>ទំនប់១មករាដែរ។ ហើយសាក្សីមួយរូបដែលខ្ញុំនិយាយ ក៏វាមានពាក់ព័ន្ធទៅនឹងការស្នើសុំរបស់យើងឲ្យកោះហៅសាក្សីនោះ<ចូលតុលាការ>ដែរ។ ដូច្នេះ ខ្ញុំគិតថា<សំណួរនេះ>ពាក់ព័ន្ធទៅនឹងប្រធានបទយើង<នៅក្នុងតុលាការនេះ> លោកប្រធាន។

[១០:១៥:១៦]

**ប្រធានអង្គជំនុំ៖**

បាទ ទៅមុខទៀត។ មិនមានការជំទាស់អីទេ គ្រាន់តែកត់សម្គាល់ប៉ុណ្ណោះ។ សូមអញ្ជើញសាក្សីឆ្លើយតបនឹងសំណួរដែលគាត់សួរចុងក្រោយអម្បាញ់មិញនេះ។

**លោក បាន សៀក៖**

ភ្លេចបាត់ហើយ។

**លោក ឌុច ផារី៖**

ចាំអត់?

**លោក បាន សៀក៖**

អត់ចាំ ភ្លេច។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញារងអន្តរជាតិតាំងសំណួរចុងក្រោយរបស់លោក សួរចំពោះសាក្សីរូបនេះសាជាថ្មីម្តងទៀត។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** បាទ លោកប្រធាន ខ្ញុំសួរអម្បាញ់មិញនេះថា តើលោកចាំទេថាឆ្នាំណាដែល បងប៉ូច នេះ គាត់ឡើងជាលេខាស្រុកបារាយណ៍?

[១០:១៦:០២]

**លោក បាន សៀក៖**

**ឆ៖** បាទ ខ្ញុំអត់ចាំទេ ព្រោះខ្ញុំនៅឡូត៍នេសាទ ជាយុទ្ធជន អត់ជាដឹងខាងនិរតីមកធ្វើ។ ពីដើមគេដាក់ឈ្មោះ “ក”, “ខ” គេមិនដាក់ឈ្មោះ ប៉ូច ផងនុំង។ ដូច្នេះមិនដឹងទេ មិនដឹងជាអ្នកណាទេ អត់ដឹងទេ អត់ស្គាល់ទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ ហើយសហព្រះរាជអាជ្ញារង។ អរគុណសាក្សី ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សីដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងដប់កន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៧ នាទី ដល់ម៉ោង ១០:៣២ នាទី)*

[១០:៣២:០៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមរំឭកដល់លោកសាក្សី លោកមិនបាច់អាននូវឯកសារអស់នុំងទេ ហើយទុកមុំទៅ លើកលែងតែពេលណាដែលភាគីសហព្រះរាជអាជ្ញា ឬក៏ភាគីដទៃទៀតមានបំណងចង់

សួរបញ្ជាក់លើចំណុចណាមួយជាក់លាក់ សឹមលោកពិនិត្យហើយឆ្លើយតប។

បាទ តទៅនេះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញារងអន្តរជាតិដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសុំធ្វើការកត់សម្គាល់ដើម្បីប្រតិចារឹក។ [redacted] <>នោះ គឺថាខ្ញុំ<>មិន<បានតវ៉ាចំពោះភាព>ពាក់ព័ន្ធ<របស់សំណួរទាំងនោះ>ទេ ប៉ុន្តែខ្ញុំ<គ្រាន់តែសន្និតពីព័ត៌មានដែល>ព្រះរាជអាជ្ញាគាត់<បាន>ដឹង<ជា>មុន ឯយើងខ្ញុំគឺថាមិនបានដឹងទេ<។ ឥឡូវនេះ នៅពេលដែលយើងបានពិនិត្យ>បុគ្គលដែលយើងកំពុងតែនិយាយនេះ គឺ<បានរកឃើញ>ថាជាបុគ្គលដែលស្ថិតនៅក្នុងបញ្ជីសាក្សីរបស់សហព្រះរាជអាជ្ញាដែល [redacted] ដោយសារតែខ្ញុំមិនចេះអានជាភាសាខ្មែរ ខ្ញុំមិនដឹងថាតើមានចម្លើយអ្វីខ្លះនៅក្នុងកំណត់ហេតុស្តាប់ចម្លើយនោះទេ។ [redacted] ដោយសារតែ <បើនិយាយជាសង្ខេបទៅ គឺ>គាត់បានដឹងជាមុនអំពីកំណត់ហេតុនេះ។ យើងខ្ញុំមិនដឹងថា<ហេតុអ្វីក៏>បុគ្គលរូបនេះ<>ជាបុគ្គល<ដែល>មានសារប្រយោជន៍<សម្រាប់ព្រះរាជអាជ្ញា>នោះទេ<។ យើងអាចធ្វើការសន្និតបាន ប៉ុន្តែយើងមិនដឹងច្បាស់ទេ។> ហើយពាក់ព័ន្ធទៅនឹងការជំទាស់របស់ខ្ញុំពីមុន<របស់ខ្ញុំ>នោះ<ខ្ញុំគិត>ថា យើងនិយាយគ្នាអំពី<វគ្គមួយនៃ>ជនជាតិចាម<។ បើសិនសាក្សី>រូបនេះ<ពិតជាសំខាន់ពិតមែន គាត់អាចត្រឡប់>មក<វិញ>នៅពេលដែល<យើងនិយាយ>ពាក់ព័ន្ធទៅនឹងការបោសសម្អាតនៅភូមិភាគឧត្តរ ឬក៏ទីកន្លែងផ្សេងទៀត។ <ប៉ុន្តែ>ឥឡូវនេះការសួរ<សំណួរទៅ>សាក្សីរូបនេះ<ជាមួយនឹងព័ត៌មានដែលលោកមេធាវីបានដឹងជាមុន ហើយយើងមិនមានព័ត៌មាននោះ គឺ>មិនអាច

ទទួលយកបានទេ<។ តាមពិត នេះជាឧទាហរណ៍របស់ស្ថានភាពដែលយើងមានបញ្ហាខ្លាំង> ជាពិសេសវា[redacted]

[១០:៣៥:៥៧]

**លោក ខេល លីសាក់៖**

ខ្ញុំសូមឆ្លើយតបសង្ខេបមុននឹងបន្តសួរទៅសាក្សីរូបនេះ។ ការអះអាងនេះគឺមិនពិតទេ ខ្ញុំខ្លួនឯងក៏មិនដឹងថា មានអ្វីនៅក្នុងកំណត់ហេតុស្តាប់ចម្លើយថ្មីរបស់សាក្សីរូបនេះដែរ។ <ខ្ញុំក៏មិនបានអានឯកសារនេះដែរ។> អ្វីដែលខ្ញុំបានអាននោះគឺកិច្ចសម្ភាសន៍មុនៗរបស់សាក្សីរូបនេះ រួមទាំងចម្លើយរបស់គាត់បានឆ្លើយនៅក្នុង<ការស៊ើបអង្កេត>សំណុំរឿង០០២ ផងដែរ។ អ៊ីចឹងឯងបានទើបយើងដឹងតួនាទីរបស់គាត់នៅស្រុកបារាយណ៍<ដោយផ្អែកលើបទសម្ភាសក្នុងសំណុំរឿង០០២។ នេះជាមូលហេតុដែល>ខ្ញុំតាំងសំណួរបែបនេះ។ ការអះអាងថា ខ្ញុំ<ទទួលបានប្រយោជន៍ ឬ>បានដឹងជាមុន <ឬក៏ដឹងអ្វីដែលមេធាវីការពារក្តី មិនទទួលបាននោះ> គឺមិនត្រឹមត្រូវទេ។ ដូច្នេះ ខ្ញុំសូមតាំងសំណួរតទៅទៀតលោកប្រធាន។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកសាក្សី បន្តទៅនេះខ្ញុំសូមសួរទៅលោកអំពីដំណើរទស្សនកិច្ចរបស់ប្រតិភូចិនៗ ដែលដឹកនាំដោយ ឆឹង យឹងគួយ ដែលបានទៅកាន់តំបន់របស់លោកនៅក្នុងខែធ្នូ ១៩៧៧។ លោកចាំថាមានដំណើរទស្សនកិច្ចរបស់ប្រតិភូចិនទៅតំបន់របស់លោកទេ?

**លោក បាន សៀក៖**

**ឆ៖** បាទ ខ្ញុំបាទអត់បានដឹងទេលោក។

[១០:៣៧:២៩]

**ស៖** លោកចាំពិធីមួយដែលគេបាន ពិធីបើកសម្ពោធនៅទំនប់១មករា ខែធ្នូ ឆ្នាំ១៩៧៧។ នៅពេលដែលគេប្រារព្ធពិធីសម្ពោធបើកការដ្ឋានទំនប់១មករាហ្នឹង លោកមានវត្តមាននៅទីនោះដែរទេ?

**ឆ៖** បាទ អត់ទេលោក។

**ស៖** ឥឡូវនេះ ខ្ញុំចូលទៅអំឡុងពេលដែលលោកក្លាយទៅជាអនុលេខាស្រុកចំការលើ។ ខ្ញុំបានសួរលោកពីមុនមកហើយ សួរថាតើលោកធ្វើការជាប្រធានពាណិជ្ជកម្មនៅតំបន់ហ្នឹងរយៈពេលប៉ុន្មាន?

លោកថា ធ្វើរយៈពេល៣ខែ។ ហើយលោកក៏បានបញ្ជាក់ផងដែរ នៅពេលដែលខ្ញុំបង្ហាញកាលបរិច្ឆេទចាប់ខ្លួន<ប្រធានពាណិជ្ជកម្មភូមិភាគ>ឈ្មោះ <ដៃ ដែលលោកបាននៅទីនោះប្រហែលជាមួយខែ> នៅពេលដែល<គាត់ត្រូវបានគេ>ចាប់ខ្លួន<>នៅ<ដើម ខែតុលា> ១៩៧៧។ លោកបានឆ្លើយថា នៅចុងឆ្នាំ១៩៧៧ <>លោក<បានទៅស្រុកចំការលើ> ហើយ<បាន>ក្លាយទៅជាអនុលេខាស្រុកចំការលើ។ តើវាត្រឹមត្រូវដែរឬទេថា វាអាចនៅចុងខែវិច្ឆិកា ឬក៏ខែធ្នូ ១៩៧៧ គឺជាពេលដែលលោកក្លាយទៅជាអនុលេខាស្រុកចំការលើ ត្រឹមត្រូវដែរទេ?

**ឆ៖** បាទ ពេលនោះខ្ញុំ ឆ្នាំ១៩៧៧ ប្រហែលជាចុងឆ្នាំហើយ មកទទួលអស់លោកលេខាស្រុកចំការលើ។

**ស៖** ចុះអ្នកណាជាលេខាស្រុកចំការលើ នៅពេលដែលលោកមានតំណែងជាអនុលេខាស្រុកនោះ?

**ឆ៖** គឺបង ស៊ូ សឿន។

[១០:៣៩:៤៩]

**ស៖** លោកនិយាយហ្នឹងនិយាយសំដៅ ស៊ូ សឿន គឺថាជាប្រពន្ធរបស់ កែ ពក ហ្នឹងឬក៏មិនមែនទេ?

**ឆ៖** បាទ ហ្នឹងហើយលោក។

**ស៖** ឥឡូវ ខ្ញុំចង់សួរនូវអ្វីដែរ ស៊ូ សឿន បានឆ្លើយ<>ចំពោះមុខតុលាការនៅថ្ងៃទី០៥ មិថុនា ២០១៥<។ សម្រាប់ប្រតិចារឹក> គឺឯកសារ <E1/311.1 គឺ>ប្រតិចារឹក<តុលាការ>នៅម៉ោង <ប្រហែល> ០៩:៤២:៤០។ ផ្នែកខ្លះនៃសក្ខីកម្មរបស់គាត់ <ថ្វីបើមាន>សាក្សី<មួយចំនួនដែលបានកំណត់អត្តសញ្ញាណគាត់>ថា<>ជាលេខាស្រុក <ដែលក្នុងចំណោមសាក្សីទាំងនោះរួមមានលោកស្រីផ្ទាល់ ពេជ្រ ជឹម និងសាក្សីដទៃទៀត> ប៉ុន្តែ ស៊ូ សឿន បានបដិសេធថាគាត់មិនដែលបានធ្វើជាចៅហ្វាយស្រុកចំការលើទេ ហើយគាត់ក៏និយាយអំពីឈ្មោះលោក។ សូមដកស្រង់៖ "សួរ៖ យោងទៅតាមលោកស្រី អ្នកណាជាប្រធានស្រុកចំការលើ? ឆ្លើយ៖ តាមខ្ញុំចាំ តាបាន គឺជាប្រធាន។ ខ្ញុំចាំថាគាត់គឺជាប្រធាន យើងជិតដិតនឹងគ្នា <ហើយយើង>រស់នៅជិត<គ្នា>ដែរ។" បញ្ចប់ការដកស្រង់។

លោកសាក្សី ខ្ញុំសូមផ្តល់ឱកាសឲ្យលោក ថាតើលោកមានប្រតិកម្មយ៉ាងម៉េចដែរ <ចំពោះការលើកឡើងនេះ? តើលោក>ដឹង<ទេ>ថា ហេតុអ្វីបានជា ស៊ូ សឿន បដិសេធថា គាត់មិនមែនជា

មេស្រុកចំការលើទេ ប៉ុន្តែអះអាងថា លោកទៅវិញទេ ដែលជាលេខាស្រុកនោះ?

**ឆ៖** ខ្ញុំបាទ មិនមែនលេខាស្រុកទេ។ ខ្ញុំបាទអនុ ប៉ុន្តែបងជាលេខា។

[១០:៤២:០៥]

**ស៖** ចុះមន្ទីរស្រុកចំការលើហ្នឹងស្ថិតនៅកន្លែងណាដែរ នៅពេលដែលលោកធ្វើការនៅថ្នាក់ស្រុកហ្នឹង?

**ឆ៖** ចម្ងាយពីមន្ទីរតំបន់ប្រហែល៥០០ម៉ែត្រលោក។

**ស៖** តើមន្ទីរស្រុកនេះស្ថិតនៅ<>ក្នុងភូមិអី ឃុំអីដែរ?

**ឆ៖** ភូមិអត់ចាំ ប៉ុន្តែឃុំស្វាយទាប។

**ស៖** លោកចាំកម្មាភិបាលម្នាក់ឈ្មោះ ផាង ដែលជាលេខាស្រុកចំការលើមុន ស៊ូ សឿន នេះដែរទេ?

**ឆ៖** បាទ អត់ទេ ព្រោះខ្ញុំអត់ស្គាល់ផង។

**ស៖** ឯកសារមួយក្នុងចំណោមកំណត់ហេតុស្តាប់ចម្លើយដែលខ្ញុំបានផ្តល់ទៅលោក<នៅថ្ងៃ>នេះ លោកអាចមើលឯកសារ E3/2957 គឺជាបញ្ជីអ្នកទោសនៅ ស-២១<ដែលខ្ញុំបានប្រគល់ជូនលោក។> បញ្ជី<ទី៣មាន>ឈ្មោះ<ថា> "ភូមិភាគកណ្តាល"។ ខ្ញុំសុំចង្អុលបង្ហាញមនុស្សពីរបីនាក់នៅក្នុងបញ្ជីនេះ លេខ៦ នៅឯកសារ E3/2957 គឺកម្មាភិបាលម្នាក់ឈ្មោះ កែវ ឆន <ហៅ> វ៉ន ដែលជាប្រធានមន្ទីរសន្តិសុខស្រុកចំការលើ ត្រូវបានចាប់បញ្ជូនខ្លួនមក ស-២១ នៅថ្ងៃទី១៩ វិច្ឆិកា ៧៧។ លេខរៀង២១ គេហៅថា គេកំណត់ថា ជាសមាជិក<គណ:>ស្រុកចំការលើ <ដែល>ចូលខ្លួនមកថ្ងៃទី១៤ នៅខែវិច្ឆិកា ៧៧។ លេខ១ នៅលើបញ្ជីនេះគឺជាប្រធានមន្ទីរសន្តិសុខតំបន់៤២ឈ្មោះ មាស សុក ហៅសៅ។ ហើយក៏មានកម្មាភិបាលមកពីតំបន់៤២ មួយចំនួនទៀតផងដែរ បើមើលពីលេខ<១៣> ដល់<១៥ និង ១៨ ដល់ ២៦។> កម្មាភិបាលទាំងអស់នេះដែលមកពីតំបន់របស់លោកត្រូវបានចាប់ខ្លួនមកមន្ទីរស-២១ អាចចន្លោះពីថ្ងៃទី១៤ ទៅថ្ងៃទី១៩ ខែវិច្ឆិកា ៧៧។ លោកមានចាំការចាប់ខ្លួន ឬការបោសសម្អាតកម្មាភិបាលនៅក្នុងស្រុករបស់លោក នៅពាក់កណ្តាលឆ្នាំ១៩៧៧? ហើយតើលោកចងចាំអ្វីខ្លះដែរ អំពីការចាប់ខ្លួនកម្មាភិបាលទាំងនោះ?

[១០:៤៥:២២]

**ឆ៖** បាទ ខ្ញុំបាទទៅហ្នឹង ការបោសសម្អាតអស់ហើយ អត់មានបោសទៀតទេ។ អត់មាន

បោសទេ ខ្ញុំទៅបោសអស់ហើយ អស់ សន្តិសុខសន្តិអីអស់រលីងហើយ នៅពួកក្រោយនេះ ដូចមិនទាន់បាន១ឆ្នាំកន្លះផង យួនចូលបាត់ហើយ។ ដូច្នេះអត់ស្គាល់ទេពួកមុន។ កាលខ្ញុំមកហ្នឹង ដូចអត់ដឹងថាចាប់អ្នកណាៗទេ។

**ស៖** ដូច្នេះក្រោយពេលកម្មាភិបាលទាំងអស់នេះ<ត្រូវបានបោសសម្អាត និង>ដកចេញ <> ទើបលោកត្រូវបានតែងតាំងជាអនុលេខាស្រុក បើខ្ញុំយល់យ៉ាងដូច្នេះ តើត្រឹមត្រូវដែរឬក៏អត់ទេ?

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេ ព្រោះមកដល់ធ្វើអនុប្រធានសាធារណការ ប្រធានពាណិជ្ជកម្មហ្នឹង មកធ្វើជាអនុស្រុកហ្នឹង ការបោសសម្អាតរបស់កម្មាភិបាលហ្នឹង ខ្ញុំបាទអត់ដឹងទេ។

**ស៖** ឥឡូវនេះ យើងនិយាយអំឡុងពេលនៅចុងឆ្នាំ១៩៧៧ ពេលលោកក្លាយទៅជា<អនុ> លេខាស្រុកចំការលើ។ សំណួរ<មួយទៀតចំពោះចំណុចនេះ> តើលោកធ្លាប់ឮអ្នកណាម្នាក់ប្រាប់លោក ហេតុអ្វីបានជាកម្មាភិបាលតំបន់៤២ ត្រូវបានចាប់ខ្លួននៅក្នុងខែវិច្ឆិកា ១៩៧៧? តើលោកធ្លាប់ឮអំពីរឿងចាប់ខ្លួននេះទេ?

**ឆ៖** ខ្ញុំបាទអត់ឮទេលោក អត់ឮទេ។

**ស៖** ឥឡូវនេះ ខ្ញុំសួរសំណួរមួយចំនួនអំពីជនជាតិចាម នៅក្នុងស្រុកចំការលើ តើមានប្រជាជនចាមរស់នៅស្រុកចំការលើដែរទេ? ហើយបើមានហ្នឹង រស់នៅត្រង់ផ្នែកខាងណានៃទឹកដីស្រុកចំការលើនោះ?

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងនៅកន្លែងណាទេ ព្រោះកាលទៅធ្វើនេះ មិនបានចុះ គេចែកឃុំនៅ ខាងឃុំល្វា និងឃុំចំការអណ្តូង។ ខ្ញុំធ្វើឃុំពីរទេ ដល់នោះចែកគ្នាកម្មាភិបាលធ្វើទៅ មានឃុំខ្លះ គេឯករាជ្យ។ ព្រោះខ្ញុំទើបតែមកថ្មី មិនសូវយល់ គេឲ្យធ្វើបន្តិចៗហ្នឹង។

[១០:៤៨:១៧]

**ស៖** បើខ្ញុំយល់មិនច្រឡំទេ គឺថាលោករស់នៅស្រុកចំការលើ ចាប់តាំងពីពេលដែលលោកធ្វើជាអនុប្រធាន<សាធារណការ>តំបន់ <គឺនៅ>មន្ទីរ<សាធារណការ> និងមន្ទីរ<ពាណិជ្ជកម្ម ដែលលោកបានធ្វើការមុននឹងក្លាយជាអនុលេខាស្រុកចំការលើ> គឺថាមានទីតាំងនៅក្នុងស្រុកតែមួយទេ នៅពេលនោះ អ៊ីចឹងមែនទេ លោក?

**ឆ៖** បាទលោក ត្រឹមត្រូវ។

**លោក ឌុច ផារី៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សូមឆ្លើយម្តងទៀតអ៊ំ។

**លោក បាន សៀក៖**

**ឆ៖** បាទ លោក នៅនឹងឯង។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ហើយលោកបានឆ្លើយប្រាប់មន្ត្រីស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតថា <លោកទទួលខុសត្រូវ>ឃុំពីរ<។> លោកបញ្ជាក់ថា ឃុំល្វា និងចំការអណ្តូង។ តើនៅក្នុងឃុំទាំងពីរនេះ មានជនជាតិចាមរស់នៅទីនោះដែរទេ?

[១០:៤៩:២១]

**ឆ៖** បាទ អត់ទេ។

**ស៖** លោកបានឆ្លើយថា ក្នុងអំឡុងពេល៣<ខែ>ដែលលោកធ្វើជាប្រធានពាណិជ្ជកម្មតំបន់ លោកធ្វើការនៅកន្លែងមួយ ហៅថាស្ពឺ <ឬជយោ>។ តើលោកដឹង<ស្គាល់>ភូមិស្ពឺ <នៅ>ឃុំជយោ <ដែល>មានជនជាតិចាមរស់នៅច្រើនទេ?

**ឆ៖** បាទ អង្កាល់ខ្ញុំទៅហ្នឹង កន្លែងមន្ទីរពាណិជ្ជកម្មនៅក្នុងវត្ត ប៉ុន្តែបងប្អូនអ៊ីស្លាម ខ្ញុំអត់ដឹងទេ ព្រោះខ្ញុំអត់ចុះមូលដ្ឋានខាងហ្នឹងដែរ ខាងជយោ ខាងអី អត់បានចុះទេ អត់ដឹងទេ។

**ស៖** ឥឡូវនេះខ្ញុំសូមជួយរំឭកដល់ការចងចាំរបស់លោកបន្តិច នៅក្នុងកិច្ចសម្ភាសន៍ឆ្លើយជូនសហចៅក្រមស៊ើបអង្កេត<បានសម្ភាស>ចាម<ម្នាក់ដែលជា "ឧកញ៉ា"> មកពីភូមិស្ពឺនេះ គឺសាក្សី 2-TCW-827 ខ្ញុំមិននិយាយចំឈ្មោះគាត់ទេ គឺឯកសារ E3/5216 ERN ជាភាសាអង់គ្លេស 00225496, ខ្មែរ 00223891 និងបារាំង 00234569។ សាក្សីរូបនេះបានឆ្លើយថា៖ "មានជនជាតិចាមជាង១.១០០គ្រួសាររស់នៅភូមិស្ពឺ ទោះបីខ្មែរក្រហមបានបញ្ជូន ផ្លាស់ទីលំនៅ<ភាគច្រើននៃគ្រួសារចាមទាំងនោះហើយបញ្ជូន>ពួកគេទៅនៅឃុំផ្សេងៗ នៅក្នុងស្រុកចំការលើក្តី។" តើវាជួយរំឭកដល់ការចងចាំរបស់លោកទេ លោកសាក្សី? តើលោកនៅចាំថាមានជនជាតិចាមជាង១.០០០គ្រួសារ រស់នៅក្នុងស្រុកចំការលើទេ?

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេលោក។

**ស៖** លោកដឹងថា មានជនជាតិចាមខ្លះរស់នៅក្នុងតាមសហករណ៍នានា ក្នុងស្រុកចំការលើដែរទេ លោកដឹងដែរទេ?

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ឆ៖** ខ្ញុំមិនបានដឹងទេ ព្រោះទៅនឹងទៅខាងការដ្ឋាន ប៉ុន្តែគេមិនប្រាប់ថា ខ្ញុំនេះចាម ខ្ញុំនេះចិន ឬខ្ញុំអី គេមិនប្រាប់យើងផង ព្រោះខាងលើមិនសូវដឹងទេ។ ទាល់តែឃុំបានដឹង គេក្តាប់ប្រជាជនផ្ទាល់។

[១០:៥២:៥៧]

**ស៖** សូមអានសម្រង់ពីចម្លើយរបស់លោក គឺឯកសារ E3/5275 គឺ E3/5275, ERN ជាភាសាខ្មែរ 00282920, អង់គ្លេស 00284492, បារាំង 00339917។ លោកបានរៀបរាប់អំឡុងពេលដែលលោកធ្វើការនៅពេលលោកជួសជុល ធ្វើការជួសជុលសាងសង់ផ្លូវនៅក្នុងស្រុកចំការលើ ដែលជាផ្នែកមួយនៃមន្ទីរសាធារណៈការ។ សូមដកស្រង់៖ "នៅមន្ទីរគមនាគមន៍គ្មានពួក១៧មេសា ចាម ឬ <ខ្មែរកាត់>ចិនទេ។ អ្នកទាំងអស់នោះ នៅឯសហករណ៍ទេ។" បញ្ចប់ការដកស្រង់។ តើវាជួយរំឭកដល់ការចងចាំរបស់លោកទេ លោកសាក្សី? តើលោកដឹងថា មានជនជាតិចាមរស់នៅក្នុងសហករណ៍នានា ក្នុងស្រុកចំការលើដែរទេពេលនោះ?

**ឆ៖** ខ្ញុំបាទយល់ថាមាន ព្រោះបងប្អូនអ៊ីស្លាមអាចទៅ គេឲ្យទៅរស់នៅតាមសហករណ៍។

**ស៖** តើជនជាតិចាមរស់នៅស្រុកចំការលើ ត្រូវបានគេអនុញ្ញាតឲ្យគោរពប្រតិបត្តិសាសនាអ៊ីស្លាមរបស់ខ្លួន ស្លៀកពាក់ខោអាវទំនៀមទម្លាប់ចាម និងអនុញ្ញាតឲ្យនិយាយភាសាចាមដែរទេ?

**ឆ៖** បាទ តាមខ្ញុំដឹង គេមិនឲ្យគោរពសាសនាទេបាទ។ សូម្បីតែព្រះសង្ឃក៏គេមិនឲ្យគោរពដែរ គេផ្សឹកហើយ។

**ស៖** ចុះតើពួកគាត់អនុញ្ញាតឲ្យនិយាយភាសាចាមដែរ ឬក៏មិនអនុញ្ញាតទេ?

**ឆ៖** បាទ ខ្ញុំបានអត់បានដឹងទេ បញ្ហាហ្នឹង ព្រោះប្រសិនណាយើងបួស គឺគេបានថាមិនឲ្យបួស សូម្បីខ្មែរយើងក៏មិនឲ្យបួស ខាងបងប្អូនអ៊ីស្លាមក៏គេមិនឲ្យបួសដែរ មិនឲ្យគោរព មិនឲ្យថ្វាយអង្គំ។

[១០:៥៥:៤៧]

**ស៖** លោកសាក្សី លោកដឹងថាជនជាតិចាមប៉ុន្មានគ្រួសារនៅស្រុកចំការលើ នៅក្នុងចំណោមជាង១.០០០គ្រួសារដែលសាក្សីរូបនេះបានបញ្ជាក់នោះ? លោកដឹងថាជនជាតិចាមប្រហែលជាប៉ុន្មាននាក់រួចរស់មានជីវិតពីរបបខ្មែរក្រហម?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ ពីព្រោះ<បើសិនជា>គាត់មិនបានដឹងថាមានជនជាតិចាមជាង១.០០០គ្រួសាររស់នៅទីនោះទេ<> ដូច្នេះពិតណាស់ថា គាត់មិនអាចដឹងថា<មានជនជាតិចាមប៉ុន្មាននាក់ ឬ>ជនជាតិចាមប៉ុន្មានភាគរយក្នុងចំណោមជនជាតិចាមដែលបានលើកឡើងទាំងប៉ុន្មាននេះរស់រានមានជីវិតនោះទេ។ <វានឹងក្លាយទៅជាការឆ្លើយស្មានទាំងស្រុងទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា ដូច្នេះខ្ញុំសូមជំទាស់។>

**លោក ឌេល លីសាក់៖**

ខ្ញុំសូមបញ្ជាក់សំណួរខ្ញុំឡើងវិញ <ពីព្រោះ>ខ្ញុំមិនបានឲ្យសាក្សីឆ្លើយបញ្ជាក់តួលេខពិតប្រាកដនោះទេ។ ខ្ញុំសូមរៀបសំណួរខ្ញុំឡើងវិញលោកប្រធាន។ ខ្ញុំមិនបានសួរឲ្យគាត់ឆ្លើយជា<តួលេខ ឬ>ភាគរយទេ។

[១០:៥៧:០៣]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី អ្វីដែលខ្ញុំសួរទៅលោក គឺសួរអំពីការចងចាំរបស់លោក។ តើជនជាតិចាមដែលបានរស់នៅស្រុកចំការលើនោះ តើពួកគាត់ទាំងអស់រស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់គ្នាឬ?

**លោក បាន សៀក៖**

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេលោក។

**ស៖** ឥឡូវនេះ ខ្ញុំសូមបង្ហាញភ័ស្តុតាងដែលត្រូវបានប្រមូលដោយលោក អ៊ីសា ឧស្មាន នៅក្នុងសៀវភៅរបស់គាត់ ហៅថា <"អ៊ូគូបះ"> គឺឯកសារ E3/1822 នៅត្រង់ ERN អង់គ្លេស 0007 8568, បារាំង 00758331 មិនទាន់មានការបកប្រែជាភាសាខ្មែរនៅឡើយទេសៀវភៅនេះ។ លោក អ៊ីសា ឧស្មាន បានសរសេរថា៖ "ជនជាតិចាម១.១០០គ្រួសារ ដែលរស់នៅភូមិស្ពឺ <>នៅមុនរបបខ្មែរក្រហមហ្នឹង គឺមានតែ១០០គ្រួសារដែលបានរស់រានមានជីវិតពីរបបខ្មែរក្រហម។" ដោយសារលោកជាអនុលេខា<>ស្រុកនេះ លោករស់នៅទី<នោះជាច្រើនខែមុនហេតុការណ៍ហ្នឹង>ដែរ។ ឥឡូវខ្ញុំចង់ឲ្យលោកជម្រាបជូនតុលាការមើល ថាតើលោកមានព័ត៌មាន<អំពី>អ្វីកើតឡើងចំពោះគ្រួសារចាម១.០០០គ្រួសារ<ដែលបានបាត់ខ្លួន>នៅក្នុងស្រុកចំការលើនោះដែរឬទេ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទខ្ញុំបាទអត់ដឹងទេលោក។

**ស៖** លោកបានឆ្លើយថាតំបន់<មួយក្នុងចំណោមតំបន់ជាច្រើនទៀត>ដែលលោកទទួលខុសត្រូវគឺ<>ឃុំល្វា។ តើលោកទទួលខុសត្រូវអ្វីនៅក្នុងឃុំល្វា?

**ឆ៖** បាទ ខ្ញុំបាទទៅទទួលខុសត្រូវប្រមូលប្រជាជនទៅធ្វើប្រឡាយ ទៅធ្វើការដ្ឋាន បង្កបង្កើនផល។

[១០:៥៩:៥៦]

**ស៖** តើមានចម្ការកៅស៊ូនៅឃុំល្វាដែរទេ ហៅឈ្មោះថា ចំការតាប៉ុម?

**ឆ៖** បាទ ខ្ញុំបាទអត់ស្គាល់ទេ។

**ស៖** តើមានចម្ការកៅស៊ូនៅក្នុងតំបន់នោះទេ? គឺចម្ការកៅស៊ូ -- តើមានចម្ការកៅស៊ូស្ថិតនៅក្នុងទឹកដីឃុំល្វាដែរទេ?

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេ លោក។ បើដឹង ដឹងថាចម្ការកៅស៊ូនៅក្នុងស្រុកចំការលើ ហ្នឹងដឹង។

**ស៖** ចុះអ្នកណាទទួលខុសត្រូវ ទទួលបន្ទុកទៅលើចម្ការកៅស៊ូនោះ?

**ឆ៖** បាទ ជំនាន់ហ្នឹង គឺខ្ញុំស្គាល់ឈ្មោះ បងជីម។ គាត់ធ្វើជាប្រធានចម្ការកៅស៊ូចំការអណ្តូង។

**ស៖** ឥឡូវនេះលោកសាក្សី ខ្ញុំសូមអាននូវពាក្យបណ្តឹងមួយដែលបានដាក់ជូនតុលាការយើងនេះពាក់ព័ន្ធទៅនឹងឃុំល្វា គឺឯកសារ E3/6979a ។ ត្រង់ ERN ជាភាសាខ្មែរ 00452293។ គឺសេចក្តីសង្ខេបនៃពាក្យបណ្តឹងនេះ គឺឯកសារ E3/6979bវិញ ជាភាសាអង់គ្លេស។ នេះគឺជាពាក្យបណ្តឹង ដែលបានឆ្លើយនៅក្នុងឯកសារនេះ។ សូមដកស្រង់៖ "នៅក្នុងឆ្នាំ១៩៧៧ ក្នុងរដូវស្ទូងដក <ម្ចាស់បណ្តឹងត្រូវបានគេប្រាប់ថា> ខ្មែរក្រហមបាននាំគ្រួសារជនជាតិចាមទៅ<សម្លាប់នៅចំការកៅស៊ូតាប៉ុម> ស្រុកចំការលើ ឃុំល្វា<លើ> ក្នុងខេត្តកំពង់ចាម។" កូនស្រីរបស់<>ម្ចាស់បណ្តឹងនេះ គឺឈ្មោះថា តេ អៃសះ និងកូនប្រសាប្រុសឈ្មោះ សាន់ មីន ហើយនិងសាច់ញាតិដទៃទៀតត្រូវបានយកទៅសម្លាប់ចោលនៅចម្ការកៅស៊ូតាប៉ុម។" បញ្ចប់ការដកស្រង់។ លោកសាក្សី លោកមានដឹងថា គេនាំគ្រួសារចាមយកទៅសម្លាប់ចោលនៅក្នុងចម្ការកៅស៊ូស្ថិតនៅក្នុងទឹកដីឃុំល្វានោះដែរទេ?

[១១:០៣:០៥]

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេលោក។

**ស៖** អ៊ីចឹងឥឡូវនេះ លោកកំពុងតែជំទាស់ទៅនឹង<ចម្លើយរបស់សាក្សីនេះដែល>ថា មាន

<គ្រួសារជនជាតិចាមជាច្រើនត្រូវបាន>គេសម្លាប់<>នៅទីនោះ <តើ>លោកកំពុងតែជំទាស់ថាមិនមានអ៊ីចឹងទេឬ?

**ឆ៖** បាទ ខ្ញុំបាទអត់ជំទាស់ទេ ព្រោះនៅក្នុងស្រុកចំការលើ មិនមែនគណៈស្រុកទេអ្នកនេះនោះ ព្រោះនៅតំបន់ហើយនិងស្រុកគឺនៅជាមួយគ្នា។ ដូចថាយោធាតំបន់ក៏នៅហ្នឹង ស្រុកក៏នៅជាមួយគ្នា។ ដូច្នេះស្រុកមិនសូវដឹងទេ ការងាររបស់តំបន់ច្រើនជាង លោក។

**ស៖** ចម្ការកៅស៊ូដែលលោករៀបរាប់នេះ ដែលថា បងជឹម នេះធ្វើការនៅទីនោះ។ តើចម្ការនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្រុក ឬក៏របស់តំបន់ <ឬរបស់ភូមិភាគ>?

**ឆ៖** បាទ របស់ភូមិភាគ លោក។

**ស៖** តើមន្ទីរសន្តិសុខស្រុកចំការលើ មានទីតាំងនៅឯណាដែរ?

**ឆ៖** តាមពេលនោះ ខ្ញុំបានឮសួរគេថានៅក្នុងឃុំបុសខ្នុរ។ ប៉ុន្តែខ្ញុំបាទអត់បានទៅផង គ្រាន់ឮថាសន្តិសុខនៅហ្នឹងឯង។

[១១:០៥:១៤]

**ស៖** តើលោកមានដែលដឹងអំពីកិច្ចប្រជុំ<ដែលធ្វើឡើងនៅ បុសខ្នុរ> ជាពិសេស<កិច្ចប្រជុំដែលធ្វើនៅកន្លែងនោះ>ពាក់ព័ន្ធទៅនឹងផែនការបោសសម្អាតជនជាតិចាម លោកដឹងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី កូប៉េ!

**លោក វិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ចំពោះសំណួរនេះលោកប្រធាន ដោយសារសំណួរនេះក៏ដូចជាសំណួរមុនៗ គឺវាពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នៅក្នុងតំបន់៤២ <ក្នុងភូមិភាគឧត្តរចាស់>ដែលជាភូមិភាគកណ្តាលថ្មី។ <ដីកាដំណោះស្រាយ>រៀបរាប់ពាក់ព័ន្ធ<តែ>ទៅនឹងការចោទប្រកាន់កូនក្តីរបស់ខ្ញុំនៅក្នុងតំបន់៤១ ឬ <តំបន់២១ នៅភូមិភាគបូព៌ា។> ឥឡូវនេះគឺថា យើងកំពុងតែចេញផុតពីព្រំប្រទល់នៃដីកា<ដំណោះស្រាយ>ហើយ ដែលយើងកំពុងតែនិយាយគ្នាអំពី<ការប្រព្រឹត្តលើ>ជនជាតិចាមនេះ។ <>ដូច្នេះ យើងខ្ញុំសូមជំទាស់ <ពីព្រោះសំណួរទាំងនេះ>ងាកចេញអំពីវិសាលភាព<នៃដីកាដំណោះស្រាយ និងដែនកំណត់នៃសវនាការនេះ>។

**លោក ឌេល លីសាក់៖**

ខ្ញុំសូមឆ្លើយតប <នេះគឺជាការជំទាស់ដែលយើងបានជួបប្រទះជាច្រើនដងនៅក្នុងតុលាការនេះ។> បន្ថែមទៅលើមូលដ្ឋានឧក្រិដ្ឋកម្ម <ដែលលោកមេធាវី កូប៉េ បានលើកឡើងនោះ គឺជា>គោលនយោបាយ និងផែនការកម្ទេចជនជាតិចាម។ វាគឺ<ជាភស្តុតាងដ៏សំខាន់ និង> ជាផ្នែកមួយដ៏សំខាន់នៅក្នុងកិច្ចដំណើរការនីតិវិធីនាពេលនេះ។ <ភស្តុតាងដែលខ្ញុំរៀបនឹងសួរសាក្សីនេះ គឺពាក់ព័ន្ធនឹងបញ្ហាថាតើគេ>មានផែនការកម្ទេចជនជាតិចោលដែរឬក៏អត់ទេ<។ ខ្ញុំសូមបញ្ជាក់ថា នេះក៏ជាភស្តុតាងដែលបានពីបុគ្គលដែលត្រូវបានជ្រើសរើសដោយតុលាការនេះដើម្បីធ្វើជាសាក្សី គឺ>2-TCW-827<។ ដូច្នេះភស្តុតាងនេះជាផ្នែកមួយដ៏សំខាន់នៅក្នុងកិច្ចដំណើរការនីតិវិធីនេះ>។

[១១:០៧:២៥]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយខ្លីទេ។ <នេះជា>បញ្ហា<ដូចគ្នាទេដែលយើង>បានលើកឡើងពីមុនមកហើយ ពាក់ព័ន្ធទៅនឹងមន្ទីរសន្តិសុខដែលវានៅខាងក្រៅដីកា<ដំណោះស្រាយ អំពី>ការប្រព្រឹត្តមកលើមន្ត្រីរបបសាធារណរដ្ឋខ្មែរ គឺថាអង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរហើយ។ <ជាក់ស្ដែង នេះគឺជាបញ្ហាគោលការណ៍> ដូច្នេះ បើសិនណាជា<អង្គជំនុំជម្រះបដិសេធចោលសេចក្ដី>ជំទាស់របស់ខ្ញុំទៀត <ខ្ញុំ>សូមឲ្យអង្គជំនុំជម្រះចេញសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរតែម្ដង <ថាព្រឹត្តការណ៍ទាំងអស់ ដែលនៅ>ខាងក្រៅវង្វង់ទឹកដីនៃតំបន់៤១ <និងតំបន់២១ នៅភូមិភាគបូព៌ា ក៏ជាផ្នែកនៃបទ>ឧក្រិដ្ឋកម្មដែលយើងកំពុងតែពិភាក្សាដេញដោលគ្នានេះ<ផងដែរ>។

**លោក ឌេល លីសាក់៖**

យើងខ្ញុំមិនចង់ចំណាយពេលទេ។ យើងមិននិយាយថានេះគឺជាទីតាំងឧក្រិដ្ឋកម្មទេ <គឺ>និយាយអំពីភ័ស្តុតាងពាក់ព័ន្ធតែទៅនឹងគោលនយោបាយប៉ុណ្ណោះ។

[១១:០៨:៣៦]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:០៩:៣៩]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ក្លូឌា ហ្វេនស៍ ដើម្បីចេញសេចក្ដី

សម្រេចក្នុងនាមអង្គជំនុំជម្រះទៅលើសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក នួន ជា គឺលោកមេធាវី វ៉ិចទ័រ កូប៉េ ចំពោះសំណួរចុងក្រោយដែលសួរឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិអម្បាញ់មិញនេះ។ បាទ សូមអញ្ជើញលោកស្រី ក្លូឌា ហ្វេនស៍!

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ការជំទាស់គឺត្រូវបានបដិសេធ។ សំណួរមិនពាក់ព័ន្ធទៅនឹងទីតាំងឧក្រិដ្ឋកម្មទេ ប៉ុន្តែវាពាក់ព័ន្ធទៅនឹងគោលនយោបាយ <ដែលត្រូវបានអនុវត្តទូទាំងប្រទេស>។ ដូច្នេះ យើងយល់ឃើញថា <ភាគីទាំងពីរបានដឹងហើយ គឺថាយើងមានបញ្ហាដដែល>ដូចមុនៗអ៊ីចឹងដែរ។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី លោកទើបតែបានឆ្លើយថាមន្ទីរសន្តិសុខស្រុកស្ថិតនៅកន្លែងមួយ គេហៅថា បុសខ្នុរ។ តើលោកដឹងថា មានកិច្ចប្រជុំគេធ្វើឡើងនៅបុសខ្នុរ ពាក់ព័ន្ធទៅនឹងផែនការបោសសម្អាតជនជាតិចាមដែរទេ?

**លោក បាន សៀក៖**

**ឆ៖** បាទ ខ្ញុំបាទអត់បានដឹងទេលោក។

[១១:១១:០៥]

**ស៖** ឥឡូវនេះ ខ្ញុំសូមអានភ័ស្តុតាងដែលបានផ្តល់ជូនតុលាការ គឺ<បានមកពីចាមដដែល "ឧកញ៉ា" មកពី>ភូមិស្ពឺ ដែលខ្ញុំបាននិយាយខាងដើម គឺឯកសារ E3/7690។ ខ្ញុំមិននិយាយឈ្មោះទេ គឺសាក្សីហ្នឹង មានរហស្សនាម 2-TCW-827។ ឯកសារនេះគឺបានរៀបរាប់អំពីរឿងរ៉ាវមួយចំនួនដោយសាក្សីរូបនេះដូចតទៅ សូមដកស្រង់៖ "ខ្មែរក្រហមមិនដឹងថាគាត់ជាចាមទេ ដូច្នេះគេបានចាត់តាំងឲ្យគាត់ឲ្យមើលខុសត្រូវកុមារៗ ៤០០នាក់នៅឃុំជយោ ស្រុកចំការលើ ខេត្តកំពង់ចាម។ ថ្ងៃមួយ ក្នុងឆ្នាំ ១៩៧៧ គាត់ត្រូវបានហៅឲ្យទៅប្រជុំចូលរួមកិច្ចប្រជុំមួយនៅភូមិបុសខ្នុរក្នុងស្រុកចំការលើ។ របៀបវារៈនៃកិច្ចប្រជុំនេះ គឺបញ្ជាក់ឲ្យបានច្បាស់លាស់អំពីផែនការមួយហៅថា ផែនការកម្ទេចខ្មាំង។ គាត់បានរាយការណ៍នៅក្នុងកិច្ចប្រជុំនេះ គាត់ឮប្រធានអង្គប្រជុំប្រកាស សូមដកស្រង់៖ ខ្មាំងរបស់បដិវត្តន៍មានច្រើនណាស់ ប៉ុន្តែខ្មាំងធំជាងបំផុតនោះ គឺពួកចាមនេះហើយ។ ដូច្នេះ ផែនការហ្នឹងគឺត្រូវបានអំពាវ

នាវឲ្យកម្ទេចជនជាតិចាមហ្នឹងចោលទាំងអស់នៅមុនឆ្នាំ១៩៨០។" បញ្ចប់ការដកស្រង់។ ក្រោយពីឮភ័ស្តុតាងនេះ លោកសាក្សី តើលោកធ្លាប់ឮប្រជាជននិយាយអំពីកិច្ចប្រជុំមួយនេះ ដែលប្រារព្ធធ្វើឡើងនៅបុសខ្នុរនោះដែរទេ?

**ឆ៖** បាទ ខ្ញុំបាទ អត់ដឹងទេលោក។

**ស៖** តើលោកមានចម្លើយ ឬការឆ្លើយតបទៅនឹងសាក្សី ឧកញ៉ានេះឆ្លើយទេ ទាក់ទងទៅនឹងផែនការកម្ទេចជនជាតិចាមចោលនោះ?

**ឆ៖** ខ្ញុំមិនបានដឹងទេ ក៏ប៉ុន្តែប្រសិនណាខ្ញុំដឹងថា បងប្អូនខ្មែរ និងបងប្អូនអ៊ីស្លាម ក្នុងពេលនោះដូចតែគ្នា សូម្បីតែបងប្អូនខ្ញុំបង្កើតដល់ទៅពីរនាក់ក៏គេកម្ទេចដែរ។ ដូច្នេះឲ្យតែខ្មាំង ខ្មាំង សេ.អ៊ី.អា និងខ្មាំង កា.ហ្សេ.បេ. គឺកម្ទេចទាំងអស់។ អត់ឮថាគេនេះចាម នេះចិន នេះខ្មែរ ខ្មែរយើងក៏អស់ច្រើនដែរ មិនមែនអស់តែបងប្អូនអ៊ីស្លាមទេបាទ។

[១១:១៤:០៥]

[redacted]

**លោក ឌេល លីសាក់៖**

[redacted]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។

**លោក វ៉ិចទ័រ កូប៉េ៖**

<លោកប្រធាន។>

**ប្រធានអង្គជំនុំ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អញ្ជើញ!

[១១:១៥:៤៣]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំជំទាស់ទៅនឹងសំណួរនេះ ហើយនិងការបង្ហាញឯកសារ<នេះ>ជូនសាក្សី<>។ [redacted] យើងបានទទួលពេលវេលា<>មួយសប្តាហ៍ ដើម្បីអានឯកសារទាំងអស់នេះ។ ជាពិសេស ឯកសារដែលកំពុងតែ<បង្ហាញ>នេះ <ហើយមាន>ឯកសារមួយ<ទៀតដែលយើងត្រូវប្រើ ដូចដែលអង្គជំនុំជម្រះដឹងស្រាប់ហើយ វានៅជា>ភាសាខ្មែរនៅឡើយ។ ឥឡូវនេះ <ដូចដែល>យើង<ខ្ញុំបាន>និយាយ <យើងកំពុងតែធ្វើការជាមួយលំហូរ>យ៉ាងគំហុកនៃ<កំណត់ហេតុស្តាប់ចម្លើយ>ចេញពីសំណុំរឿង០០៤។ ដូច្នេះ យើងខ្ញុំស្នើសុំឱ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីពាក់ព័ន្ធទៅនឹងជនជាតិចាមនេះ ទាំងស្រុង<>។ ជាពិសេសពាក់ព័ន្ធទៅនឹងតំបន់៤១។ <យើងកំពុងតែបន្តទៅមុខហើយឥឡូវនេះ ធ្វើដូច>យើងខ្ញុំមិនដែលស្នើសុំបែបនេះ<អ៊ីចឹង>។ <ខ្ញុំមិនដឹងថាតើអង្គជំនុំជម្រះបានសម្រេចទៅសំណើសុំដំបូងរបស់យើង គឺ>សុំឱ្យផ្អាកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធទៅនឹងផ្នែកនៃសវនាការពាក់ព័ន្ធនឹងជនជាតិចាមនេះ <បើសិនណាជា>សំណុំរឿង០០៤<នៅតែបន្តនោះ>។ <ឥឡូវនេះ យើងមានឧទាហរណ៍ល្អមួយពីអ្វីដែលយើងកំពុងតែដំណើរការនេះ។> យើង<ខ្ញុំយល់ស្រប>ថា <ឯកសារនេះគឺជា>កំណត់ហេតុស្តាប់ចម្លើយ<ដ៏សំខាន់ ប៉ុន្តែវាចេញពីការ>ស៊ើបអង្កេត<ដែលកំពុងតែធ្វើនៅពេល>នេះ<>។ ហើយយើងខ្ញុំ<គិត>ថា អង្គជំនុំជម្រះមិនទាន់បានចេញសេចក្តីសម្រេច<ចំពោះសំណើរបស់ខ្ញុំដើម្បីសុំ>ផ្អាកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធទៅនឹង<ព្រឹត្តការណ៍ផ្សេងៗដែលទាក់ទងនឹង>ជនជាតិចាមនៅក្នុងតំបន់៤១ <ឬតំបន់៤២>នៅឡើយទេ។ <តាម>ការកត់សម្គាល់<របស់ខ្ញុំ> យើងខ្ញុំក៏ស្នើសុំ<ម្តងទៀត>ឱ្យសហព្រះរាជអាជ្ញាផ្អាក<>ការសួរពាក់ព័ន្ធទៅនឹង<ទីតាំងដែលបច្ចុប្បន្នកំពុងស្ថិតនៅក្រោមការស៊ើបអង្កេតនៅក្នុង>សំណុំរឿង០០៤សិន។

[១១:១៧:៥៥]

**លោក ឌេល លីសាក់៖**

យើងខ្ញុំមិនចង់ចូលទៅពាក់ព័ន្ធទៅនឹងបញ្ហាដែលបានជំទាស់នៅចំពោះមុខអង្គជំនុំជម្រះរួចហើយ

<នោះទេ>។មេធាវីការពារក្ដីបាន<ធ្វើការជំទាស់ចំពោះបញ្ហានេះ។>ហើយ<អង្គជំនុំជម្រះបានសម្រេចដោយ>អនុញ្ញាតឱ្យខ្ញុំបន្តសួរសាក្សីរូបនេះ<ទៀត។> សេចក្ដីសម្រេចនេះក៏បានប្រកាសកាលពីសប្ដាហ៍មុនហើយ។ <>មេធាវីការពារក្ដីបានប្រើប្រាស់ឱកាសរបស់ខ្លួនជាច្រើន<នៃការសម្ភាសសួរដេញដោល>នៅក្នុងកិច្ចដំណើរការនីតិវិធីនេះ។ <ហើយនេះជាសាក្សីដែលយើងបានកំណត់អត្តសញ្ញាណ>នៅក្នុងបញ្ជី<ដើមរបស់>សាក្សី<ក្នុងសវនាការ>នៅក្នុងខែមិថុនា ឆ្នាំ២០១៤ <គឺថាជា>សាក្សីម្នាក់ដែលឯកសារ<ជាច្រើន>របស់គាត់នោះ<>ត្រូវបានអង្គជំនុំជម្រះទទួលយកប៉ុន្មានខែមុននេះ។ ដូច្នេះ នេះជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះដែលអង្គជំនុំជម្រះ <ហើយដែលយើងខ្ញុំមានសិទ្ធិក្នុងការប្រើប្រាស់ក្នុងតុលាការនេះ។ សូម>អនុញ្ញាតឱ្យខ្ញុំសួរពាក់ព័ន្ធទៅនឹងឯកសារនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

<តាមពិតទៅ-->

**ប្រធានអង្គជំនុំ៖**

ទុកបន្តិចសិន វ៉ិចទ័រ កូប៉េ! ចាំស្ដាប់ភាគីដទៃទៀត ពាក់ព័ន្ធផង។ សូមអញ្ជើញ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងសំណើសុំផ្អាកសវនាការលើអង្គហេតុជនជាតិចាម ដោយមូលហេតុនៃការជំនន់ឯកសារដែលហូរចូលពីសំណុំរឿង០០៣, ០០៤ ដាក់បង្ហាញដោយសហព្រះរាជអាជ្ញាមកក្នុងសំណុំរឿង០០២នេះ។ តើយ៉ាងម៉េចដែរ ដើម្បីកុំឱ្យបញ្ហានេះ វាកើតឡើងដដែលៗ?

បើមិនមានបញ្ហាអីទេ សូមអញ្ជើញលោក វ៉ិចទ័រ កូប៉េ!

[១១:១៩:៤១]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនិយាយដោយខ្លីទេ គ្រាន់តែយើងចង់ប្រាប់ថា យើងគ្មានគោលជំហរអ្វីនោះទេ ពាក់ព័ន្ធនឹងសំណើរបស់ក្រុម នួន ជា នេះ ហើយ<យើងសូមធ្វើទៅតាមអ្វីដែលយើងបានធ្វើ គឺ>យើងអាស្រ័យទៅលើការសម្រេចរបស់អង្គជំនុំជម្រះតែប៉ុណ្ណោះ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ក្រុមមេធាវីការពារក្ដីលោក ខៀវ សំផន យ៉ាងម៉េចដែរ?

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ក្រុមមេធាវីលោក ខៀវ សំផន យោងទៅនឹងសារណារបស់ខ្លួន គឺ

ឯកសារ <E363 បើខ្ញុំចាំមិនច្រឡំទេ ចំពោះការបង្ហាញឲ្យឃើញនូវឯកសារមួយចំនួនមកពីសំណុំរឿង ០០៣ និង០០៤> ដែលយើងបានសុំ<ជាច្រើនដង>ឲ្យអង្គជំនុំជម្រះចេញវិធីសាស្ត្រក្នុងការជំនុំជម្រះមួយ។ <យើងផ្អែកទៅលើសារណារបស់យើង។ ប៉ុន្តែយើងមិនបានទទួលការឆ្លើយតប ដែលវាពាក់ព័ន្ធនឹង>គោលជំហររបស់យើងទេ<>។

**លោក វ៉ិចទ័រ កូប៉េ៖**

ចំណុចមួយដែលយើងខ្ញុំសូមឆ្លើយតបឲ្យច្បាស់លាស់ទៅនឹងតំណាងសហព្រះរាជអាជ្ញា យើងខ្ញុំ <ពិតបានកត់ចំណាំ>ថា ការជំទាស់របស់<យើង>ពាក់ព័ន្ធទៅនឹងការប្រើប្រាស់កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីរូបនេះ គឺថាត្រូវបានបដិសេធហើយ<។> ប៉ុន្តែ<គួរចាប់អារម្មណ៍ថា> សេចក្តីសម្រេចរបស់អង្គជំនុំជម្រះ<ដែលនឹងត្រូវចេញមកនោះ ត្រូវការពេល២ថ្ងៃមុននឹង>ការបកប្រែជាភាសាខ្មែរ<រួចរាល់>។ យើងខ្ញុំក៏<មានសេចក្តីសំអាង>យ៉ាងជាក់លាក់<ដោយផ្អែក>ទៅលើច្បាប់<ជាតិ>កម្ពុជា<។> ប៉ុន្តែយើងខ្ញុំនៅតែឆ្ងល់ថា តើចៅក្រមជាតិសម្រេចថាដូចម្តេចដែរ ចំពោះ<សំណើនេះដោយ>មិនទាន់បានអាននូវ<សារណា>របស់យើងខ្ញុំពាក់ព័ន្ធទៅនឹងបញ្ហា<ជាក់លាក់នេះ។>

[១១:២១:៤៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២៦:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមជម្រាបជូនទៅលោកមេធាវី វ៉ិចទ័រ កូប៉េ ហើយនិងភាគីដទៃទៀតពាក់ព័ន្ធនឹងបញ្ហានេះថា សំណើដែលពាក់ព័ន្ធនឹងបញ្ហានេះ អង្គជំនុំជម្រះបានជម្រាបជូនរួចហើយថា វាស្ថិតនៅដំណាក់កាលកំពុងតែធ្វើការរៀបចំ។ ហើយជាពិសេសហ្នឹង គឺរៀបចំទៅនឹងភាសាផ្សេងៗទៀតដែលអង្គជំនុំជម្រះនឹងចេញឆាប់ៗនេះ លើបញ្ហាពាក់ព័ន្ធនឹងបញ្ហានេះដែលលោកបានលើកឡើងអម្បាញ់មិញនេះ។ អង្គជំនុំជម្រះមិនបានព្រងើយកន្តើយនៅក្នុងកិច្ចការងារនេះទេ។ ហើយអង្គជំនុំជម្រះរង់ចាំការរៀបចំរួចស្រួលបួល គឺអង្គជំនុំជម្រះនឹងជាលាយលក្ខណ៍អក្សរប្រកាសផ្សព្វផ្សាយជម្រាបជូនភាគីឲ្យបានជ្រាបលើបញ្ហានោះ។ ហើយបច្ចុប្បន្នេះកំពុងស្ថិតនៅកាលដំណាក់កាលចុងក្រោយនៅពេលវេលានៃការអាចនឹងលទ្ធភាពចេញនៃសេចក្តីសម្រេច ពាក់ព័ន្ធនឹងបញ្ហាដែលលោកមេធាវី វ៉ិចទ័រ កូប៉េ បានលើកនោះហើយ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហើយបញ្ហាមួយទៀត គឺយើងបានជម្រាបជូនហើយថា បញ្ហាប្រឈមគឺកើតឡើងមានដូចគ្នាពិតមែនតែអង្គជំនុំជម្រះមិនបានលើកបញ្ជាក់ជូនឲ្យបានច្បាស់លាស់លើកបញ្ហានេះ ដោយកត់សម្គាល់លើភាពស្ថានភាពភាគីដទៃទៀតដែលពាក់ព័ន្ធលើបញ្ហាអាននូវឯកសារផ្សេងៗ ដែលភាគីសហព្រះរាជអាជ្ញាដាក់បង្ហាញមកពីសំណុំរឿង០០៣, ០០៤នោះ គឺបញ្ហាប្រឈមដូចគ្នា។ ហើយបញ្ហានេះអង្គជំនុំជម្រះបានជម្រាបជូនហើយ ស្ថិតនៅក្នុងការពិភាក្សាដ៏តឹងតែង ដើម្បីដោះស្រាយលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ដែលពាក់ព័ន្ធនឹងបញ្ហានេះ។ ហើយអង្គជំនុំជម្រះបានជម្រាបពិភាក្សាឯកភាពគ្នា ស្រុះស្រួលគ្នាលើបញ្ហាមួយចំនួនហើយ។ នៅមួយចំនួនទៀតនោះគឺមានស្ថានភាពស្មុគស្មាញដែលគប្បីធ្វើការប្រធៀបផ្ទៀងផ្ទាត់បញ្ហាហ្នឹងឲ្យបានច្បាស់លាស់ ជាក់លាក់ មុននឹងចេញឆ្លើយតបទៅនឹងសំណើសុំរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន លើបញ្ហានេះ វានឹងគ្របដណ្តប់លើបញ្ហាទាំងអស់ផ្សេងទៀត ដែលយើងអាចបើកទូលាយ និងសម្រួលដល់កិច្ចដំណើរការសវនាការរបស់យើងគឺអាចទៅមុខបានហើយ។ ហើយបញ្ហានេះ ដោយសារវាស្ថិតនៅក្នុងស្ថានភាពនេះ អង្គជំនុំជម្រះសម្រេចបដិសេធលើសំណើសុំរបស់ក្រុមមេធាវីការពារក្តី នួន ជា ដែលបានលើកឡើងសុំឲ្យអង្គជំនុំជម្រះផ្អាកកិច្ចដំណើរការសវនាការចាប់ពីពេលនេះតទៅ ចំពោះអង្គហេតុចាមនោះ។ ហើយអង្គជំនុំជម្រះសម្រេចថា បន្តធ្វើសវនាការលើបញ្ហាអង្គហេតុនេះតទៅទៀត ជាពិសេសលើសាក្សីដែលអង្គជំនុំជម្រះបានកំណត់មកផ្តល់សក្ខីកម្ម ដែលបានកំណត់កាលវិភាគជម្រាបជូនទៅភាគីរួចហើយ។

អញ្ជើញបន្តការតាំងសំណួរលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ។

[១១:២៩:៣៣]

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអរគុណលោកប្រធាន។ លោកសាក្សី ចម្លើយនេះដែលខ្ញុំបានផ្តល់ទៅលោកនេះ សូមលោកកុំនិយាយឈ្មោះសាក្សីនេះឲ្យគេឮ គ្រាន់តែមើល<ឈ្មោះ និងប្រវត្តិរូប>ទៅលើទំព័រទី២ <តើលោកស្គាល់>គាត់<ទេ?> តើគាត់គឺជាមនុស្សដែលលោកធ្លាប់បានស្គាល់កាលពីរបបខ្មែរក្រហមដែរឬអត់<? ខ្ញុំយោងទៅលើ>ឯកសារ E319/15.3.1<ម្តងទៀត។>

**លោក បាន សៀក៖**

**ឆ៖** បាទ ខ្ញុំបាទអត់បានស្គាល់ទេលោក។

**ស៖** [redacted]

[redacted]

[១១:៣២:៥៥]

**លោក វ៉ិចទ័រ កូប៉េះ**

លោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹងការតាំងសំណួរនេះ គឺថាមិនគួរតាំងសំណួរបែបនេះទេ។ គាត់សួរអំពី តាអាន <ដោយ>មុនដំបូងអានសម្រង់ជាច្រើនចេញពីកំណត់ហេតុស្តាប់ចម្លើយ<របស់សាក្សីរូបនេះ។> ឥឡូវនេះ <ភស្តុតាងនេះត្រូវបានយកមកនិយាយនៅក្នុងតុលាការ គឺថា>សហព្រះរាជអាជ្ញា<ទទួលបាន>អ្វីដែលគាត់ចង់បាន<ហើយ>។ សាក្សីរូបនេះ<មិនអាចនិយាយអ្វីទាក់ទងនឹងអ្វីដែលកើតឡើងនៅតំបន់៤១ទេ ពីព្រោះគាត់>មិនមែនជាសមាជិកនៅក្នុងតំបន់៤១<នោះ។ របៀបដែលសហព្រះរាជអាជ្ញាកំពុងតែដំណើរការនីតិវិធីគឺមានភាពច្របូកច្របល់ ហើយអង្គជំនុំជម្រះតែងតែលើកលែងចំពោះការតាំងសំណួរបែបនេះ>។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក ឌេល លីសាក់៖**

លោកប្រធាន ខ្ញុំដឹងថាហេតុអ្វីបានជាមេធាវីការពារក្ដីគាត់មិនពេញចិត្ត<ចំពោះភស្តុតាងនេះ>។ ខ្ញុំចង់សួរមួយដំណាក់កាលម្ដងៗ។ សាក្សីដែលបានឆ្លើយនៅក្នុងកំណត់ហេតុនេះគឺថា គាត់បានទទួលបញ្ជាពីលេខាតំបន់៤១។ <សាក្សីរូបនេះបាននិយាយអំពីបុគ្គលនោះ។> អ៊ីចឹងឯងបានជាដំបូង ខ្ញុំចង់សួរថា តើលេខាស្រុកនៅក្នុងតំបន់៤១ នោះគឺមាន<តួនាទីអ្វីនៅ>ក្នុង<គណៈ>ភូមិភាគ<កណ្ដាល>នោះ? <នេះជាសំណួរទី១របស់ខ្ញុំ។>

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដីលោក នួន ជា។ សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយសហព្រះរាជអាជ្ញារងអន្តរជាតិ សំណួរចុងក្រោយអម្បាញ់មិញនេះ។

**លោក បាន សៀក៖**

**ឆ៖** បាទ ខ្ញុំបាទស្គាល់ឈ្មោះ តាអាន។ ពេលខ្ញុំបាទស្គាល់ គឺចូលព្រៃបានស្គាល់ ព្រោះដឹងថាតាអាន ហ្នឹងជាលេខាតំបន់៤១ ហើយជាគណៈអចិន្ត្រៃយ៍របស់ភូមិភាគ។

**ប្រធានអង្គជំនុំ៖**

បាទ បានហើយ។ បាទ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីដែលនឹងមកជំនួសលោកមេធាវី ឌុច ផារី នៅរសៀលនេះមកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងសវនាការនេះនៅវេលាម៉ោងមួយកន្លះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:៣៥ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយមុននឹងផ្តល់វេទិកាជូនទៅក្រុមសហព្រះរាជអាជ្ញារង តំណាងសហព្រះរាជអាជ្ញាក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ អង្គជំនុំជម្រះសួរទៅលោកស្រីមេធាវី សុក សុជាតា តើលោកស្រីអាចប្រាប់ដល់អង្គជំនុំជម្រះបានទេថា តើលោកស្រីនៅការិយាល័យ នៅមេធាវី ធ្វើមេធាវីហ្នឹងមានអត្តលេខប៉ុន្មាន ហើយការិយាល័យធ្វើការរបស់លោកស្រីនៅទីកន្លែងណាដែរ សព្វថ្ងៃនេះ?

**លោកស្រី សុក សុជាតា៖**

ចាស នាងខ្ញុំឈ្មោះមេធាវី សុក សុជាតា អត្តលេខ៧១០ ដែលមានការិយាល័យអមរិន្ទ ទីស្នាក់ការនៅផ្ទះលេខ៤៣E0 ផ្លូវ៤៣៤ សង្កាត់ទួលទំពូង១ ខណ្ឌចំការមន។ ចាស សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

[១៣:៣៤:៣១]

**លោក ឌេល លើសាក់៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ឌេល លើសាក់៖**

**ស៖** ជម្រាបសួរលោកសាក្សី។ [redacted] លោកបានបញ្ជាក់ថា លោកបានធ្លាប់ស្គាល់<>លេខាតំបន់៤១គឺ តាអាន។ សំណួររបស់ខ្ញុំ ថាតើ តាអាន មានតួនាទីអ្វីដែរនៅក្នុងគណៈកម្មាធិការភូមិភាគ<? តើ>គាត់ជា<អនុ>លេខា<ភូមិភាគកណ្តាល>ដែលស្ថិតនៅក្រោម កែ ពក <មែនទេ?>

**លោក បាន សៀក៖**

**ឆ៖** បាទ តាអាន ជាលេខាតំបន់ ជាគណៈអចិន្ត្រៃយ៍របស់ភូមិភាគ ហៅអនុភាគក៏បាន ហៅអចិន្ត្រៃយ៍ក៏បាន ហើយគាត់ទទួលតំបន់៤១។

**ស៖** ការបកប្រែដែលខ្ញុំស្ដាប់ឮដូចមិនសូវជាច្បាស់<>។ <តើលោកអាចប្រាប់ខ្ញុំម្ដងទៀតបានទេថា> នៅថ្នាក់គណៈ<>ភូមិភាគ គាត់មានតួនាទីជាអ្វីដែរ?

**ឆ៖** តាអាន គាត់ជាលេខាតំបន់៤១ ជាលេខាភូមិភាគឧត្ដរមានជ័យជាគណៈ -- ជាអនុ – អនុភូមិភាគ ជាគណៈអចិន្ត្រៃយ៍ភូមិភាគ។

[១៣:៣៦:៤០]

**ស៖** [redacted] <ខ្ញុំចង់ដឹងប្រតិកម្មរបស់លោកចំពោះសក្ខីកម្មនេះ ជាពិសេស> ខ្ញុំសួរលោកមើល តើលោកធ្លាប់ឮការបញ្ហាស្រដៀងគ្នានេះដែរទេនៅក្នុងតំបន់៤២?

**ឆ៖** បាទ ខ្ញុំបាទ អត់ដែលឮទេលោក។

**ស៖** លោកសាក្សី លោកស្ថិតនៅក្នុងស្រុកចំការលើពីពាក់កណ្ដាលឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ចំពោះការបាត់គ្រួសារចាម១.០០០គ្រួសារ<នៅក្នុងស្រុកហ្នឹង> ក្រៅពីការ<កំណត់អត្តសញ្ញាណ ហើយ>សម្លាប់<ចោលនោះ> តើវាមានបញ្ហាអី មូលហេតុអីផ្សេងទៀតទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំជំទាស់ទៅនឹងៗរបៀបតាំងសំណួរនេះ ដោយសហព្រះរាជអាជ្ញារងអន្ដរជាតិនេះ គាត់បានបង្ហាញភ័ស្ដុតាងដែលមិនអាចប្រកែកបានចេញពីកំណត់ហេតុស្ដាប់ចម្លើយរបស់សាក្សីដ៏សំខាន់ម្នាក់។ ខ្ញុំមិនដឹងថាតើសាក្សីរូបនេះ គាត់បានព័ត៌មាននេះមកពីណានោះទេ។ ដូច្នេះគាត់គួរតែរៀបសំណួរនេះឡើងវិញ ហើយកំណត់ប្រភពនៃភ័ស្ដុតាងនេះឲ្យបានច្បាស់លាស់ជាមុនសិន។

[១៣:៣៩:០៥]

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំរៀបចំសំណួរឡើងវិញ លោក<ប្រធាន>។ <លោកសាក្សី> ពីមុននេះ យើងបាននិយាយគ្នាថា គ្រួសារចាម១.០០០គ្រួសារនៅក្នុងស្រុកចំការលើបានបាត់ខ្លួននៅក្នុងរបបនោះ។ លោកអាចពន្យល់ជូនតុលាការបានទេ ថាហេតុអ្វីបានជាគ្រួសារចាមទាំងអស់នេះបាត់ខ្លួន <ក្រៅ>ពី<ត្រូវគេ>សម្លាប់<នោះ តើមាន>មូលហេតុអី<ផ្សេងទេ>?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះទៅលើពីរចំណុច។ ទី១ គឺសហព្រះរាជអាជ្ញារងបានស្នើឲ្យសាក្សីពន្យល់នូវព្រឹត្តិការណ៍មួយ ដែលក្នុងនាមជាសាក្សីមិនអាចផ្ដល់នូវសេចក្ដីពន្យល់ជាលក្ខណៈសន្និដ្ឋានណាមួយឲ្យទៅអង្គជំនុំជម្រះបានទេ។ ហើយទី២ សាក្សីរូបនេះបានឆ្លើយបញ្ជាក់រួចហើយខាងដើមថា គាត់មិនបានដឹងពីប្រជាជនចាម ១.១០០នាក់ជាងដែលបាត់ខ្លួន ឬថាមានចាមនៅក្នុងស្រុករបស់គាត់នោះទេ។ បើដូច្នេះបញ្ហានេះ វាជាការសួរផ្ទុយទៅនឹងសក្ខីកម្មដែលសាក្សីបានផ្ដល់ឲ្យក្នុងពេលកន្លងមក។ បាទ សូមអរគុណ។

**លោក ឌេល លីសាក់៖**

លោកប្រធាន បើសិនណាលោកសាក្សី គាត់មិនដឹង គាត់ឆ្លើយមិនដឹង គឺជាការស្រេចហើយ។

[១៣:៤០:៤៧]

**ប្រធានអង្គជំនុំ៖**

សំខាន់ លោករៀបចំសំណួរឡើងវិញ យើងគិតថា វាគួរតែរៀបរយឲ្យបានស្រួលបួល បើពុំដូច្នេះទេ មានតែបដិសេធប៉ុណ្ណោះ ពីព្រោះលោកឲ្យសាក្សីពន្យល់ ហើយនិងពាក់ព័ន្ធជាមួយនឹង១.០០០គ្រួសារ ឬក៏១.០០០នាក់ជនជាតិចាមនៅតំបន់៤២ហ្នឹង ដូចជាសាក្សីបានឆ្លើយបញ្ជាក់ថា ខ្លួនមិនបានដឹងតាំងពីដើមទីមក។

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន ខ្ញុំនឹងសួរសំណួរផ្សេង។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី យោងទៅលើបទពិសោធន៍របស់លោកជាកម្មាភិបាលថ្នាក់ស្រុក និងថ្នាក់តំបន់ តើលេខាតំបន់ និងលេខាភូមិភាគមានអំណាចសម្រេចថាត្រូវបោសសម្អាត និងកម្ទេចមនុស្សក្រុមណានោះដែរទេ? ឬក៏ថាសេចក្ដីសម្រេចកម្ទេចនេះ <មានតែថ្នាក់ដឹកនាំបក្សនៅភ្នំពេញទេ>? ខ្ញុំសួរនេះខ្ញុំមិនឱ្យលោកស្មានទេ សួរដោយលោកឆ្លើយ ដោយយោងទៅលើ<រយៈពេលដែល>លោកជាកម្មាភិបាលថ្នាក់ស្រុក និងថ្នាក់តំបន់?

**លោក បាន សៀក៖**

**ឆ៖** បាទ តាមខ្ញុំយល់ លេខាភូមិភាគ លេខាតំបន់ ដូចជាគ្មានសិទ្ធិសម្រេចទេ ទាល់តែមានទិសផែនការពីខាងលើ។ ខ្ញុំសូមទោស ខ្ញុំសូមឧទាហរណ៍បន្តិចទៅ ក្រែងលោថា ដូចជាសម្ដេចតេជោថាមានមិនឱ្យសម្លាប់នោះ តើយើងសម្លាប់បានទេ? រួចដល់ពេលនោះ តើអ្នកណាអ្នកឱ្យសម្លាប់? អាហ្នឹងបានដឹង ប៉ុណ្ណឹងបានហើយ។ ខ្ញុំសូមឆ្លើយប៉ុណ្ណឹង សូមអត់ទោស។

[១៣:៤២:៤៦]

**ស៖** ឥឡូវនេះខ្ញុំសូមសួរលោកពាក់ព័ន្ធទៅនឹងលោក នួន ជា។ លោកសាក្សី តើលោកដឹងតួនាទី នួន ជា ក្នុងរបបនោះដែរឬទេ ជាពិសេសពាក់ព័ន្ធទៅនឹងការអភិវឌ្ឍ ក៏ដូចជាពាក់ព័ន្ធទៅនឹងគោលនយោបាយបក្ស?

**ឆ៖** បាទ ខ្ញុំបាទបានដឹងតាមកម្មាភិបាលដូចគ្នាបានទៅរៀនជាមួយអ៊ំ នួន ជា ទេ។ ថាអ៊ំនួន ជា គឺថាមានគាត់មាន ដូចថាតឹង ដូចថាលិទ្ធិមួយតឹង។ ពេលណាទៅរៀន គាត់ប្រជុំ អត់មានប្រជុំ អត់មានថា ដូចថាគាត់ឱ្យប្រជុំ ឱ្យខិតខំធ្វើការ សំខាន់គឺឱ្យប្រជុំ។ ដូច្នេះ បើនិយាយពីស្ថានភាពនៅក្នុងហ្នឹងដែលខ្ញុំដឹង គឺមានតែអ៊ំ នួន ជា ទេ ដែលគាត់ជាអ្នកអប់រំកម្មាភិបាលថ្នាក់តំបន់ ថ្នាក់ស្រុក ថ្នាក់អី ដែលបានទៅរៀននៅជំនាន់មុននោះ។

**ស៖** តើ<នរណាខ្លះជា>កម្មាភិបាលដែលចូលរួមនៅក្នុងវគ្គរៀនសូត្រ<ឬកិច្ចប្រជុំ>ជាមួយ នួន ជា ហើយប្រាប់លោកហ្នឹង កម្មាភិបាលទាំងនោះឈ្មោះអ្វីដែរ?

**ឆ៖** កម្មាភិបាលថ្នាក់តំបន់ ដែលគាត់ជាកម្មាភិបាលអចិន្ត្រៃយ៍ស្រុក គាត់ទៅរៀនទៅ មកវិញដែលនៅក្នុងនោះ ដែលយើងសួរថា ទៅរៀនយ៉ាងម៉េចរៀនហ្នឹង? គេប្រាប់ទៅ។ ដូចជា បងប៉ូច អ៊ីចឹងគាត់បានទៅរៀន បានទៅរៀនខាងលើហើយ។ ដូច្នេះមក គាត់តែងតែប្រាប់ហើយ។ អ៊ីចឹងដូចជាខ្ញុំបាន

ទៅរៀនជាមួយអ៊ំ សុន សេន អ៊ីចឹង។ ទៅរៀនផ្ទះអ៊ំ សុន សេន គាត់អត់ទេ អត់សួរឲ្យប្រជុំទេ។ ដូចអ៊ំ នួន ជា ឲ្យប្រជុំ។ ខ្ញុំថាអ៊ំសុន សេន ទៅមើលកុនមើលអីហ្នឹងណ៎ា ដែលខ្ញុំទៅរៀនម្ដង។

[១៣:៤៥:០៣]

**ស៖** នៅពេលលោកនិយាយទៅដល់កម្មាភិបាលតំបន់ លោក<ចង់>និយាយអំពី<កម្មាភិបាលនៅក្នុងគណៈតំបន់ គឺ>គណៈតំបន់<៤២ ដែល>រួមមាន<សាច់ថ្លៃរបស់លោក>ឈ្មោះ អឿន នោះផងដែរ។ លោកចង់និយាយថាអ៊ីចឹង ឬយ៉ាងណា?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ!

**លោក បាន សៀក៖**

**ឆ៖** បាទ ថ្នាក់តំបន់ ថ្នាក់ស្រុក លេខាស្រុកទៅ ទៅរៀន។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមអានសម្រង់នៃចម្លើយរបស់លោក ឯកសារ <E319/2823.1> នៅត្រង់ចម្លើយលេខ១០ លោកបានឆ្លើយទៅនឹងសំណួរដូចតទៅ៖ “សួរ៖ តាមដែលលោកដឹង តើអ្នកណាចេញបញ្ជាឲ្យបោសសម្អាតប្រជាជននៅភូមិភាគកណ្ដាល និងសម្លាប់ជនជាតិចាម? ឆ្លើយ៖ ខ្ញុំមិនដឹងពិតប្រាកដអំពីរឿងនេះទេ ប៉ុន្តែខ្ញុំចាំអ្វីដែលខ្ញុំឮពីគេ អ្នកដទៃទៀតនិយាយថា នៅក្នុងរបបនោះ ប៉ុល ពត គឺមិនមែនជាអ្នកដែលចេញបញ្ជាទាំងអស់នេះនោះទេ <គាត់>គ្រាន់តែជាអ្នកនៅពីលើ និងអ្នកនៅពីក្រោយឆាក<នយោបាយ>ប៉ុណ្ណោះ។ គេនិយាយថា អ្នកដែលចេញបញ្ជាសម្រាប់រឿងទាំងនេះ គឺ នួន ជា ពីព្រោះគាត់គឺជាអ្នកដែលរៀបចំបង្កើតគោលនយោបាយ និង<ដាក់ឲ្យ>អនុវត្តគោលនយោបាយបក្សកុម្មុយ-នីស្តកម្ពុជា។” បញ្ចប់ការដកស្រង់។

ឥឡូវនេះ ខ្ញុំចង់សួរបញ្ជាក់ឲ្យច្បាស់ត្រង់ចំណុចនេះ។ តើនរណាដែលបានប្រាប់លោកអំពីរឿង នួន ជា នេះ? តើមនុស្សដដែល ដែលលោក<ទើបតែ>បញ្ជាក់<អម្បាញ់មិញនេះ គឺអ្នកដែលនៅ>គណៈ<>ស្រុក និង<>គណៈតំបន់ហ្នឹងឬដែលនិយាយប្រាប់លោក<មែនទេ>?

[១៣:៤៧:១៩]

**ឆ៖** បញ្ហានេះគឺថា ជាផែនការរបស់ខាងលើ ក៏ប៉ុន្តែតាមដែលមិត្តៗខាងលើប្រាប់ថា អ៊ំប៉ុល ពត គាត់ដូចជានៅខាងលើ មិនដែលចុះមកអប់រំផ្ទាល់ច្រើនទេ ព្រោះច្រើនតែអ៊ំនួន ជា ជាអ្នកអប់រំ។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដូច្នេះជាផែនការ ជានយោបាយ ជាសកម្មភាព បញ្ហាអភិវឌ្ឍន៍ស្អីៗ បញ្ហាកម្លាំងសហករណ៍ រៀបចំសហករណ៍យ៉ាងម៉េចៗ គឺមានតែអ៊ំនួន ជា ហ្នឹងឯង។

**ស៖** ហើយសំណួររបស់ខ្ញុំ<ទាក់ទងនឹង>ព័ត៌មានដែលលោកឆ្លើយទៅនឹងសំណួរ<មុន>នេះ តើ<ព័ត៌មាននោះចេញមកពី>កម្មាភិបាល<តែមួយ>ដែលលោកទើបលើកឈ្មោះអម្បាញ់មិញ<ឬយ៉ាងណា> ដែលជាសមាជិកគណៈ<>ស្រុក <និង>គណៈ<>តំបន់ដែលបានចូលរួមក្នុងវគ្គរៀនសូត្រ<ដែលធ្វើឡើងដោយ> នួន ជា <>?

**ឆ៖** សូមបញ្ជាក់ថា អានេះដឹងតាមការនិយាយដូចថា ដូចប្អូន អឿន ហ្នឹងទៅជួប ថាម៉េចបានជាមានការបោសសម្អាតអី? ថាខាងលើ មិនមែនផែនការទេ រឿងទី១ សេ.អ៊ី.អា, ទី២ កា.ហ្សេ.បេ ដូច្នេះគេដាក់អីចឹងឯង ដាក់ជាស្លាកអក្សរខ្មៅថា "សេ.អ៊ី.អា និង កា.ហ្សេ.បេ ត្រូវតែកម្ទេចចោលទាំងអស់"។

[១៣:៤៩:០៦]

**ស៖** ហើយថាតើលេខាតំបន់ឈ្មោះ អឿន នេះមានបាននិយាយប្រាប់លោកអំពីតួនាទីពិតប្រាកដរបស់ នួន ជា ដែរទេ?

**ឆ៖** បាទ ប្រាប់។

**ស៖** ឥឡូវនេះ ខ្ញុំសួរលោកពីអំឡុងពេលក្នុងឆ្នាំ១៩៧៨ នៅពេលកម្មាភិបាលភូមិភាគបូព៌ាត្រូវបានគេបោសសម្អាត ហើយលោកត្រូវបានបញ្ជូនឲ្យទៅធ្វើជាលេខាស្រុកក្រូចឆ្មារ។ ទី១ ដើម្បីបញ្ជាក់ថានៅពេលណាដែលគេបញ្ជូនលោកទៅធ្វើជាលេខាស្រុកក្រូចឆ្មារហ្នឹង? តើមុន ឬក្រោយការចាប់ខ្លួនកម្មាភិបាលមូលដ្ឋាននៅភូមិភាគបូព៌ា នៅពេលដែលគេបញ្ជូនលោកទៅធ្វើការនៅក្នុងស្រុកក្រូចឆ្មារនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វិ៉ចទ័រ កូប៉េ!

**លោក វិ៉ចទ័រ កូប៉េ៖**

ខ្ញុំជំទាស់ទៅនឹងការរៀបចំសំណួរនេះ។ តំណាងសហព្រះរាជអាជ្ញាប្រើពាក្យ "ការបោសសម្អាត" និង "ការចាប់ខ្លួន" កម្មាភិបាលភូមិភាគបូព៌ា ជាពិសេសគាត់<សំដៅ>ទៅលើស្រុកក្រូចឆ្មារដែលស្ថិតនៅក្នុងតំបន់<២១>។ យើងដឹងហើយថា នៅពេលនោះ<មិន>មានការចាប់ខ្លួនជាច្រើន

<ទេ> នៅពេលដែលគាត់ទៅធ្វើនៅស្រុកក្រូចឆ្មារ គឺមាន<ជម្លោះ>ប្រដាប់អាវុធ <និងសង្គ្រាមយោធា>ពេញទំហឹងហើយ។ ដូច្នេះខ្ញុំ<គិតថា ការប្រើពាក្យ "ការបោសសម្អាត" និង "ការចាប់ខ្លួន" នៅក្នុងសំណួរនេះមិន>ត្រឹមត្រូវ<ទេ>។

[១៣:៥១:០៨]

**លោក ឌេល លីសាក់៖**

លោកមេធាវី ឥឡូវនេះកំពុងតែផ្តល់សក្ខីដោយខ្លួនឯងហើយ។ ខ្ញុំយល់ឃើញថា ការរៀបរាប់របស់គាត់ហ្នឹង គឺវាខុសហើយ<។ មានកំណត់ហេតុមួយបញ្ជាក់>ថាកម្មាភិបាលភូមិភាគបូព៌ារាប់រយពាន់នាក់ត្រូវបានចាប់ខ្លួន និងបញ្ជូនមក ស-២១ <នៅពេលនោះ ហើយខ្ញុំរីករាយនឹងផ្តល់លេខឯកសារយោង>។ តែយ៉ាងណា គឺថាខ្ញុំ<សាកល្បង>រៀបសំណួរតាមរបៀបផ្សេងឡើងវិញ<ដើម្បីសួរសាក្សីរូបនេះ>។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកសាក្សី តើលោកបានដឹង<ទេ>ថា<មាន>កម្មាភិបាលភូមិភាគបូព៌ា<ដែល>អាចត្រូវបានគេចាប់ខ្លួន <> ឬក៏អាចថា<>រត់គេចចូលខ្លួនទៅក្នុងព្រៃ<>នៅក្នុងឆ្នាំ១៩៧៨? ហើយ<ទាក់ទងនឹង>ពេលដែលគេបញ្ជូនលោកទៅធ្វើការស្រុកក្រូចឆ្មារនោះ <តើ>គេបញ្ជូនទៅមុន ឬក៏ក្រោយពេល<ដែល>កម្មាភិបាលភូមិភាគបូព៌ាត្រូវបានគេ<ចាប់ខ្លួន> ឬក៏រត់គេចខ្លួនចូលទៅក្នុងព្រៃនោះ?

**លោក បាន សៀក៖**

**ឆ៖** បាទ ក្នុងពេលដែលខ្ញុំទៅគឺអ៊ំ ជា ស៊ីម, ហេង សំរិន គាត់បានផ្តាច់ខ្លួនទៅចូលព្រៃហើយ។ ដូច្នេះ កាលខ្ញុំទៅហ្នឹង ខែនោះរៀបចំរណសិរ្សសាមគ្គីសង្គ្រោះជាតិហើយ។ ហើយបងប្អូនដែលប្រាប់ថាមានទាំងទង់ជ័យកំពូលប្រាំអី ហើយមានកងឈ្លបប្រទូស្តប្រទាំងគ្នា ដែលខ្ញុំទៅអ៊ីចឹង។ ហើយដែលការបោសសម្អាតហ្នឹង ខ្ញុំបាទអត់ដឹងទេ ព្រោះខ្ញុំបាទនៅឯឡូត៍នេសាទទេ។ ការបោសសម្អាតហ្នឹង អត់ដឹងទេ ព្រោះហ្នឹងរឿងខាងលើទេលោក។

[១៣:៥៣:០៣]

**ស៖** កម្មាភិបាលមកពីភូមិភាគបូព៌ាមួយចំនួនបានផ្តល់កាលបរិច្ឆេទថា គឺថ្ងៃទី២៥ ខែឧសភា ១៩៧៨ ជាកាលបរិច្ឆេទដែលគេចាប់ខ្លួនកម្មាភិបាល<ជាន់ខ្ពស់ជាច្រើន> រួមទាំងមនុស្សដែលលោកបានលើកឈ្មោះឡើងនេះ រត់ចូលព្រៃ។ <តើ>លោកចាំទេថា <រយៈពេលប៉ុន្មាន>ក្រោយថ្ងៃទី២៥

ឧសភា ៧៨ <ដែល>គេបញ្ជូនលោកទៅស្រុកក្រូចឆ្មារ<>?

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹងចំណុចលម្អិតនៃការតាំងសំណួរនេះ។ ខ្ញុំ<គិត>ថា ពាក្យថា "រត់ចូលព្រៃ" នេះមិនត្រូវទេ <ពួកគេ>រត់ទៅវៀតណាម។ ដូច្នេះសូមរៀបសំណួរឲ្យស្រួលបួល។ មិនមែនរត់ចូល "ព្រៃ" ទេ <គឺ>រត់ទៅ "វៀតណាម"។

**លោក ឌេល លីសាក់៖**

ប៉ុន្តែគេរត់ហ្នឹង គេរត់ចូលព្រៃមុន<សិន ប៉ុន្តែខ្ញុំរីករាយនឹងបញ្ចូលវាទៅក្នុងសំណួរ>។ <ពួកគេបានរត់គេចចូលព្រៃ ហើយអ្នកខ្លះទៀតបន្តរត់>ទៅវៀតណាម។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** តើគេបញ្ជូនលោកទៅធ្វើការនៅស្រុកក្រូចឆ្មារនៅពេលណា ដោយយក<>ថ្ងៃទី២៥ ឧសភា ៧៨ <>នេះជាគោល តើលោកវិញគេបញ្ជូនទៅក្រូចឆ្មារនៅថ្ងៃខែឆ្នាំណា? <តើលោកចាំទេ?>

**លោក បាន សៀក៖**

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងថ្ងៃខែទេ លោក។ ខ្ញុំដឹងតែអ៊ំ ជា ស៊ុម, អ៊ំ ហេង សំរិន ចូលទៅផ្ដាច់ខ្លួនទៅខាងវៀតណាមទៅ ហើយដឹងថាគេថា មិនមែនថាអ៊ីចឹងទេ គេថាភូមិភាគបូព៌ាក្បត់ទាំងអស់ហ្នឹងឯងក្បត់។ គេថាពួក កា.ហ្សេ.បេ។

[១៣:៥៥:០១]

**ស៖** ខ្ញុំនឹងសួរបញ្ជាក់ចំណុចនេះនៅពេលក្រោយបន្តិច។ នៅពេលដែលលោកធ្វើជាលេខាស្រុកក្រូចឆ្មារ តើអ្នកណាជាលេខាតំបន់? ហើយអ្នកណាជាលេខាភូមិភាគដែលត្រូវលោករាយការណ៍ទៅឲ្យទាំងពីរថ្នាក់ខាងលើហ្នឹង?

**ឆ៖** បាទ លេខាតំបន់ឈ្មោះ រិន ជាយោធា ប៉ុនមកទទួលលេខាតំបន់។ សុន សេន ជាអគ្គបញ្ជាការកងទ័ព ទទួលជាលេខាភូមិភាគ។

**ស៖** អ៊ីចឹងខ្ញុំសូមសួរលោកពីឈ្មោះ រិន នេះមុនសិន។ តើ រិន នេះមកខាងណាដែរ?

**ឆ៖** បាទ រិន នេះមកខាងនិរតីលោក។

**ស៖** តើលោកដឹងថា រិន នេះជាសាច់ឈាមរបស់ តាម៉ុក ដែរឬក៏អត់ទេ?

**ឆ៖** បាទ លោកមានប្រសាសន៍ត្រឹមត្រូវហើយ។ សុទ្ធខ្សែរបស់ តាម៉ុក ទាំងអស់។ ភូមិភាគ

និរតីខាងខ្សែ តាម៉ុក ទាំងអស់។

[១៣:៥៧:២៣]

**ស៖** លោកបានលើកពីឈ្មោះ សុន សេន ថា<>ជាលេខាភូមិភាគ។ សាក្សីមួយចំនួន<ផ្សេងទៀត>បានផ្តល់សក្ខីកម្មថា នួន ជា ទេដែលជាលេខាភូមិភាគបូព៌ាក្រោយ សោ ភឹម ស្លាប់ទៅ។ ជាពិសេស <សាក្សីដែលជាសមាជិកគណៈ>ស្រុកត្បូងឃ្មុំ<ឈ្មោះ> ម៉ាត់ លី<។ នេះ>គឺ<បទសម្ភាសន៍គឺ>ឯកសារនេះលេខ E3/390, ERN ជាភាសាខ្មែរ 00392076, អង់គ្លេស <00436853>, បារាំង 00479788។ ម៉ាត់ លី បានឆ្លើយទៅនឹងកិច្ចសម្ភាសន៍ដូចតទៅ៖ “ខ្ញុំបានឃើញថា នៅពេលដែល<គេប្រកាស>ថា សោ ភឹម <បានស្លាប់បាត់>ទៅ<ហើយ នួន ជា ក៏> បានក្លាយទៅជាលេខាភូមិភាគ និង តាន់ សេងហុង ជាអនុ ប៉ុន្តែ<តាមពិត គឺហាក់ដូចជា>អត់ដែលបានឃើញ<មុខលោក នួន ជា និងលោក> តាន់ សេងហុង ទេ។” បញ្ចប់ការដកស្រង់។ ហើយនៅក្នុងឯកសារ E3/455 ERN អង់គ្លេស 00149917, ខ្មែរ 00146678, បារាំង 00149943 នេះជាកិច្ចសម្ភាសន៍<ប្រធានមន្ទីរ> ស-២១ <ឈ្មោះ> ឌុច ដែលឆ្លើយថា៖ “កម្លាំងភូមិភាគបូព៌ាដែលស្ថិតនៅក្រោម សោ ភឹម ត្រូវបានកម្ទេចអស់ទាំង<>ស្រុងហើយ ហើយកម្លាំងនៅក្រោម តាម៉ុក ត្រូវបានដាក់ទៅជំនួស។ ប៉ុន្តែ នួន ជា ក៏បានក្លាយទៅជាលេខាភូមិភាគបូព៌ា។” បញ្ចប់ការដកស្រង់។

ដូច្នេះសំណួររបស់ខ្ញុំ <តើ>ធ្វើម៉េចបានជាលោកដឹង<>ថា សុន សេន ជាលេខាភូមិភាគ? ហើយចុះលោកមានប្រតិកម្មយ៉ាងម៉េចដែរជាមួយ<ចម្លើយរបស់>សាក្សី<ទាំងនេះ>ដែល<>ឆ្លើយថា នួន ជា ទៅវិញទេដែលជាលេខាភូមិភាគបូព៌ានោះ?

[១៣:៥៩:៣៩]

**ឆ៖** បាទ ខ្ញុំបាទបានទៅរៀននៅភូមិភាគ គឺមាន សុន សេន ជាអ្នកបង្រៀនអប់រំខ្ញុំបាទ ហើយនិង វិន ជាមួយគ្នានឹង ព្រោះអត់មានមន្ទីរទេ ព្រោះចល័តហើយ ព្រោះក្តៅហើយ ព្រោះវៃវៀតណាមវៃចូលហើយ។ អត់មានអ៊ំ នួន ជា ទេគឺ សុន សេន តែម្តង ព្រោះខ្ញុំជាថ្នាក់ស្រុកទៅរៀននោះឯង។

**ស៖** ខ្ញុំនឹងសួរអំពីវគ្គរៀនសូត្រនេះនៅពេលក្រោយ។ តើនៅក្នុងអង្គប្រជុំនេះ សុន សេន មានបានឧទ្ទេសនាមថា គាត់ជាលេខាភូមិភាគបូព៌ាថ្មីដែរទេ?

**ឆ៖** បាទ កាលនោះគាថាគាត់ជាលេខាភូមិភាគ មានអ៊ំ ហុង គាត់ជាអនុលេខាភូមិភាគ ទទួលតំបន់ភ្លោះ។

**ស៖** សូមអរគុណ។ នៅពេលលោកធ្វើជាលេខាស្រុកក្រូចឆ្មារ មន្ទីររបស់លោកស្ថិតនៅត្រង់កន្លែងណាដែរពេលនោះ?

**ឆ៖** បាទ អត់មានកន្លែងមន្ទីរទេ ព្រោះសភាពការណ៍ហ្នឹង អត់មានដាក់មន្ទីរបានទេ ចល័តតែម្តង។

**ស៖** នៅក្នុងចម្លើយរបស់លោកឆ្លើយជូនការិយាល័យសហចៅក្រមស៊ើបអង្កេត លោកនិយាយអំពីកិច្ចប្រជុំថ្នាក់ស្រុក។ តើ<>កិច្ចប្រជុំថ្នាក់ស្រុកដែលលោកបានឆ្លើយនោះ គេធ្វើនៅកន្លែងណា?

**ឆ៖** ប្រជុំហ្នឹងជួនណានៅកន្លែងវត្តទៅ ជួនណាទៅនៅឯក្រូចឆ្មារទៅ ចល័ត អត់មាននៅទេ។ ខ្ញុំសូមជម្រាបថា មិនទាន់បានប៉ុន្មានថ្ងៃផង កម្លាំងពីក្នុងបាញ់កម្មាភិបាលអនុស្រុកឈ្មោះ ឱ ត្រូវគ្រាប់បាត់ហើយ ព្រោះកម្លាំងឈ្លបទៅដល់ហើយ។

**ស៖** លោកបានកំណត់ទីកន្លែងពីរ<។ ខ្ញុំគ្រាន់តែចង់បានព័ត៌មានច្បាស់ជាងនេះ។ លោក> ថា កិច្ចប្រជុំ<ទាំងនោះ>ជួនកាលប្រជុំនៅក្នុងវត្ត។ វត្តឈ្មោះអីដែរ? ហើយវត្តហ្នឹងស្ថិតនៅក្នុងភូមិឃុំណាដែរ?

[១៤:០២:៣៦]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ!

**លោក បាន សៀក៖**

**ឆ៖** បាទ ខ្ញុំបាទអត់ស្គាល់វត្តទេ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** លោកឆ្លើយថា ជួនកាលអង្គប្រជុំហ្នឹង<ធ្វើ>នៅឯស្រុកក្រូចឆ្មារ។ នៅស្រុកក្រូចឆ្មារហ្នឹងប្រជុំនៅៗកន្លែងណា? សូមលោកបញ្ជាក់ពីការប្រជុំនៅស្រុកក្រូចឆ្មារហ្នឹងមើល នៅស្រុកក្រូចឆ្មារមែនប៉ុន្តែនៅកន្លែងណា?

**ឆ៖** នៅកន្លែងពាណិជ្ជកម្មស្រុក។ ពាណិជ្ជកម្មស្រុកចាស់គេ កន្លែងគេ។

**ស៖** អតីតមន្ទីរពាណិជ្ជកម្មចាស់នេះ តើពេលខ្លះមានត្រូវបានប្រើប្រាស់ដើម្បីឃុំខ្លួនមនុស្សដែលគេបានចាប់ខ្លួនដែរឬទេ?

**ឆ៖** បាទ អត់ទេ។

**សះ** ខ្ញុំសូមអានចម្លើយដែលលោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេត គឺឯកសារ E3/375, ERN ជាភាសាខ្មែរ 00348802 ដល់ 03, អង់គ្លេស 00360762, បារាំង 00369924។ នេះគឺជាអ្វីលោកបានឆ្លើយនៅក្នុងកិច្ចសម្ភាសន៍នោះ។ សូមដកស្រង់សម្ដីលោក៖ “កន្លែងមួយ<ដែល>ស្ថិតនៅក្នុងមន្ទីរពាណិជ្ជកម្មនៅទីរួមស្រុកក្រូចឆ្មារ <ត្រូវបានប្រើ>ជាកន្លែងឃុំខ្លួនមនុស្សមុនពេលយកទៅកម្ទេចចោល។” បញ្ចប់ការដកស្រង់។ តើ<មន្ទីរនោះនៅកន្លែងណា តាមដែលលោកបានរៀបរាប់>នៅក្នុងកិច្ចសម្ភាសន៍មួយនេះ<? តើគេ>ឃុំមនុស្ស<នៅឯណា>មុនពេលយកទៅកម្ទេចចោល? <តើ>មន្ទីរពាណិជ្ជកម្មនេះមានទីតាំងនៅត្រង់កន្លែងណាដែរ?

[១៤:០៥:២២]

**ឆះ** ខ្ញុំភ្លេចហើយលោក អត់ចាំ។

**សះ** ឥឡូវនេះខ្ញុំសួរមើល តើលោកមានប្រតិកម្មយ៉ាងម៉េចដែរចំពោះ<>ចម្លើយរបស់សាក្សីផ្សេង<មួយទៀត។ សម្រាប់ប្រតិចារឹក> គឺសាក្សី <2-TCW-904 នេះគឺជាបទសម្ភាសន៍ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត> គឺឯកសារ E3/9324, <>ERN ជាភាសាខ្មែរ 00204457, អង់គ្លេស 00242064, បារាំង 00485139។ នេះគឺជាចម្លើយពីសាក្សីមួយរូបមកពីភូមិទ្រា២ ដែល<គាត់>ក្នុងរបបនោះ ធ្វើការជាស្មៀនឃុំ។ សូមដកស្រង់៖ “ថ្ងៃនេះ ខ្ញុំសូមបង្ហាញជូនអ្នកស៊ើបអង្កេត<របស់សាលាក្ដីខ្មែរក្រហមនូវ>ទីតាំង<នៃមន្ទីរឃុំរបស់ខ្មែរក្រហមនៅ>ឃុំទ្រា<២ នៅក្នុងឆ្នាំ១៩៧៥។> នៅក្នុងខែឧសភា ១៩៧៨ គេបានយកទីតាំងនេះប្រើប្រាស់ជាមន្ទីរស្រុក<វិញ។> ក្រោយមកគេក៏យកផ្ទះពីរនៅជាប់មន្ទីរស្រុកហ្នឹង ប្រើប្រាស់ជាមន្ទីរស្រុកទៀត<។> ហើយគេកំណត់ទីតាំងខាងជើង<និង>ខាងត្បូង<នៃមន្ទីរ>ស្រុកហ្នឹងថាជាទីតាំងមន្ទីរសន្តិសុខស្រុក។ <ផ្ទះទាំងអស់ដែល>នៅជុំវិញមន្ទីរស្រុកនេះ គឺថាប្រើប្រាស់ជាកន្លែងឃុំឃាំងមនុស្ស។” តើវាត្រឹមត្រូវដែរទេ សក្ខីកម្មរបស់សាក្សីម្នាក់នេះ ដែលបានឆ្លើយថាមន្ទីរដែលលោកបានរៀបរាប់នេះ ត្រូវបានគេយកទៅប្រើប្រាស់ជាមន្ទីរ<ស្រុក>គឺនៅក្នុងភូមិទ្រានេះឯង អ៊ីចឹង ឬក៏យ៉ាងណា? តើលោកមានប្រតិកម្មយ៉ាងម៉េច?

**ឆះ** តាមការពិត គឺថាយើងមិនបានរៀបចំកន្លែងជាកំណត់ទេ ហើយមិនមានកន្លែងឃុំឃាំងមនុស្សទៀត អត់មានទេ ព្រោះអត់មានសន្តិសុខទេ អត់មានកន្លែងសន្តិសុខទេ។

[១៤:០៧:៥៥]

**សះ** លោកទើបតែជម្រាបជូនតុលាការប៉ុន្មាន<នាទី>មុននេះ ថាមន្ទីរពាណិជ្ជកម្មត្រូវបានយក

ទៅប្រើប្រាស់ជាមន្ទីរស្រុក។ តើមន្ទីរពាណិជ្ជកម្មដែលត្រូវបានយកប្រើប្រាស់ជាមន្ទីរស្រុកដែលលោកថានេះ ស្ថិតនៅក្នុងភូមិទ្រាហ្នឹងឬ?

**ឆ៖** មន្ទីរពាណិជ្ជកម្មនៅក្នុងទីប្រជុំជន មានកន្លែងមួយ កន្លែងដែលខ្ញុំនៅ កន្លែងហ្នឹងកន្លែងហៅក្រូចឆ្មារ គេហៅក្រូចឆ្មារៗ មានកន្លែងចតកាណូត ចតអី កន្លែងពាណិជ្ជកម្មនៅកន្លែងហ្នឹង។

**សៈ** ហើយកន្លែងដែលគេចតទូកកាណូតហ្នឹង វាជាៗកំពង់ចម្លងដែលៗស្ថិតនៅក្នុងភូមិទ្រា <ឃុំទ្រា>ហ្នឹងដែរ ឬក៏យ៉ាងម៉េច? <តើលោកចាំទេ លោកសាក្សី?>

**ឆ៖** នៅក្នុងកន្លែងទី -- កន្លែងនោះ ហៅថាកន្លែងថាក្រូចឆ្មារតែម្តង កន្លែងហ្នឹងដាក់ក្រូចឆ្មារ ព្រោះកន្លែងហ្នឹងមានកន្លែងនេះ ស្ពានគេសម្រាប់ចុះកាណូតអី ចតនៅកន្លែងហ្នឹងឯង។ មិនមែនភូមិទ្រាទេ គឺក្រូចឆ្មារ។

**សៈ** បាទ ខ្ញុំសូមចូលទៅប្រធានបទមួយទៀត គឺនិយាយពីឈ្មោះហៅក្រៅដែលលោកបានប្រើប្រាស់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ លោកបានកំណត់ឈ្មោះពីរ ដែលលោកបានប្រើប្រាស់ <ក្នុងបទសម្ភាសន៍ទាំងនោះ។> មួយហៅ "ហង្ស <ផុស>" ហើយមួយទៀត "ហង្ស ស៊ុនហ៊ូ"។ តើឈ្មោះហៅក្រៅទាំងពីរនេះ ឈ្មោះហៅក្រៅមួយណាដែលលោកនិយមប្រើប្រាស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យសម្រាប់ខ្លួនលោកនេះ?

[១៤:១០:០៤]

**ឆ៖** បាទ ឈ្មោះខ្ញុំពីកំណើតឈ្មោះ ហង្ស ស៊ុនហ៊ូ។ ដល់មកធ្វើបដិវត្តន៍ ខ្ញុំបាទដាក់ឈ្មោះ ហង្ស ផុស។ សព្វថ្ងៃគេហៅក្រៅ គេហៅ ផុសៗ។ ឈ្មោះក្នុងអត្តសញ្ញាណប័ណ្ណឈ្មោះ បាន សៀក។

**សៈ** លោកសាក្សី នៅក្នុងពេលលោកនៅស្រុកក្រូចឆ្មារ តើលោកប្រើឈ្មោះ ហ៊ូ ហ្នឹងឬក៏អត់?

**ឆ៖** បាទ អត់ប្រើទេ។

**សៈ** ឥឡូវនេះ ខ្ញុំសូមសួរលោកអំពីសក្ខីកម្មដែលឆ្លើយដោយអតីតកម្មាភិបាល<មួយចំនួន> ដែល<បានកំណត់អត្តសញ្ញាណលោកដោយឈ្មោះ> គឺអតីតកម្មាភិបាលមកពីស្រុកក្រូចឆ្មារ<ដែលកំណត់អត្តសញ្ញាណលោក ហើយ>ស្គាល់<>ថាលោកឈ្មោះ ហ៊ូ។ ទី១ គឺចម្លើយឆ្លើយជូនសហចៅក្រមស៊ើបអង្កេតE3/5253, ERNជាភាសាខ្មែរ 00235002, អង់គ្លេស 00235483, បារាំង 00250059 នេះគឺឯកសារ E3/5253។ លោកសាក្សី នេះគឺជាសក្ខីកម្មរបស់អ្នកភូមិ<ជាស្ត្រី>ម្នាក់ដែលធ្វើជាចុងភៅសម្រាប់មន្ទីរពាណិជ្ជកម្មស្រុកក្រូចឆ្មារ ឆ្លើយដូចតទៅ៖ "សួរ តើលោកស្គាល់សម

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មិត្ត ហូ ដែលជាលេខាស្រុក ដែលបាន<ទៅ>ពិនិត្យមើល<មន្ទីរ>នោះដែរឬទេ? ឆ្លើយថា៖ ចាស ខ្ញុំធ្លាប់ឃើញគាត់មកមើលមន្ទីរពាណិជ្ជកម្ម ពីព្រោះមន្ទីរហ្នឹងកាលពីមុន គ្រាន់តែជាកន្លែងសម្រាប់កម្មាភិបាលជាន់ខ្ពស់រស់នៅ។" បញ្ចប់ការដកស្រង់។ <សាក្សីម្នាក់ទៀត គឺ>កម្មាភិបាលដែលមកពី<កន្លែងតែមួយក្នុង>ស្រុកក្រូចឆ្មារនេះ<>គឺ<សាក្សី> 2-TCW-904 <នេះគឺជាអ្នកដែល>ធ្លាប់ធ្វើជាស្មៀននៅ<មន្ទីរឃុំទ្រា។ នៅក្នុងកិច្ចសម្ភាសន៍> គឺឯកសារ<> E3/5288, ERNជាភាសាខ្មែរ 00326653 ដល់54, អង់គ្លេស 00336290 ដល់ 91, បារាំង 00411588 ដល់ 89។ ហើយខ្ញុំសូមអាននូវអ្វីដែលសាក្សីរូបនេះបានឆ្លើយ សូមដកស្រង់៖ "គណៈស្រុកក្រូចឆ្មារ ឈ្មោះ ហូ។ ក្នុងឆ្នាំ១៩៧៨ ហូ បានមកធ្វើជាគណៈស្រុក ហើយបានតែងតាំងឈ្មោះ ម៉េង ជាគណៈឃុំទ្រា។ ហូ ធ្លាប់ទៅមើលកន្លែងខ្ញុំម្តងម្កាល។ ហើយបន្តមកទៀតសួរ៖ តើលោកបានជួប ហូ មុនដំបូងនៅពេលណា? ឆ្លើយ៖ ប្រហែលជានៅខែមិថុនា ឬខែកក្កដា ឆ្នាំ១៩៧៨ ពេលនោះ ខ្ញុំបានឃើញគាត់ដើរនៅតាមផ្លូវទៅមកៗ។ ខ្ញុំធ្លាប់ចូលរួមប្រជុំជាមួយគាត់ម្តងនៅផ្ទះបាយក្នុងមន្ទីរឃុំទ្រា។ សួរ៖ តើកិច្ចប្រជុំនោះធ្វើឡើងនៅក្នុងឆ្នាំណា? ឆ្លើយ៖ ប្រហែលជាខែកញ្ញា ឆ្នាំ១៩៧៨។ សួរ៖ តើហេតុអ្វីបានជាលោកស្គាល់ថាគាត់ឈ្មោះ ហូ? ឆ្លើយ៖ ខ្ញុំ<ដឹងថាគាត់>ឈ្មោះ ហូ ពីព្រោះគណៈឃុំហៅគាត់ថា ហូ។ ហើយសំណួរពីរបីខាងក្រោមមកទៀតសួរ៖ តើលោកដឹងថាគាត់មកពី<តំបន់ណា>មុនគាត់មក<ធ្វើ>ជាគណៈស្រុក<>? ឆ្លើយ៖ គាត់ធ្លាប់ធ្វើជាអ្នកនេសាទតំបន់នៅស្រុកស្ទឹងត្រង់។" បញ្ចប់ការដកស្រង់។

លោកសាក្សី <វាហាក់ដូចជា>មានមនុស្សមួយចំនួនចាំឈ្មោះលោក ហើយ<បានកំណត់អត្តសញ្ញាណ>លោកថាជាអតីតអ្នក<>នេសាទ<តំបន់ ប៉ុន្តែតើនរណា>ស្គាល់<លោកថា>ឈ្មោះ ហូ។ តើ<អាចទៅរួចទេដែលថាលោកភ្លេចបាត់ទៅហើយ ហើយការពិតក្នុងរយៈពេលខ្លីដែល> លោកនៅជាលេខាស្រុកក្រូចឆ្មារ<> លោកប្រើឈ្មោះ ហូ មិនប្រើឈ្មោះ ផុស ទេ <>តើវាអាចអ៊ីចឹងដែរ ឬក៏យ៉ាងណា?

[១៤:១៥:១៨]

**ឆ៖** បាទ កាលនោះស្រុកក្រូចឆ្មារ ខ្ញុំអត់ដាក់ឈ្មោះ ហូ ទេ។ បើស្គាល់ខ្ញុំ ប្រហែលនៅឡូត៍នេសាទ។ ឡូត៍នេសាទខ្ញុំនៅហៅឈ្មោះ ហូ។ ដល់ទៅស្រុកក្រូចឆ្មារ ទៅតាំងពីទៅដល់តំបន់៤២ លែងដាក់ឈ្មោះ ហូ ហើយ។

**ស៖** ខ្ញុំសូមចូលទៅប្រធានបទមួយផ្សេងទៀត។ នៅពេលដែលលោកធ្វើជាលេខាស្រុកក្រូចឆ្មារ

តើខ្លួនលោកផ្ទាល់នេះ មានសិទ្ធិអំណាចចេញសេចក្ដីសម្រេចថា ត្រូវឲ្យសម្លាប់អ្នកណាចោលដែរឬទេ? ហើយបើលោកមិនមានទេ ចុះអ្នកណាជាអ្នកមានសិទ្ធិអំណាចចេញបញ្ជាឲ្យសម្លាប់មនុស្សចោលនោះ?

**ឆ៖** បាទ ខ្ញុំបាទមិនមានសិទ្ធិសម្រេចទេ។ ព្រោះការសម្រេចដូចខ្ញុំលើកខាងដើមថា ពីលើមកតែម្ដង ថាដូចខ្ញុំជម្រាបថា កា.ហ្សេ.បេ និង សេ.អ៊ឺ.អា កម្មេចទាំងអស់។ សូមជម្រាបប៉ុណ្ណឹង។

**ស៖** ឥឡូវខ្ញុំចង់សួរសំណួរមួយចំនួនអំពីហេតុការណ៍ ដែលលោកបានរៀបរាប់យ៉ាងច្រើនជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។ ប្រហែលជា១សប្ដាហ៍ ឬ២សប្ដាហ៍ក្រោយពីលោកទៅដល់ស្រុកក្រូចឆ្មារ តើមានហេតុការណ៍មួយដែលមានប្រជាជននៅក្នុងឃុំមួយនោះងើបបះបោរ <ឬ>ងើបវាយបក<បក្ស>វិញ<ទេ>? បើមានការបះបោរបែបនេះមែន តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបានទេ ថាប្រជាជនហ្នឹង <បានធ្វើអ្វីខ្លះ>? ហើយមានអ្វីកើតឡើងទៅដល់អ្នកបះបោរទាំងនោះ?

[១៤:១៧:៣១]

**ឆ៖** បាទ កាលហ្នឹងមិនមែនប្រជាជនទេលោក គឺកងចល័តបះបោរ ខ្ញុំមិនបានទៅឃើញទេ ប៉ុន្តែសុទ្ធក្មេងៗ ប្រហែលអាយុ១៧, ២០ជាងអីហ្នឹង សុទ្ធតែក្មេងៗទេ មកហ្នឹង ដល់ពេលនេះ។

**ស៖** <>តើ<>យុវជន<ក្មេងៗដែល>នៅក្នុងកង<ចល័ត>ហ្នឹង <ពួក>គេបានធ្វើអ្វី<ខ្លះ> ដែរ?

**ឆ៖** បាទ តាមខ្ញុំដឹងពីបង គាត់ថា ពួកហ្នឹងដូចជាដាច់ខ្សែ ដាច់ខ្សែពីព្រៃហ្នឹងមកដល់ ដូចជាម៉េច នាំគ្នាប្រជុំគ្នា បះបោរបណ្ដោយ។ ដល់អ៊ីចឹងទៅ ធម្មតាទេនៅក្នុងរបបនោះ តែប្រឆាំងទោះជាសាច់ញាតិ គ្មានភ័ន្តភាំងដែរ កម្មេចឲ្យចេញ កុំឲ្យសល់ម្នាក់។ ខ្ញុំសូមជម្រាបប៉ុណ្ណឹងថា នៅក្នុងរបបហ្នឹង គឺអ៊ីចឹងតែម្ដង។

**ស៖** ដូច្នេះ សូមលោកជម្រាបជូនតុលាការបន្តិចមើល តើគេចាត់ការយ៉ាងម៉េចដែរ ជាមួយនឹងយុវជននៅក្នុងកង<ចល័ត>ដែលងើបរើបម្រះហ្នឹង? <ហើយតើជាបញ្ជារបស់នរណាដែរ>?

**ឆ៖** បាទ យុវជនទាំងអស់ហ្នឹង គឺគេយកទៅកន្លែងមួយ ហើយគេបោសសម្អាតទាំងអស់លោក។

**ស៖** <ពាក្យថា> "បោសសម្អាត" ហ្នឹង <តើលោកចង់>មានន័យថា <អ្នកទាំងនោះត្រូវបានគេ>សម្លាប់ចោល<មែនទេ>?

**ឆ៖** បាទ លោក។

**ស៖** ហើយចុះអ្នកណាជាអ្នកសម្រេចថា យុវជនទាំងអស់ហ្នឹងត្រូវតែយកទៅសម្លាប់ចោល? ហើយតើការបញ្ជានេះ <បញ្ជូនត>មកលោក<ដោយរបៀបណា>?

**ឆ៖** បាទ ខាងភូមិភាគបញ្ជាមក ប៉ុន្តែភូមិភាគ បែបខាងលើមកបញ្ជាមកភូមិភាគ ភូមិភាគបញ្ជាមកតំបន់ តំបន់បញ្ជាមកស្រុក ស្រុកប្រាប់ទៅឃោធា ឃោធាគេដោះស្រាយ។

[១៤:២០:១៤]

**ស៖** នៅក្នុងចម្លើយរបស់លោកឆ្លើយជូនសហចៅក្រមស៊ើបអង្កេតលោកថាមានសេចក្ដីណែនាំជាលាយលក្ខណ៍អក្សរ សរសេរជាអក្សរប៊ិកក្រហម។ លោកចាំទេ ការបញ្ជាជាលាយលក្ខណ៍អក្សរដែលសរសេរជាប៊ិកក្រហមនេះ ចេញដោយអ្នកណា អ្នកណាជាអ្នក<ចុះហត្ថលេខា និង>ចេញបញ្ជាសរសេរជាអក្សរពណ៌ក្រហមនេះ?

**ឆ៖** បាទ បញ្ជាចេញមកពីភូមិភាគ បញ្ជាមកពី រិន លេខាតំបន់ដែលគាត់បញ្ជាមក។

**ស៖** តើគេឃុំខ្លួនមនុស្សទាំងនេះនៅកន្លែងណា? ហើយយកទៅសម្លាប់ចោលនៅកន្លែងណា? ហើយនៅពេលដែលគេឃុំខ្លួនមនុស្សហ្នឹង លោក<ផ្ទាល់>មានបានទៅមើល<កន្លែងឃុំខ្លួននោះ>ទេ?

**ឆ៖** បាទ ខ្ញុំបាទបានទៅមើលនឹងគេដែរ។ ទៅឃើញនៅកន្លែងមួយដូចសាលាដូចអីអ៊ីចឹង គ្រាន់តែអើតទៅឃើញ ក៏ខ្ញុំត្រឡប់មកវិញ។

**ស៖** លោកបានឆ្លើយនៅក្នុងកិច្ចសម្ភាសន៍នេះផងដែរថា កន្លែងនេះគឺនៅលើកោះមួយ ប៉ុន្តែលោកភ្លេចឈ្មោះកោះហ្នឹងទៅហើយ។ ឥឡូវអ្វីដែលខ្ញុំចង់ដឹងហ្នឹង កោះដែលលោក<បានធ្វើដំណើរទៅហើយ>គេយកមនុស្សទៅឃុំហ្នឹង <តើវា>ជាកោះនៅខាងលិចស្រុកក្រូចឆ្មារ ឬជាកោះនៅខាងជើង<>ស្រុក លោកចាំទេ?

**ឆ៖** បាទ អត់ចាំទេលោក។ ខ្ញុំដូចជាមិនស្គាល់ស្រុកគេច្បាស់ផង។

[១៤:២២:៤០]

**ស៖** លោកដឹងទេថា មនុស្សទាំងនេះត្រូវបានសម្លាប់ដោយរបៀបណា? អ្នកណាជាពេជ្ឈឃាដ?

**ឆ៖** បាទ យកសំបុត្រទៅហ្នឹង យកទៅឲ្យកងទ័ពគេនៅហ្នឹង។ កងទ័ពមានកងទ័ពខាងមជ្ឈិមផង កងទ័ពស្រុកដែលរៀបនៅស្រុកក្រូចឆ្មារបានខ្លះៗ រើសពីឃុំអីមកហ្នឹង ចូលរួមទាំងអស់គ្នានៅនឹងកន្លែងនោះឯង។

**ស៖** ពេលលោកនិយាយថា កងទ័ពមជ្ឈិម លោកសំដៅទៅលើអ្នកណា? ទាហានទាំងអស់នេះមកពីណា? ហើយបើថាទាហានមជ្ឈិមអីចឹង អីចឹងទាំងអស់នេះស្ថិតនៅក្រោមការបញ្ជារបស់អ្នកណា?

**ឆ៖** បាទ ទាហាននេះបញ្ជារបស់ សុន សេន។ ការគ្រប់គ្រងកងទ័ពពិសេសហ្នឹងគឺដោយ គង់ ហៅ រ៉ន។

**ស៖** រ៉ន ជាអ្នកណាលោក?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

**លោក បាន សៀក៖**

**ឆ៖** រ៉ន ហ្នឹងឈ្មោះពីរ ឈ្មោះ គង់ ផង ឈ្មោះ រ៉ន ផង។ គាត់ជាប្រធានកងពិសេសរបស់អ៊ំខៀវ ផ្ទាល់ ហៅកងមជ្ឈិម សម្រាប់ការពារភូមិភាគ តំបន់ ស្រុកអី ការពារសន្តិសុខនៅខាងក្នុងផ្ទៃប្រទេស អត់ទៅវ៉ៃព្រំដែនទេ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ខ្ញុំសូមសួរបញ្ជាក់ឲ្យច្បាស់បន្តិច ពេលលោកប្រើឈ្មោះថា "ខៀវ, បងខៀវ" នេះលោកនិយាយសំដៅទៅលើអ្នកណា?

**ឆ៖** បាទ គឺ សុន សេន។

[១៤:២៥:១៨]

**ស៖** លោកបានឆ្លើយពីខាងដើមថា កិច្ចប្រជុំដែលលោកបានចូលរួមនេះ គឺជាកិច្ចប្រជុំមួយដឹកនាំដោយ សុន សេន។ សូមលោកជម្រាបជូនតុលាការថា កិច្ចប្រជុំហ្នឹងគេប្រារព្ធធ្វើនៅកន្លែងណា? អ្នកណាចូលរួម? ហើយ សុន សេន និយាយអ្វីខ្លះដែរ?

**ឆ៖** បាទប្រជុំនៅកន្លែងភូមិភាគ។ ភូមិភាគហ្នឹងចល័តដែរ ចល័តដូចនៅក្នុងចម្ការកៅស៊ូ។ នៅហ្នឹងមានតំបន់ ប្រធានស្រុក ទៅប្រជុំហ្នឹង រៀនសូត្រហើយ បានដាក់ផែន។ ទី១ ផែនការប្រមូលប្រជាជនដើម្បីទៅការដ្ឋាន។ ទី២ ប្រមូលជ្រើសរើសកងទ័ពទៅសមរភូមិមុខ។

**ស៖** លោកក៏បានបញ្ជាក់នៅក្នុងចម្លើយរបស់លោកជូនចៅក្រមស៊ើបអង្កេតថា <ការប្រជុំធ្វើឡើងនៅស្នួង> តើ<ស្នួងហ្នឹងជាកន្លែងដែលមាន>ចម្ការកៅស៊ូ<មែនទេ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះពី>ចម្ការកៅស៊ូ<ដែលគេធ្វើការប្រជុំ>ហ្នឹង <តើ>វានៅក្នុងទឹកដីភូមិណា ឃុំណា ស្រុកណា

តំបន់ណា?

**ឆ៖** អាហ្នឹងហៅថាតំបន់ហៅថាតំបន់ត្បូងឃ្មុំ នៅកន្លែងតំបន់ត្បូងឃ្មុំ ស្រុកត្បូងឃ្មុំ ពីដើមអត់មានខេត្តទេ។ ស្រុកត្បូងឃ្មុំ ហើយនិងចម្ការកៅស៊ូ ហៅថាចម្ការកៅស៊ូជប់។

**សៈ** នៅក្នុងកិច្ចប្រជុំនេះ តើ សុន សេន មានបាននិយាយអំពីការបោសសម្អាតខ្មាំងដែរឬទេ? ហើយបើគាត់និយាយពីបោសសម្អាតខ្មាំង គាត់មាននិយាយអីលម្អិតបន្ថែមខ្លះ?

**ឆ៖** បាទ គាត់និយាយពីខ្មាំងផ្ទៃក្នុង។ ខ្មាំងផ្ទៃក្នុងគឺ សេ.អ៊ី.អា និង កា.ហ្សេ.បេ។ ជាពិសេសត្រូវរើសទ័ពឲ្យបានល្អ កុំឲ្យមានខ្សែបង្កប់នៅក្នុងផ្ទៃក្នុង នាំឲ្យបរាជ័យ។ ដូច្នេះពេលនោះ សភាពការណ៍វាទុំហើយ វាធ្វើអីមិនកើតទេ។

[១៤:២៨:១៣]

**សៈ** ខ្ញុំសូមសួរលោក<>ពាក់ព័ន្ធនឹងចម្លើយរបស់លោក <ក្នុងកិច្ចសម្ភាសន៍ដែលនិយាយពីការប្រជុំនេះ។> នៅក្នុងឯកសារ E3/375, ERN ជាភាសាខ្មែរ <00348796> ដល់ 97, អង់គ្លេស 00360756, បារាំង 00369919 គឺឯកសារ E3/375។ លោក<ចាប់ផ្ដើមដោយ>រៀបរាប់ថាកិច្ចប្រជុំនេះ <ដូចអ្វីដែលលោកបានជម្រាបជូនអង្គជំនុំជម្រះ គឺកិច្ចប្រជុំដែល>បានរៀបចំឡើង<ដោយ អ៊ំខៀវ> និយាយអំពីការបោសសម្អាត <ហើយលោកបានផ្ដល់ចម្លើយដូចតទៅ>។ "សួរ៖ តើ<>ប្រជាជនប្រភេទណាដែលត្រូវបានចាត់ទុកថាជាសមាសភាពមិនល្អ? ឆ្លើយ៖ ប្រជាជនថ្មីត្រូវចាត់ទុកថាជាសមាសភាពមិនល្អ។ ប្រជាជនភាគច្រើនធ្វើការនៅការដ្ឋានការងារ គឺត្រូវបានខ្ញុំព្រមានកុំឲ្យនិយាយច្រើនពេក។ មាគ៌ាការងារអ្វីគឺថាយើងត្រូវធ្វើអ៊ីចឹង។ ហើយបើ<ធ្វើអ្វីខុស>ពីមាគ៌ាបក្ស យើង<គឺជា>ខ្មាំង។" <អ្វីដែលខ្ញុំចង់ឲ្យលោកឆ្លើយបំភ្លឺនោះគឺ> តើ សុន សេន ឬដែល<ជាអ្នក>និយាយថា ប្រជាជនថ្មីត្រូវបានចាត់ទុកថាជាសមាសភាពមិនល្អ? ហើយ<តើគាត់បានពន្យល់ថា>ហេតុអ្វីបានជាគេចាត់ទុកប្រជាជន<ថ្មី>ថាជាសមាភាពមិនល្អ?

**ឆ៖** បាទ ការទៅប្រជុំហ្នឹងអត់ដាក់ប្រជាជនថ្មីទេ ដាក់សមាសភាពខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង កា.ហ្សេ.បេ និង សេ.អ៊ី.អា ប៉ុន្តែនៅក្នុងបូព៌ា គេហៅ កា.ហ្សេ.បេ។ ដូច្នេះ អ្នកប្រឆាំងគេហៅថា កា.ហ្សេ.បេ ផ្អែបម្រើយួន។

[១៤:៣០:២០]

**សៈ** សូមសួរសំណួរទូទៅពីរបីសំណួរ អំពីប្រជាជនចាមនៅក្នុងស្រុកក្រូចឆ្មារ នៅពេលដែល

លោកនៅទីនោះ តើមានប្រជាជនចាមរស់នៅក្នុងស្រុកក្រូចឆ្មារច្រើនដែរទេ? ហើយបើមាន តើចាមទាំងនោះរស់នៅក្នុងភូមិឃុំអ្វី? រស់នៅត្រង់ផ្នែកណានៃទឹកដីស្រុកក្រូចឆ្មារ?

**ឆ៖** បាទ ខ្ញុំមិនចាំបានថានៅកន្លែងណា ព្រោះទៅការដ្ឋានហ្នឹង ក៏បងប្អូនចាម គាត់ទៅការដ្ឋានដែរ។ ដូច្នេះមិនដឹងថា គាត់នៅភូមិណា អីភូមិណាទេ។

**ស៖** នៅពេលដែលគេចាត់តាំងឱ្យលោកទៅធ្វើជាលេខាស្រុកក្រូចឆ្មារ តើគេមានប្រាប់លោកអំពីជនជាតិចាមនៅក្នុងស្រុកនោះទេ? ជាពិសេស តើគេមាន<ប្រាប់>លោកអំពីការងើបឡើងបះបោរ<ពីរលើក របស់ប្រជាជនចាមដែលបានកើតឡើងនៅ>ក្នុងឆ្នាំ១៩៧៥នោះ?

**ឆ៖** បាទ ខាងលើអត់មាននិយាយអំពីបងប្អូនខ្មែរអ៊ីស្លាមទេ ព្រោះកាលណោះ និយាយម៉េចនឹងកើត ព្រោះសភាពការណ៍អ៊ីចឹង មានតែបង្រួបបង្រួមគ្នា និយាយអំពី ជា ស៊ីម និង ហេង សំរិន ក្បត់ត្រូវតែតស៊ូវាយពួកក្បត់ដែលទៅចូលខ្ញុំយួន។

**ស៖** លោកសាក្សី នៅពេលដែលការិយាល័យសហចៅក្រមស៊ើបអង្កេតសម្ភាសលោក គេសម្ភាសនៅខែកុម្ភៈ ២០០៩ គឺឯកសារ E3/5275, ERN ជាភាសាខ្មែរ <00282921>, អង់គ្លេស 00284493, បារាំង 00339918។ នៅក្នុងកិច្ចសម្ភាសន៍លើកដំបូងនេះ គេសួរលោកថា៖ "តើលោកធ្លាប់ធ្វើលេខាស្រុកក្រូចឆ្មារដែរទេ?" ហើយនេះលោកឆ្លើយទៅនឹងសំណួរនៅពេលនោះថា យ៉ាងដូច្នេះ សូមដកស្រង់៖ "ខ្ញុំមិនធ្លាប់ដែលធ្វើការនៅក្នុងស្រុកក្រូចឆ្មារទេ ខ្ញុំមិនដែលមានតួនាទីជាលេខាស្រុកអីទេ ហើយខ្ញុំក៏មិនដែលបានទៅមើលមន្ទីរស្រុកអីដែរ។ ជាមួយពួកចាម ខ្ញុំមិនដែលទាក់ទងអីទេ នៅពេលនោះ។ ខ្ញុំមិនដែលមានជម្លោះជាមួយអ្នកណាទេ។ ខ្ញុំមិនដែលឮអំពីការបោសសម្អាតចាមទេ។ ខ្ញុំមិនដែលឃើញគេចាប់ចងមនុស្សយកទៅសម្លាប់ចោលទេ។" បញ្ចប់ការដកស្រង់។

[១៤:៣៣:៤១]

ពាក់ព័ន្ធទៅនឹងភាពត្រឹមត្រូវនៅក្នុងកិច្ចសម្ភាសន៍<បន្ទាប់របស់លោក គឺ>លោកបានទទួលស្គាល់តួនាទីរបស់លោកនៅក្នុងស្រុកក្រូចឆ្មារ ហើយខ្ញុំនិយាយពីបញ្ហាមួយចំនួនដែលបានកើតឡើងនៅក្នុងស្រុកនេះ។ ឥឡូវខ្ញុំសូមផ្តល់ឱកាសឱ្យលោកពន្យល់អំពីសម្រង់ដែលខ្ញុំអានជូនលោកអម្បាញ់មិញនេះ ហេតុអីបានជាលោកមិននិយាយប្រាប់ការពិត អំពីតួនាទីរបស់លោកនៅស្រុកក្រូចឆ្មារ នៅពេលដែលមន្ត្រីស៊ើបអង្កេតនៃសហចៅក្រមស៊ើបអង្កេតសម្ភាសលោកលើកដំបូងនោះ? ហេតុអីក៏លោកមិនឆ្លើយឱ្យបានស្មោះត្រង់?

**ឆ៖** បាទ កាលណោះ ខ្ញុំយល់ថា ខ្ញុំទៅធ្វើការស្រុកក្រូចឆ្មារ វាខ្លីពេក នឹងរៀបរាប់អំពីការទៅអំពីការគេសម្លាប់ប្អូន ហើយខ្លួនត្រឡប់មកវិញ។ ដូច្នេះគិតថា អាហ្នឹងវាទុកជារួចគ្នាទៅចុះ ដោយក្នុងដំណាក់កាល ខ្ញុំគិតថា មិនឆ្លើយទេ ព្រោះកាលណោះ វាមានបញ្ហាផ្ទាល់ខ្លួនផង និងបញ្ហាជារួមផង។

**ស៖** លោកសាក្សី ហេតុផលមួយក្នុងចំណោមហេតុផលជាច្រើន គឺនៅក្នុងកិច្ចសម្ភាសន៍លើកទី១ របស់លោក លោកបានបដិសេធថា លោកមិនដែលធ្វើជាលេខាស្រុកក្រូចឆ្មារទេ ហើយលោកមិនដែលដឹងអ្វីដែលកើតឡើងក្នុងស្រុកនោះទេ។ <លោកមិនចង់និយាយអំពីរឿងអាក្រក់ៗដែលគ្រប់គ្នា> មិនចង់<>រំឭក <និងមិនចង់និយាយ>រឿងហ្នឹងឡើងវិញ តើត្រឹមត្រូវទេ បើខ្ញុំនិយាយថា យ៉ាងដូច្នេះ?

[១៤:៣៥:៣៤]

**ឆ៖** បាទ ដល់បច្ចុប្បន្ន ថាត្រឹមត្រូវទេ ក៏ប៉ុន្តែពេលនោះ ខ្ញុំយល់ថា ការទៅធ្វើហ្នឹងវាខ្លី ហើយមានការបោសសម្អាតប្អូនសម្អាតអីទៅ ខ្ញុំថា មិនលើកឲ្យមានបញ្ហាវែងឆ្ងាយទេ។ ហើយកាលនោះ ក៏មិត្តភក្តិដែលធ្វើការ អ្នកតស៊ូទាំងអស់ថា កុំចេះច្រើនពេក ចេះច្រើនពេកវានាំតែវាមានរឿងតទៅទៀតទេ។ ដូច្នេះត្រង់ណា គួរមិននិយាយ យើងកុំនិយាយ បាទៗ។

**លោក ឌេល លីសាក់៖**

ឥឡូវនេះ ខ្ញុំសួរសំណួរមួយចំនួនពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍<ទាំងនោះ>នៅ<ភូមិ>ទ្រា។

លោកប្រធាន ខ្ញុំត្រូវដល់ពេលចូលទៅប្រធានបទថ្មី <ខ្ញុំអាចបន្តសំណួរទៀត> ប៉ុន្តែមើលទៅឃើញថា <>ដល់ពេលល្មមសមសម្រាកហើយ តើគួរឲ្យខ្ញុំបន្ត ឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះក៏សមពេលសម្រាកដែរហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីខ្ទះប្រាំនាទី សូមបញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក និង ឲ្យអញ្ជើញគាត់រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបីខ្ទះប្រាំនាទី។

បាទ សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៧ នាទី ដល់ម៉ោង ១៥:០០ នាទី)*

[១៥:០០:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** បាទ លោកសាក្សី ខ្ញុំចង់និយាយអំពីព្រឹត្តិការណ៍មួយចំនួនដែលកើតមានឡើងនៅភូមិទ្រា។ តើលោកមានដឹងពីព្រឹត្តិការណ៍មួយដែលកើតឡើងនៅភូមិទ្រាដែរឬទេ ដែលនៅពេលនោះមានជនជាតិចាមជាច្រើនដែលត្រូវបានគេសម្លាប់?

**លោក បាន សៀក៖**

**ឆ៖** បាទ ខ្ញុំបាទអត់ដឹងទេ ព្រោះពេលនោះដូចខ្ញុំបាននិយាយថា មួយរយៈនោះខាងលើហៅទៅរៀន។ ដល់ត្រឡប់មកវិញ ខ្ញុំទៅការដ្ឋាន ហើយដូច្នេះមិនបានដឹងទេ។

**ស៖** តើលោកមានបានឃើញសាកសពអណ្តែតក្នុងទន្លេមេគង្គ ហើយដែលមានសាកសពមួយចំនួននោះ ត្រូវបានគេកាត់ក្បាលទៀតផង?

**ឆ៖** បាទ ឃើញលោក។

**ស៖** លោកសាក្សី តើលោកឃើញព្រឹត្តិការណ៍នុំងនៅពេលណាដែរ?

**ឆ៖** បាទ នៅពេលដែលខ្ញុំជិះកាណូត ឃើញ។

[១៥:០២:១០]

**ស៖** ឥឡូវខ្ញុំសូមដកស្រង់កំណត់ហេតុស្តាប់ចម្លើយរបស់លោកមួយ គឺឯកសារ E3/375, ERN ជាភាសាខ្មែរគឺ <00348804>, ភាសាអង់គ្លេសគឺ 00360763, ជាភាសាបារាំងគឺ 00369926 ។ "សំណួរ៖ នៅពេលដែលលោកនៅក្នុងគណៈ<>ស្រុកក្រូចឆ្មារនោះ តើលោកធ្លាប់ឮគេនិយាយអំពី<ការកម្ទេច>ក្រុមស្ត្រី<>ដែលត្រូវបានគេកាត់ក្បាលនៅភូមិទ្រា ស្រុកក្រូចឆ្មារ? ចម្លើយ៖ ខ្ញុំដឹងថាមានការសម្លាប់បែបហ្នឹងមែននៅក្នុងភូមិទ្រា ក៏ប៉ុន្តែខ្ញុំមិនដឹងថាអ្នកទាំងអស់នោះជាបុរស ឬក៏ស្ត្រីនោះទេ អ្នកដែលត្រូវបានគេសម្លាប់នោះ។" អ៊ីចឹងលោកសាក្សី ខ្ញុំចង់សួរលោកសាក្សីថា តើលោកដឹងថាមានការកាប់សម្លាប់មនុស្សនៅក្នុងភូមិទ្រានេះតាមរបៀបណាដែរ?

**ឆ៖** បាទ តាមមិត្តយើងដែលគេប្រាប់ថា មានការសម្លាប់ពួក ស្លាប់ហ្នឹងដែលថា តែពួកដែល

បះបោរហ្នឹង គេប្រាប់ថាសម្លាប់ ប៉ុន្តែដឹងគេសម្លាប់កន្លែងណា ខ្ញុំមិនបានដឹងទេ។

**ស៖** តើអ្នកណាជាអ្នកចេញបញ្ជាឲ្យសម្លាប់មនុស្សនៅក្នុងភូមិទ្រានេះ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ!

**លោក បាន សៀក៖**

**ឆ៖** បាទ កាលនោះ បញ្ជាតែម្តងទេ ពេលដែលបះបោរហ្នឹង។ រាយការណ៍ទៅលើ ខាងលើឲ្យលិខិតមកវិញហ្នឹង ក៏បញ្ជូនទៅខាងកងទ័ពហ្នឹង។ អាហ្នឹងដូចខ្ញុំជម្រាបថា គេថាឲ្យតែពួកបះបោរ សុទ្ធតែពួក កា.ហ្សេ.បេ។

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** ពីរបីនាទីមុននេះ លោកបាននិយាយថា លោកឃើញសាកសពនៅក្នុងទន្លេនៅពេលដែលលោកជិះកាណូត។ តើលោកអាចជម្រាបជូនតុលាការបានដែរឬទេថា នៅពេលណាដែរ? <ហេតុអ្វីបានជាលោកជិះកាណូត?> ហើយលោកកំពុងធ្វើអីដែរនៅពេល<>ដែលឃើញសាកសព<អណ្តែតនៅក្នុងទន្លេមេគង្គ>ហ្នឹង?

[១៥:០៥:០៨]

**ឆ៖** ពេលជិះកាណូតហ្នឹង គឺថាពេល ពួកយើងមិនហ៊ានឡើងគោកជិតៗទេ ជិះឆ្ងាយអ៊ីចឹងគ្រាន់ជិះប្រយ័ត្នប្រយែង ព្រោះកាលហ្នឹង ខាងកងឈ្លប គេបានបាញ់អនុស្រុកម្នាក់ របួសធ្ងន់ទៅហើយ ដូច្នេះគ្រាន់តែយើងមិនហ៊ានជិះម៉ូតូជិះអីតាមផ្លូវ យើងជិះកាណូតតាមទឹក។

**ស៖** លោកសាក្សី ខ្ញុំសូមអានសម្រង់ចម្លើយរបស់កូន កែ ពក ឈ្មោះ កែ ពេជ្រវណ្ណៈ។ ខ្ញុំសូមដកស្រង់កំណត់ហេតុស្តាប់ចម្លើយរបស់គាត់<ឆ្លើយជូនការិយាល័យសហចៅក្រមស៊ើបអង្កេត> គឺឯកសារ E3/35, ERN ជាភាសាខ្មែរគឺ 00340569 ដល់70, ជាភាសាអង់គ្លេសគឺ 00346155, ជាភាសាបារាំងគឺ 00367727។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់គាត់នេះ កូន<ប្រុស> កែ ពក ពិពណ៌នាដូចតទៅនេះ គឺគាត់និយាយអំពីពេលវេលាដែលកងពល<>មជ្ឈិម<ដែលស្ថិតក្រោមដឹកនាំរបស់ សុន សេន បាន>មកដល់ ដើម្បីបោសសម្អាតនៅភូមិភាគបូព៌ា ហើយ<ឪពុករបស់>គាត់ត្រូវបានគេកោះហៅទៅប្រជុំជាមួយ ប៉ុល ពត។ “នៅពេលដែលឪពុកខ្ញុំត្រឡប់មកវិញ ខ្ញុំសួរគាត់ថា មានរឿងអីកើតឡើង? គាត់និយាយថា រឿងនេះចម្លែកណាស់ ព្រោះថា បងប៉ុល ពត នោះឃើញមានសាកសពអណ្តែត

នៅមុខមន្ទីររបស់គាត់ ហើយបងក៏បានបញ្ជាឲ្យចុះស្រាវជ្រាវរឿងនេះជាបន្ទាន់។ ពេលដែលឪពុកខ្ញុំត្រឡប់មកដល់ផ្ទះវិញ គាត់បានចេញបញ្ជាឲ្យប្រធានកងពលម្នាក់ឈ្មោះ សមមិត្ត ឆាយ នាំក្រុមស៊ើបអង្កេតរឿងសាកសពដែលអណ្តែតទឹកនោះ។ ហើយលទ្ធផលនៃការស៊ើបអង្កេតហ្នឹង ឃើញថាពួកចាមហ្នឹង ត្រូវបានគេចាប់ខ្លួន ហើយដាក់នឹងកាណូត រួចហើយកាត់ក្បាលមុននឹងបោះទម្លាក់ចូលទៅក្នុងទឹកទន្លេ។ ព្រឹត្តិការណ៍នេះកើតឡើងនៅក្នុងស្រុកក្រូចឆ្មារ នៅទល់មុខស្រុកស្ទឹងត្រង់។ <កងអន្តរាគមន៍> ចេញមកពីមជ្ឈិមដឹកនាំដោយ ពីន ដែលបាន<ជាប់ពាក់ព័ន្ធនឹងការសម្លាប់>នេះ។ បន្ទាប់ពីទទួលបានលទ្ធផលនេះ ឪពុកខ្ញុំបានផ្ញើ ធ្វើរាយការណ៍ទៅមន្ទីរ ម-៨៧០។” ហើយទំព័របន្ទាប់ទៀតនេះ គឺនៅក្នុងកំណត់ហេតុស្តាប់ចម្លើយដដែល សរសេរថា៖ “ភូមិភាគបានផ្ញើរបាយការណ៍ទៅថ្នាក់លើ ទាក់ទងទៅនឹងការបោសសម្អាត<ប្រជាជន>អ៊ីស្លាមនៅក្រូចឆ្មារនេះ។ អាស្រ័យដូចនេះហើយ បានឃើញមានសាកសពអណ្តែតនៅក្នុងទន្លេ។” លោកសាក្សី ខ្ញុំចង់សួរលោក ថាតើលោកមានដឹង <ឬធ្លាប់ឮ>អំពីហេតុការណ៍ដែលពិពណ៌មានដោយកូន<ប្រុស>របស់ កែ ពក នេះទេ?

[១៥:០៨:៤៦]

**ឆ៖** បាទ កូន កែ ពក នេះជាក្មួយថ្លៃរបស់ខ្ញុំបាទដែរ ក៏ប៉ុន្តែគាត់ បើតាមខ្ញុំស្គាល់គាត់ គាត់មិនដែលសួរចុះមកភូមិទេ ព្រោះគាត់ដើរតាមឪពុកគាត់។ ដូច្នេះ ខ្ញុំមិនដឹងថា គាត់ដឹងរឿងអីខ្លះទេ ព្រោះដើរតាមឪពុកគាត់ជាប់រហូត ជាកងការពារឪពុកគាត់។ ដូច្នេះ បញ្ហាទាំងអស់នេះ វាសំខាន់តែលើឪពុកគាត់ទេ ដែលដឹងរឿងទាំងអស់នៅក្នុងភូមិភាគបូព៌ាក្តី ភូមិភាគកណ្តាលក្តី។ ដូច្នេះគាត់ កែ ពក នេះគាត់ត្រូវតែទទួលបញ្ជាការយោធានៅប្រចាំភូមិភាគបូព៌ាផង ជាមួយ សុន សេន។

**ស៖** អ្វីដែលខ្ញុំទើបតែអានឲ្យលោកស្តាប់អម្បាញ់មិញនេះ គឺថា កូន កែ ពក បាននិយាយថា <វាជាកង>អន្តរាគមន៍ដែលចេញពីមជ្ឈិមដែលមាន <ពីន> ជាអ្នកដឹកនាំ ហើយបានចូលរួមក្នុងព្រឹត្តិការណ៍<សម្លាប់>នេះ។ តើលោកមានដឹងអំពីកងអន្តរាគមន៍<ពិសេស>មកពីមជ្ឈិមដែលដឹកនាំដោយ<សមមិត្ត ពីន> នេះទេ?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ទេ កងទ័ពមជ្ឈិមរបស់ <ពីន> ស្គាល់តែកងទ័ពមជ្ឈិមរបស់ វ៉ន ហៅ គង់។

**ស៖** <ផ្នែកមួយផ្សេងទៀតនៃបទសម្ភាសន៍ជាមួយកូនប្រុស កែ ពក> គឺឯកសារ E3/35, ERN ជាភាសាខ្មែរគឺ 00340568, អង់គ្លេសគឺ 00346154, ជាភាសាបារាំងគឺ 00367726។ នៅក្នុង

<ផ្នែកមួយនៃ>កំណត់ហេតុស្តាប់ចម្លើយ<>នេះ<> កូន<ប្រុសរបស់> កែ ពក <>បានកំណត់អត្តសញ្ញាណមេបញ្ជាការ<ដទៃទៀត>នៃ<កងពិសេសនេះ>។ គាត់និយាយថា៖ "សុន សេន បានចេញបញ្ជាឲ្យកងអន្តរាគមន៍ពិសេសដែលដឹកនាំដោយ តាពីន ហើយនិង តាវិន មកការពារ<អ្នកទាំងនោះ> និងបញ្ជាឲ្យទៅគ្រប់គ្រង<ទាំងស្រុងលើ>កងពលទាំងអស់ដែលគេបានបោសសម្អាតមេៗ។ តាវិន ជាកូនប្រសារ តាម៉ុក និងជាអនុរបស់ តាពីន។ តាញ៉ ជាប្រធានកងពលតូច ចំណុះឲ្យកងពលអន្តរាគមន៍របស់ តាពីន។" សំណួររបស់ខ្ញុំដូចតទៅនេះលោកសាក្សី តើលោកមានស្គាល់<នរណាខ្លះទេក្នុងចំណោម>ឈ្មោះមេបញ្ជាការ<យោធា>ទាំងអស់នេះដែលកូន កែ ពក បានរៀបរាប់ហ្នឹង<>? ដូចជាកូនប្រសាររបស់ តាម៉ុក ដែលមានឈ្មោះថា តាវិន ហើយនិងមេបញ្ជាការ<កងពលតូច>មួយទៀតឈ្មោះ តាញ៉ <>?

[១៥:១២:១៣]

**ឆ៖** បាទ ឈ្មោះ វិន ខ្ញុំបាទស្គាល់កាលពីផ្តាច់ខ្លួនទៅ -- កាលពីវៀតណាមចូលមកបានឃើញ វិន ថាកូនប្រសារ តាម៉ុក។ កាលហ្នឹងខ្ញុំស្គាល់ តាវិន ដែរ ឯ ញ៉ ខ្ញុំអត់ស្គាល់ទេ។

**ស៖** តើលោកដឹងថា តាវិន ហ្នឹងគាត់នៅក្នុងអង្គភាពណា ឬក៏កងពលណាដែរឬទេនៅក្នុងឆ្នាំ ១៩៧៨ ហ្នឹង?

**ឆ៖** បាទ វិន នោះជាអនុប្រធានយោធាមជ្ឈិម។ កាលនោះ ពីន ជាប្រធានយោធាមជ្ឈិម។

**ស៖** ព្រឹត្តិការណ៍មួយទៀតដែលខ្ញុំចង់សុំប្រតិកម្មពីលោក ព្រឹត្តិការណ៍នេះកើតឡើងនៅភូមិទ្រា គឺមានបុគ្គលម្នាក់ដែលខ្ញុំបាននិយាយពី<មុន>មកនោះគឺ សាក្សី <2-TCW-904 គឺជាចាម> ធ្វើការ<ជាស្មៀន>នៅឃុំមួយដែលមានភូមិទ្រានៅក្នុងហ្នឹង។ នៅក្នុងឯកសារ E3/5196, ERNជាភាសាខ្មែរគឺ 00204456, ERN ជាភាសាអង់គ្លេសគឺ 00223088, ជាភាសាបារាំងគឺ 00274740។ សាក្សីនេះបាននិយាយដូចតទៅនេះ ខ្ញុំសូមដកស្រង់៖ "មន្ទីរសន្តិសុខត្រូវបានបង្កើតក្នុងភូមិ<>ក្រោមការគ្រប់គ្រងរបស់ ហូ <>ដែល<ជា>ខ្មែរមកពីត្រើយម្ខាង<ទន្លេ ក្នុងភូមិភាគកណ្តាល។> ហើយគាត់ហ្នឹងជាអ្នក<ទទួល>ខុសត្រូវក្នុងការចាប់ខ្លួនចាមជាច្រើន។" នៅទំព័រដដែល គាត់<បានបន្តរៀបរាប់អំពី>រយៈពេលពីរសប្តាហ៍ ដែលក្នុងរយៈពេល<នោះ> ចាមត្រូវបានគេបញ្ជូនទៅភូមិទ្រា។ លោកសាក្សី ខ្ញុំសុំឲ្យលោកឆ្លើយតបទៅអ្វីដែលបានលើកឡើងដោយសាក្សីរូបនេះ។ ខ្ញុំសូមសួរលោកថាតើលោក<ផ្ទាល់មានសិទ្ធ>សេចក្តីសម្រេចឲ្យចាប់ជនជាតិចាមទាំងអស់នេះដែរឬទេ? ឬក៏ការសម្រេចចាប់ខ្លួននេះ ទាល់តែ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សម្រេចចេញមកពីតំបន់ ឬក៏ភូមិភាគ <ឬថ្នាក់មជ្ឈិម>ឯណោះ បានអាចធ្វើទៅបាន?

**ឆ៖** បាទ បញ្ហាហ្នឹងខ្ញុំបាទមិនបានដឹងច្បាស់ទេ ព្រោះដូចខ្ញុំបានជម្រាបខាងលើថា ខ្ញុំបាទរៀន ហើយទៅការដ្ឋាន រៀបចំកងទ័ព ប៉ុន្តែអាហ្នឹងកងទ័ពមជ្ឈិម កងទ័ពអី គេរៀបចំការបោសសម្អាត ការរៀបចំភូមិអី ព្រោះសភាពការណ៍វាទុំទៅហើយ។ ខ្ញុំសូមបញ្ជាក់បន្តិច ដូចកាលដែលគេដកខ្ញុំបាទមកភូមិភាគឧត្តរវិញហ្នឹង ប្រជាជន គេជម្លៀសប្រជាជនស្រុកក្រូចឆ្មារហ្នឹង ក៏មានផែនការទ័ពគេជម្លៀសដែរ ដោយថាគ្រប់គ្រងមិនបាន អ៊ីចឹងឯង។

[១៥:១៦:២៩]

**ស៖** លោកសាក្សី មានប្រធានបទពីរចុងក្រោយដែលខ្ញុំចង់ចោទសំណួរទៅកាន់លោក មួយគឺទាក់ទងទៅនឹងការប្រព្រឹត្តទៅលើជនជាតិវៀតណាម នៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យ។ តើលោកអាចរៀបរាប់ជូនតុលាការបានដែរឬទេថា កាលសម័យនោះ គេប្រព្រឹត្តយ៉ាងដូចម្តេចទៅលើជនជាតិវៀតណាម? ហើយមានរឿងអ្វីកើតឡើងខ្លះចំពោះជនជាតិវៀតណាម នៅពេលនោះ?

**ឆ៖** បាទ ខ្ញុំបាទ មិនបានដឹងទេ ប៉ុនគ្រាន់តែឮគេនិយាយថា វៀតណាមគេបោសសម្អាតតាមដងទន្លេសាប ហើយវៀតណាមដែលនៅផ្ទះជាមួយខ្ញុំបាទហ្នឹង ក៏គេយកទៅដែរ។

**ស៖** បាទ នៅពេលដែលលោកនិយាយអំពីជនជាតិវៀតណាម នៅតាមមាត់ទន្លេ ឬក៏តាមភូមិអីនោះ តើលោកអាចបញ្ជាក់ពីកន្លែងឲ្យបានច្បាស់លាស់បានដែរឬទេ លោកសំដៅទៅកន្លែងណាខ្លះ?

**ឆ៖** បាទ ដែលគេប្រាប់ហ្នឹង គឺកន្លែងសំរោងសែន តាមដងស្ទឹងហ្នឹង ពីទន្លេសាបមក មកដល់សង្ខាយហ្នឹងដែលមានប្រជាជនវៀតណាម គាត់រកស៊ីត្រី។

**ស៖** បាទ ខ្ញុំប្រហែលជា<សួរ>មិនច្បាស់ទេអម្បាញ់មិញ ឥឡូវខ្ញុំចង់សួរថា តើ<លោកចង់សំដៅទៅ>ឃុំណា ស្រុកណាដែរ? សំរោងហ្នឹងនៅឯណាដែរ<>?

**ឆ៖** បាទ សំរោងសែន គឺនៅខេត្តកំពង់ឆ្នាំង លោក។

**ស៖** តើលោកដឹងអំពីការសម្លាប់ជនជាតិវៀតណាម<>នៅក្នុងខេត្តកំពង់ឆ្នាំងហ្នឹង<ដោយរបៀបណា>?

[១៥:១៩:១៣]

**ឆ៖** បាទ តាមរយៈកងទ័ព ដែលមកគេថាវៀតណាមវាយទម្លាក់ទឹកអស់ហើយ។

**ស៖** បាទ ខ្ញុំសូមអានសម្រង់មួយនៃកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺឯកសារ E3/375

ERN ជាភាសាខ្មែរគឺ00348799, ជាភាសាអង់គ្លេសគឺ00360759 និងជាភាសាបារាំងគឺ 00369921 លោកបាននិយាយដូចតទៅនេះ៖ "សំណួរ៖ តើមានការបោសសម្អាតជនជាតិវៀតណាមដែរឬទេនៅពេលនោះ? ចម្លើយ៖ អ្នកដែលជាជនជាតិវៀតណាមត្រូវគេសម្លាប់ទាំងអស់។ ចំពោះការសម្លាប់នេះ ខ្ញុំមិនដឹងថា ជាគោលនយោបាយពីថ្នាក់លើដែរឬក៏អត់នោះទេ ប៉ុន្តែឲ្យតែជនជាតិយួនត្រូវបានគេសម្លាប់ទាំងអស់ សូម្បីតែខ្មែរភាគខាងជើង (កម្ពុជាក្រោម) ដែលត្រូវបានអប់រំដោយយួន <>ហើយត្រឡប់មកធ្វើជាកម្មាភិបាលខ្មែរក្រហមវិញនោះ ក៏ត្រូវបានគេយកទៅកម្ទេចចោលដែរ។" អ្វីដែលខ្ញុំចង់<បានការបំភ្លឺពីលោក> គឺថានៅក្នុងចម្លើយរបស់លោក<ដែលបានលើកឡើង>នេះ បើតាមសំណៅជាភាសាអង់គ្លេស ដែលខ្ញុំអាននោះ លោកនិយាយថា សូម្បីតែខ្មែរភាគខាងជើង ហើយឃើញនៅក្នុងវង់ក្រចកនេះសរសេរថា "កម្ពុជាក្រោម"។ ខ្ញុំចង់ឲ្យ -- ខ្ញុំចង់សួរលោកថា លោកចង់សំដៅទៅលើខ្មែរក្រោម ឬក៏លោកចង់និយាយថា សំដៅទៅលើកម្មាភិបាលខ្មែរដែលស្ថិតនៅ<ក្នុងបក្ស>ដែលបានទៅរៀនទទួលការអប់រំនៅប្រទេសវៀតណាម<ខាងជើង>? លោកចង់និយាយយ៉ាងម៉េចដែរចំណុចនេះ?

[១៥:២១:២៨]

**ឆ៖** បាទ តាមខ្ញុំដឹងនៅកន្លែងខ្ញុំហ្នឹង គឺមានកម្មាភិបាលខ្មែរហ្នឹង ដែលទៅរៀននៅប្រទេសវៀតណាម ដែលពីដើមហៅថា គេហៅថា គណបក្សពលករ។ ដល់អ៊ីចឹងទៅមកវិញ ដល់វៀតណាមចូលមក ពួកហ្នឹងបានមកធ្វើជាកម្មាភិបាល អប់រំកសាងកម្លាំងហ្នឹង។ ដល់តែពេលឆ្នាំ៧៣-៧៤ហ្នឹង ក៏ឮថា បងៗហ្នឹង គេបោសសម្អាតបណ្តើរៗអស់។

**សៈ** តើកម្មាភិបាលដែលបានទទួលការបណ្តុះបណ្តាលនៅប្រទេសវៀតណាមនេះ ត្រូវបានគេបោសសម្អាតនៅពេលណាដែរ?

**ឆ៖** តាមខ្ញុំចាំប្រហែលជាឆ្នាំ១៩៧៤-៧៥ -- ៧៣-៧៤ បាទមិនមែន៧៥ទេ ៧៣-៧៤។ កាលនោះ វៀតណាមក៏ត្រឡប់ទៅវិញ បងប្អូនកម្មាភិបាលហ្នឹងក៏ត្រូវគេបោសសម្អាត។ ខ្ញុំឮសួរគេថា ពួកខាងជើង ភាគខាងជើង ហៅ "ភាគជើងៗ" គេបោសសម្អាតទាំងអស់។

**លោក ឌេល លីសាក់៖**

បាទ សូមអរគុណលោកសាក្សីដែលបានឆ្លើយតបនឹងសំណួរខ្ញុំនៅពេលនេះ។ ខ្ញុំអស់សំណួរហើយលោកសាក្សី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

[១៥:២៣:៣៣]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី និងសាធារណជន ជាពិសេសដើមបណ្តឹងរដ្ឋប្បវេណី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំបាទ ឈ្មោះ ពេជ អង្គ ជាមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរមួយចំនួនសម្រាប់សួរលោកបន្តពីតំណាងសហព្រះរាជអាជ្ញា។ ជាបឋមខ្ញុំសូមលើកឯកសាររបស់លោក ដែលមានលេខ E3/375 ត្រង់ ERN ជាភាសាខ្មែរ 00348800, ភាសាអង់គ្លេស 00360759 ជាភាសាបារាំង 00369921 និងបន្តបន្ទាប់។ នៅក្នុងឃ្លានោះ ខ្ញុំសូមអានតែម្តង លោកឆ្លើយនឹងសំណួរមួយថា៖ "តើជនជាតិចាមត្រូវបានគេចាត់ទុកជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជាដែរឬទេ? លោកបានឆ្លើយថា៖ ខ្ញុំគិតថា មិនមែនជាសត្រូវរបស់បក្សកុម្មុយនីស្តកម្ពុជាទេ ប៉ុន្តែកាលនោះ ជនជាតិចាម គេមិនអនុញ្ញាតឲ្យមានការសូត្រធម៌នោះទេ។ សូម្បីតែព្រះសង្ឃក៏មិនមានដែរ។ ពេលនោះគ្រប់សាសនាទាំងអស់ត្រូវបានបំបាត់ចោល មានតែបក្សកុម្មុយនីស្តកម្ពុជាទេ ដែលត្រូវគោរព។ បក្សកុម្មុយនីស្តស្អប់ព្រះសង្ឃនិងស្តេចជាងគេ។" បញ្ចប់ការដកស្រង់។ ជាពិសេសពាក់ព័ន្ធទៅនឹងឃ្លាចុងក្រោយដែលនិយាយថា "បក្សកុម្មុយនីស្តស្អប់ព្រះសង្ឃ និងស្តេចជាងគេ" តើលោកមានហេតុផលអ្វីដែលលោកនិយាយថា "បក្សកុម្មុយនីស្តស្អប់ព្រះសង្ឃ និងស្តេចជាងគេ"? តើលោកអាចនិយាយពន្យល់អំពីបញ្ហានេះបានទេ?

[១៥:២៥:៣៦]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន យើងបានបង្កើតនីតិវិធីមួយហើយ គឺថាត្រូវចោទសំណួរទូទៅជាមុនសិន ហើយបន្ទាប់មកទៀត យើងអាចដកស្រង់កំណត់ហេតុស្តាប់ចម្លើយ<ដើម្បីមកតទល់ជាមួយ>សាក្សី។ តែឥឡូវនេះ លោកមេធាវី ពេជ អង្គ គាត់អានកំណត់ហេតុស្តាប់ចម្លើយ ហើយគាត់សុំការបញ្ជាក់ពីសាក្សីទៅវិញ។ អ៊ីចឹង ខ្ញុំមើលទៅឃើញថា ការអនុវត្តបែបនេះគួរតែត្រូវលុបចោលទៅលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ចំពោះសំណួរនេះ ពីព្រោះថាសាក្សីមិនមែនជាអ្នកជំនាញទេ ហើយគាត់មិនអាចផ្តល់នូវការពន្យល់អំពីខ្លឹមសារ ពីមូលហេតុដែលនាំឲ្យថា មានការស្អប់លោកសង្ឃ ឬក៏ជនជាតិចាមនោះទេ។ សូមអរគុណ។

[១៥:២៦:៤៥]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ឆ្លើយតបទៅនឹងអ្វីដែលលោក កូប៉េ បានលើក បែបបទមានពីរនៅក្នុងការលើកអំពីសម្រង់នេះ គឺបែបបទទី១ គឺការបញ្ជាក់ឲ្យសាក្សីបញ្ជាក់ទៅលើខ្លឹមសារនោះតែម្តងថាតើគាត់បាននិយាយយ៉ាងដូច្នេះ ឬក៏យ៉ាងណា។ ដូច្នេះចំណុចទី១ ដែលលោក កូប៉េ បានលើក គឺករណីបែបនេះ ក៏ប៉ុន្តែករណីខ្ញុំគឺមិនដូចគ្នាទេ គឺលើកអំពីឃ្លាដើម្បីឲ្យមានការពន្យល់បង្ហាញ ថាតើឃ្លានោះអ្វីដែលជាមូលដ្ឋានដែលគាត់ដែលចេញពីបទពិសោធន៍ ពីចំណេះដឹងផ្ទាល់របស់គាត់ ដែលគាត់និយាយថាយ៉ាងដូច្នេះ។ ហើយចំពោះការជំទាស់របស់លោក គង់ សំអុន គឺអ្វីដែលខ្ញុំបានលើកនេះ សំណួរខ្ញុំនេះគឺជាការសួរឲ្យគាត់ឆ្លើយទៅនឹង ពន្យល់បង្ហាញដោយលើកពីអំណេះអំណាងផ្សេងៗដែលជាបទពិសោធន៍ផ្ទាល់របស់គាត់។ ដូច្នេះ ខ្ញុំគិតថា វាមិនមែនជាបញ្ហាពាក់ព័ន្ធទៅនឹងលក្ខណៈរបស់គាត់ជាអ្នកជំនាញនោះទេ។ បាទ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់របស់មេធាវីទាំងពីរត្រឹមត្រូវ។ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ។

**សួរដោយលោក ពេជ អង្គ៖**

បាទ ខ្ញុំសូមបន្តទៅទៀត។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** លោកសាក្សី ថាតើតាមបទពិសោធន៍ផ្ទាល់របស់លោក ការដឹងឮរបស់លោក ថាតើគេធ្វើយ៉ាងដូចម្ដេចចំពោះព្រះសង្ឃ និងអ្នកដែលនៅក្នុងខ្សែរបស់រាជវង្ស? តើលោកបានដឹង បានឮអំពីបញ្ហាហ្នឹងទេ ពីបទពិសោធន៍របស់លោក?

[១៥:២៨:៤៩]

**លោក បាន សៀក៖**

**ឆ៖** បាទ ខ្ញុំបាទបានដឹងខ្លះៗដែរ ព្រោះថាស្ដេច និងព្រះសង្ឃនេះ ជាសត្រូវរបស់ខ្មែរក្រហមហើយ ព្រោះព្រះសង្ឃមិនឲ្យមាន ព្រោះចាំតែដើរសុំគេស្រាប់ៗនោះ គេឲ្យធ្វើការពលកម្ម។ ហើយស្ដេចអីចឹងដែរ ឲ្យមកធ្វើការពលកម្មនៅតាមស្រែដូចប្រជាជនកសិករ ហៅថាតស៊ូវណ្ណៈ លោក។

**ស៖** តើលោកមានធ្លាប់ចូលរួមប្រជុំ ឬក៏រៀនសូត្រណាមួយដែលលោកបានទទួលព័ត៌មានដែលលោកបាននិយាយអម្បាញ់មិញទេ ដែលគេនិយាយអំពីបញ្ហាដូចបាន ដូចលោកបានលើកអម្បាញ់មិញ?

**ឆ៖** ខ្ញុំបាទអត់បានរៀនទេ ក៏ប៉ុន្តែខ្ញុំបាទបាន កាលនោះគ្រួសារមានទម្ងន់ បានទៅកំពង់ចាម។ ទៅៗ ប្អូនប្រាប់ថានោះ សីហនុ គេដាក់ គេយកមកទុកនៅកំពង់ចាមហើយទាំងប្រពន្ធអីហ្នឹង ថាអីចឹង។ ដល់អីចឹង គេថាម៉េចបានយកស្ដេចមកទុកហ្នឹង? គេថា អ្ហ៎! បងឯងមិនដឹងទេអ្ហេះ? ស្ដេចហ្នឹងរាជវង្សហើយ ឲ្យទៅធ្វើស្រែធ្វើអីនោះ។ ខ្ញុំបាទបានដឹងអីចេះឯង។ ឯព្រះសង្ឃគឺគេផ្សឹក តែប្អូនខ្ញុំ គ្រូសង្ក្រាជដែលគេសម្លាប់ចោល ក៏គេផ្សឹកដែរ ផ្សឹក។ យកធ្វើទាហានហើយ សម្លាប់ចោលបណ្ដោយ។

**ស៖** តើលោកអាចបញ្ជាក់បានទេ ប្អូនរបស់លោកដែលត្រូវបានគេសម្លាប់ចោលហ្នឹង ឈ្មោះអ្វីដែរ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ!

**លោក បាន សៀក៖**

**ឆ៖** ឈ្មោះ អង់ ហុង ហៅ កុក។

[១៥:៣០:៣៤]

**សួរដោយលោក ពេជ អង្គ៖**

**ស៖** លោកអាចបញ្ជាក់ឆ្នាំបានទេ?

**ឆ៖** បាទ ឆ្នាំដែលកម្មេច គឺឆ្នាំមួយពាន់ប្រាំបួនរយ ចុងឆ្នាំហើយ ១៩៧៨ ចុងឆ្នាំហើយ ជិត

ឃ្លួនចូលហើយហ្នឹង គេកម្ទេចទៅ។ រួចដល់កម្ទេចទៅ សុន សេន បានហៅខ្ញុំទៅរៀន។ រៀនហើយ ឲ្យធ្វើប្រវត្តិរូបពិស្តារ។ គាត់ថា "មិត្តឯងកុហក ប្អូនមួយបក្សកម្ទេចហើយ ថាអត់។ ឥឡូវប្អូននេះ ឥឡូវគេកម្ទេចហើយ"។ រួចខ្ញុំបះជើងទៅក្រោយ ភ័យខ្លាំងពេក គាត់សម្លឹងមុខ ពាក់វ៉ែនតា។ គាត់ថា "កុំភ័យអីមិត្តឯងទៅនៅជាមួយ មិត្តអឿន, មិត្តប៉ូច វិញទៅ។ ហើយទៅប្រាប់កម្មាភិបាលថា កុំឲ្យភ័យ បក្សអត់កម្ទេចទេ ព្រោះមានរឿងធ្វើប្រវត្តិរូប ដាក់ថា បក្សកម្ទេច"។ កម្ទេចមែន ប៉ុន្តែដល់ប្រាប់អីចឹងទៅ គេកម្ទេចប្អូនមួយទៅ។ រួចខ្ញុំ គេឲ្យមកតំបន់៤២វិញទៅ។

**ស៖** បាទ ខ្ញុំសូមអរគុណច្រើន។ ខ្ញុំចូលទៅដល់ស្រុកក្រូចឆ្មារវិញ។ លោកនៅពេលដែលលោកនៅក្រូចឆ្មារហ្នឹង លោកបានធ្វើការអ្វីខ្លះ តើលោកអាចរៀបរាប់បានទេ នៅស្រុកក្រូចឆ្មារហ្នឹង?

**ឆ៖** បាទ ខ្ញុំបាទនៅស្រុកក្រូចឆ្មារ ទៅមុនដំបូង ដូចខ្ញុំបានរៀបរាប់ខាងលើ។ ទៅមុនដំបូង ប៉ះសភាពការណ៍ដែលបងប្អូនបះបោរ ថ្នាក់កងចល័ត។ ធ្វើការហើយ គ្រាន់តែរៀបធ្វើការនេះហើយ ខាងលើហៅទៅរៀន ហៅទៅរៀនហើយ បានឲ្យត្រឡប់មកវិញ ឲ្យទៅប្រមូលប្រជាជនទៅការដ្ឋានទៅអីទួលស្នួល ទៅកន្លែងដីទួល ដើម្បីបង្កបង្កើនផលហ្នឹង រៀបចំប្រមូលកងទ័ពទៅសមរភូមិមុខ។

[១៥:៣២:៣០]

**ស៖** លោកបានមានប្រសាសន៍អម្បាញ់មិញអំពីការដ្ឋាន តើការដ្ឋាននោះ ទីតាំងនៅកន្លែងណា លោកអាចបញ្ជាក់បានទេ នៅក្នុងឃុំអី?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ!

**លោក បាន សៀក៖**

**ឆ៖** បាទ នៅក្នុងឃុំទួលស្នួល ហៅ -- អាហ្នឹងចំការកៅស៊ូ ហៅ ឈូក។ នោះឯង កន្លែងនោះឯងមានទួល ទៅធ្វើចម្ការនោះឯង ដើម្បីដាំដំណាំបង្កបង្កើនផលឲ្យប្រជាជនបានហូប។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** តើលោកអាចបញ្ជាក់បានទេ អ្នកដែលលោកប្រមូលទៅធ្វើការដ្ឋានទួលស្នួលហ្នឹង មានសមាសភាពយ៉ាងណាខ្លះ មានខ្មែរ មានចាម ឬក៏ថាមានអ្នកផ្សេងពីហ្នឹងទៀតទេ លោកអាចបញ្ជាក់ពីរឿងហ្នឹងបានទេ?

**ឆ៖** បាទ បានឲ្យឃុំប្រមូលប្រជាជនទាំងអស់ដើម្បីទៅការដ្ឋាន ទាំងបងប្អូនខ្មែរអ៊ីស្លាម ទាំង

ខ្មែរយើងទាំងអស់ ទៅការដ្ឋានដើម្បីបង្កបង្កើនផល។ ជាពិសេសទិសរបស់ខាងលើ សំដៅទៅលើការប្រមូលប្រជាជន ដើម្បីក្តាប់ប្រជាជន ហើយដើម្បីរើសកងទ័ពទៅសមរភូមិមុខ។

**ស៖** តើលោកអាចជម្រាបបានទេ ប្រជាជនទាំងអស់នោះ ដែលត្រូវបានប្រមូលហ្នឹង មានគ្នាប៉ុន្មាននាក់ដែរ?

[១៥:៣៤:២២]

**ឆ៖** បាទ ទូទាំងស្រុក គ្រប់ឃុំទាំងអស់ទៅ ពេញតែវាល មីក្រូទ្រហឹង។

**ស៖** អ៊ីចឹងមានន័យថា មិនមានអ្នកផ្សេងដែលនៅ ស្ថិតនៅកន្លែងផ្សេង នៅក្នុងឃុំផ្សេងទេ គឺទាំងអស់ពីក្នុងស្រុកហ្នឹង ត្រូវបានប្រមូលមកនៅលើទួលនៅឃុំនោះទាំងអស់គ្នា អ៊ីចឹងមែនទេ លោក?

**ឆ៖** បាទ ពិតប្រាកដហើយលោក។ ការប្រមូលប្រជាជននេះ សុន សេន បានប្រាប់ថាប្រមូលប្រជាជនហើយ ឲ្យឃុំទាំងអស់រៀបចំជ្រើសរើសកងទ័ពដើម្បីបញ្ជូនទៅសមរភូមិមុខ។

**ស៖** លោកបានមានប្រសាសន៍អម្បាញ់មិញថា ប្រមូលអស់ពីស្រុកមក តែលោកមិនបានឆ្លើយថា មានប្រជាជនទាំងអស់ហ្នឹងប៉ុន្មាននាក់ទេ។ តើលោកអាចបញ្ជាក់បានទេ អាចប៉ាន់ស្មានបានទេប៉ុន្មាននាក់?

**ឆ៖** បាទ អត់ដឹងទេលោក ព្រោះខ្ញុំក្តាប់មិនជុំទេ ព្រោះទៅនឹងគ្រាន់តែការអប់រំទៅដើម្បីជ្រើសរើសកងទ័ព ដើម្បីប្រជាជនខំបង្កបង្កើនផល ដើម្បីពន្យល់អំពីការក្បត់របស់ ជា ស៊ីម និង ហេង សំរិនហ្នឹង ថារត់ចូលយួន ទៅបម្រើយួនដើម្បីលេបទឹកដីកម្ពុជាហ្នឹង អប់រំបងប្អូន គេឲ្យអប់រំអ៊ីចឹង ព្រោះអ្នកទៅសុទ្ធ ពួក កា.ហ្វេ.បេ។

**ស៖** បាទ សូមអរគុណ។ ខ្ញុំចង់សុំសួរលោកមើល៍ថា តើនៅពេលដែលលោកមានប្រសាសន៍ឆ្លើយទៅនឹងតំណាងសហព្រះរាជអាជ្ញា លោកនិយាយអំពីលោកបានជិះទូក ហើយឃើញសាកសពអណ្តែតក្នុងទឹក។ តើលោកអាចជម្រាបបានទេ ពេលដែលលោកជិះទូកហ្នឹង គឺជាពេលតែមួយដែលលោកជិះទូកទៅកោះដែលមានមនុស្សឃុំខ្លួននៅលើកោះនោះ ជាពេលតែមួយ ឬក៏ជាពេលផ្សេងគ្នា?

[១៥:៣៦:៥៧]

**ឆ៖** បាទ ផ្សេងគ្នាលោក។ ជាសភាពការណ៍ មិនដឹងជាអ្នកណាអ្នកណីហើយ ព្រោះ០៩ ក៏បានធ្វើកងឈ្លបចុះមកដល់ដែរ។ ដូច្នេះមិនដឹងជាអ្នកណាអ្នកណីទេ កងទាហានក៏មិនដឹង អីមិនដឹងទេ ឃើញតែកំបុតក្បាល ហើមតាមគុម្ពត្រែង។

**ស៖** លោកមានប្រសាសន៍អម្បាញ់មិញ ០៩ ធ្វើជាកងឈ្លបចុះមក។ តើ ០៩ ហ្នឹងជាអ្នកណា លោកអាចបញ្ជាក់បានទេ?

**ឆ៖** កងទ័ពរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិ លោក។

**ស៖** បាទ សូមអរគុណ។ សាកសពដែលលោកបានឃើញនៅពេលដែលលោកជិះទូកដំបូង ខ្ញុំសន្មតថាអ៊ីចឹងចុះ។ លោកជិះទូកដំបូងដែលឃើញសាកសពអណ្តែតទឹកហ្នឹង ថាតើសាកសពនោះជាសាកសពថ្មី ឬក៏ជាសាកសពដែលចាស់ ដែលត្រូវបានសម្លាប់រយៈពេលយូរហើយ អាចលើសពីមួយអាទិត្យឡើងទៅ លោកអាចបញ្ជាក់ពីរឿងហ្នឹងបានទេ?

**ឆ៖** បាទ ខ្ញុំមិនដឹងជាមួយអាទិត្យអី ពីព្រោះហើមបះដៃបះជើងហើយ។ ហើយហើមមិនដឹងជាប៉ុន្មានថ្ងៃ ឃើញអណ្តែតទឹក។

**ស៖** បាទ សូមអរគុណលោក។ ខ្ញុំចង់សុំសួរពេលមួយទៀតដែលលោកជិះទូកដូចគ្នាទៅកោះដែលមានការឃុំខ្លួននោះ។ លោកអាចបញ្ជាក់បានទេ លោកជិះទូកហ្នឹងមានទូកប៉ុន្មាន តែទូកលោកមួយ ឬក៏មានទូកផ្សេងទៀតទៅជាមួយលោក?

**ឆ៖** បាទ កាណូតលោក មិនមែនទូកទេ កាណូត វាធំបាទ។

[១៥:៣៩:១៦]

**ស៖** បាទ សូមទោសៗបាទ។ មានកាណូតផ្សេងទៀតទៅជាមួយលោក ពេលជាមួយគ្នាទេ?

**ឆ៖** បាទ អត់មានទេលោក។

**ស៖** បាទ អរគុណ។ នៅពេលលោកទៅដល់កោះដែលលោកមានប្រសាសន៍ហ្នឹង លោកមានបានឃើញកាណូត ឬក៏ថាជាអាម៉ារីនរបស់កងទ័ពទេ លោកមានបានឃើញទេ ឬក៏មិនមាន?

**ឆ៖** បាទ តាមខ្ញុំមើលទៅកាណូតកងទ័ពគេនៅខាងក្រោមណោះ ព្រោះកោះហ្នឹង ខ្ញុំមិនស្គាល់ដែរ ប៉ុនគេមក មិនមែនមកហែលទេ ខមាលទោស មកហ្នឹងគេមានកាណូតរបស់គេ គេមកកាណូតដែរខាងកងទ័ព។

**ស៖** លោកអាចនិយាយបានទេ ថាតើមានកាណូតតិច ឬក៏ច្រើនដែលមកហ្នឹង? ហើយលោកមានដឹងទេ ថាកាណូតទាំងអស់នោះ គេមកមុនលោកយូរហើយឬនៅ?

**ឆ៖** បាទ មកមុនៗ ខ្ញុំ។

**ស៖** បាទ ខ្ញុំចង់សួរពេលដែលលោក ហើយនិងអ្នកដទៃទៀតឡើងពីទូករបស់លោកហ្នឹង លោក

អាចជម្រាបបានទេ មានអ្នកណាខ្លះដែលឡើងពីទូក ឬក៏ថាអមដំណើរលោកឡើងទៅសាលាដែលមានឃុំមនុស្ស?

[១៥:៤១:១៧]

**ឆ៖** បាទ ទៅទាំងអស់គ្នា ប្អូនដប់នាក់ហ្នឹង ទៅទាំងអស់គ្នាបាទ ឡើងទៅមើលហើយ ត្រឡប់មកវិញ។

**ស៖** លោកអាចរៀបរាប់បានទេ មនុស្សដែលលោកនៅចាំឈ្មោះដែលទៅជាមួយលោកពេលនោះ ឡើងទៅពិនិត្យ ហើយនិងត្រឡប់មកវិញហ្នឹង លោកអាចចាំឈ្មោះបានខ្លះទេ?

**ឆ៖** បាទ អត់ចាំបានអស់ទេ ចាំតែពីរនាក់ បីនាក់ ដែលជាសមាជិកស្រុក។

**ស៖** បាទ សូមអញ្ជើញរៀបរាប់មក តើពួកគាត់ជាអ្នកណាខ្លះ? សូមអញ្ជើញ!

**ឆ៖** បាទ ឈ្មោះ ឱ, ឈ្មោះ អួន, ឈ្មោះ សៀម។

**ស៖** ចុះទ័ពដែលគេមកដល់មុនលោកហ្នឹង ជាទ័ពរបស់អ្នកណា លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ ទ័ពរបស់មជ្ឈិម ហៅថា កងពិសេសរបស់ អ៊ំខៀវ។

**ស៖** តើមានទ័ពស្រុកចូលរួមដែរទេ?

**ឆ៖** បាទ មាន។

**ស៖** លោកមានបានជួបតំណាងរបស់ទ័ពទេ ពេលឡើងពីទូកទៅលើច្រាំង?

**ឆ៖** បាទ បានជួបដែរ ក៏ប៉ុន្តែអត់មានទំនាក់ទំនងទេ គ្រាន់តែអើតមើល ត្រឡប់មកវិញ ព្រោះមិនបានទៅសាកសួរយ៉ាងម៉េចៗ រឿងអីៗទេ ព្រោះរឿងវារួចទៅហើយ។

**ស៖** បាទ ខ្ញុំចង់សួរអំពីថាលោកបានជួបតំណាងរបស់ទ័ពដែលឈរជើងនៅទីនោះដែរឬទេ? ហើយលោកមានបាននិយាយជាមួយគាត់ ឬបានបង្ហាញអ្វីដល់គាត់ដែរទេ?

**ឆ៖** បាទ ឲ្យលិខិតពីខាងលើមកជូនទៅគាត់។

**ស៖** អ្នកណាជាអ្នកឲ្យ? លោកឲ្យប្រគល់ផ្ទាល់ដៃ ឬក៏ថាមានអ្នកណាផ្សេង ក្រៅពីលោកជាអ្នកប្រគល់ទៅតំណាងទ័ព? ហើយលោកមានបាននិយាយអ្វីទៅតំណាងទ័ពទីនោះទេ?

[១៥:៤៣:៥៦]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់!

**លោក បាន សៀក៖**

**ឆ៖** កាលនោះឈ្មោះ ខិ ជាអនុហ្នឹង គាត់បានកាន់សំបុត្រហ្នឹង គាត់យកទៅឱ្យទៅ ខ្ញុំគ្រាន់តែអើតទេ ខ្ញុំក៏ត្រឡប់មកនៅកាណូតវិញ។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ ខ្ញុំសួរបន្តិចទៀត នៅពេលដែលលោក ហើយនិងសហការីរបស់លោកឡើងពីលើទូកហ្នឹងថា តើមានសហការី ឬក៏អ្នកណាគេម្នាក់ក្នុងចំណោមពួកលោក កាន់ប៊ិក កាន់សៀវភៅ ពីទូកឡើងទៅលើហ្នឹងទេ សម្រាប់សរសេរ ឧទាហរណ៍?

**ឆ៖** បាទ អត់ទេលោក អត់មានកាន់ប៊ិក កាន់សៀវភៅទេបាទ។

**ស៖** បាទ នៅពេលដែលលោកទៅដល់សាលាហ្នឹង ដែលលោកបាននិយាយថា ដូចជាសាលា។ លោកអាចរៀបរាប់បានទេ សាលាហ្នឹងមានរូបរាងយ៉ាងដូចម្តេច ទំហំប៉ុនណា បណ្តោយទទឹងប៉ុនណា ឬក៏នៅខ្ពស់ ឬក៏ទាបនៅជាប់ដី លោកអាចបញ្ជាក់អំពីបញ្ហាហ្នឹងបានទេ?

**ឆ៖** បាទ នៅជាប់នឹងដី លោក។ ឯបណ្តោយទទឹង ខ្ញុំអត់បានដឹងទេ។

**ស៖** បាទ អរគុណ។ តើលោកអាចនិយាយពីទំហំទូទៅនៃផ្ទះហ្នឹង ទំហំប៉ុនណាដែរ ប្រហែលជាប៉ុន្មានម៉ែត្រការ៉េ លោកអាចប៉ាន់ស្មានបានទេ?

**ឆ៖** ប៉ាន់មិនបានទេ ព្រោះខ្ញុំមិនបានដើរបណ្តោយទៅមើលផង គ្រាន់តែទៅហ្នឹង ដូចជាសាលាបង្រៀនបន្តិច ដូចជាសាលាលោកបន្តិច ប៉ុន្តែជាប់ដី វាមិនច្បាស់ដែរបាទ។

[១៥:៤៦:១៨]

**ស៖** ខ្ញុំចង់សូមសួរបញ្ជាក់លោកបន្តិច ដែលលោកមានប្រសាសន៍ថា ជាកោះមួយ តែលោកមិនចាំឈ្មោះ តើកន្លែងនោះមានផ្ទះ ឬអគារ ហើយនិងដើមឈើនៅជុំវិញហ្នឹង មានទេ លោកអាចបញ្ជាក់បានទេ?

**ឆ៖** បាទ អង្កាល់ទៅដូចអត់ឃើញមានផ្ទះ ឃើញតែដើមឈើ ដើមអំពៅ ដើមស្អី ដំឡូងអី អត់ឃើញ ដើមចេក ដើមអី អត់ឃើញជាផ្ទះជាអីផង។ មិនបានមើលសព្វផង លោក។

**ស៖** តើមានតែចំនួនតិចតួច ឬក៏ថាមានច្រើនដើម លោកអាចបញ្ជាក់ពីបញ្ហាហ្នឹងបានទេ?

**ឆ៖** បាទ នៅដីកោះមានដំណាំច្រើន។

**ស៖** ដែលលោកសន្និដ្ឋានថា ជាដីកោះនុ៎ង ថាតើ ឬក៏លោកនិយាយថា ជាដីកោះហ្នឹង តើគេ

ជម្រាបលោកថា ជាកោះ ឬលោកមើលទៅឃើញមានទឹកព័ទ្ធជុំវិញ?

**ឆ៖** មើលទៅថាជាកោះតែម្តង។

**ស៖** តើលោកមានឃើញទឹកព័ទ្ធជុំវិញទេ លោក ឬក៏ឃើញទឹកតែមួយចំហៀង?

**ឆ៖** បាទ ឃើញតែមួយជ្រុងទេ លោក។

[១៥:៤៨:២១]

**ស៖** បាទ អ៊ីចឹងមានន័យថា មួយជ្រុង -- ឃើញតែមួយជ្រុងទេ ហើយជ្រុងផ្សេងទៀត លោកមិនបានឃើញច្បាស់លាស់ថា មានទឹកព័ទ្ធជុំវិញទេ។ អ៊ីចឹងមែនទេ?

**ឆ៖** បាទ លោក។

**ស៖** បាទ ខ្ញុំចង់សូមសួរអំពីមនុស្សដែលនៅក្នុងអគារ ឬក៏នៅក្នុងសាលានោះ។ លោកបានមានប្រសាសន៍ថា លោកបានមើលឃើញ តើលោកអាចជម្រាបបានទេ មនុស្សដែលនៅក្នុងនោះជាស្រី ឬក៏ជាប្រុស ឬក៏ថា មានទាំងស្រីផង ប្រុសផង លោកអាចបញ្ជាក់អំពីរឿងហ្នឹងបានទេ?

**ឆ៖** បាទ មានស្រីប្រុស លោក។

**ស៖** មនុស្សប្រុស លោកបានឃើញច្បាស់លាស់ទេ ហើយបើសិនលោកបានឃើញច្បាស់លាស់ មនុស្សប្រុសប្រហែលមានប៉ុន្មាននាក់ លោកអាចបញ្ជាក់បានទេ ចំនួន?

**ឆ៖** បាទ អត់ច្បាស់ទេ លោក។ អត់បានដឹងចំនួនប៉ុន្មានទេ។ តាមស្មានប្រហែលជា២០ទៅ៣០នាក់។

**ស៖** បាទ តើមាននរណាក្នុងចំណោមពួកលោកបានចូលនៅក្នុងសាលានោះ ហើយបាននិយាយជាមួយមនុស្សដែលជាប់ឃុំនៅក្នុងនោះទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេលោក។

**ស៖** បាទ អ៊ីចឹងលោកអាចបញ្ជាក់បានទេ ពេលដែលលោកទៅដល់សាលានោះ លោកធ្វើអ្វីនៅពេលនោះ?

**ឆ៖** បាទ ខ្ញុំបាទ គ្រាន់តែអើតមើល ត្រឡប់មកវិញ។

[១៥:៥១:០៨]

**ស៖** បាទ មានកន្លែងមួយនៅក្នុងឃ្លារបស់លោកដែលបាននិយាយថា លោកបានអើតមើល ហើយនិងសហការីរបស់លោក បានចូលនៅក្នុងសាលានោះ។

ខ្ញុំសូមអធ្យាស្រ័យលោកប្រធាន ខ្ញុំវង្វេងចំណុចនោះហើយ ខ្ញុំអាចជូន ERN នៅពេលក្រោយ។

ថាតើលោកអាចបញ្ជាក់បានទេ ថាតើលោកធ្លាប់បាននិយាយថា សហការីរបស់លោក បានចូលនៅក្នុងសាលានោះដែរឬទេ?

**ឆ៖** បាទ ប្រហែលជាមាន លោក ព្រោះកងទ័ពគេទៅ ខ្លះគេទៅមើល។

**ស៖** បាទ ខ្ញុំសូមលើកសម្ដីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ដែលឈ្មោះ នោ សាទះ។ គាត់បាននិយាយថា ខ្ញុំសូមលើកនៅក្នុងប្រតិចារឹករបស់គាត់នាថ្ងៃទី២៩ ខែ០៩ ឆ្នាំ២០១៥ វេលាម៉ោងដប់មួយ និងដប់ពីរនាទីព្រឹក។ លោកស្រីបាននិយាយថា លោកស្រីត្រូវបានសួរដោយចៅហ្វាយស្រុកឈ្មោះ ហួ នៅក្នុងបន្ទប់នោះ។ តើលោកមានប្រតិកម្មយ៉ាងដូចម្ដេចដែរ នៅពេលដែល -- ចំពោះអ្វីដែលលោកស្រី នៅ សាទះ គាត់បាននិយាយថា លោកមានវត្តមាននៅក្នុងបន្ទប់នោះ ហើយបានសួរទៅគាត់ថា គាត់ជាខ្មែរ ឬក៏ចាម តើលោកមានប្រតិកម្មយ៉ាងដូចម្ដេចដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវី គង់ សំអុន!

[១៥:៥៣:០៥]

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន ខ្ញុំមិនជំទាស់ទេ ប៉ុន្តែចង់បញ្ជាក់ទៅលើឈ្មោះ តាមខ្ញុំចាំ គឺឈ្មោះ នោ សាទះ។ បាទ សូមអរគុណ។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណ។ គាត់ឈ្មោះ នោ សាទះ។

**ប្រធានអង្គជំនុំ៖**

ចុះលោកមេធាវី វ៉ិចទ័រ កូប៉េ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំ<ប្រហែលជា>ច្រឡំហើយ <ប៉ុន្តែ>ខ្ញុំដូចជាមិនចាំថា នោ សាទះ ហ្នឹង ធ្លាប់បាននិយាយថា គាត់ហ្នឹងត្រូវបានឃុំខ្លួននៅលើកោះអីមួយនោះទេ។ គាត់បានប្រាប់ថា គាត់ហ្នឹង ត្រូវបានគេឃុំខ្លួននៅភូមិទ្រា <មិនមែននៅកោះ>ទេ។ បើសិនជាខ្ញុំយល់ច្រឡំ សូមជួយកែខ្ញុំផង លោកមេធាវី។ អ៊ីចឹងខ្ញុំ

មើលទៅមិនឃើញថា <សំណួររបស់លោក>មានភាពពាក់ព័ន្ធ<>ជាមួយនឹងសក្ខីកម្មរបស់លោកស្រី នោ សាទះ នេះ<ទេ>។

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ ខ្ញុំអម្បាញ់មិញបានសួរអំពីកោះមួយដែលលោកសាក្សីបាននិយាយថា ហើយដែលអាច វាមិនមែនជាកោះ ដោយសារគាត់បានឃើញតែមួយផ្នែកនៃទឹក ហើយមួយផ្នែកផ្សេងទៀតដែលមិនមាន ហើយមានដើមឈើនៅទីនោះច្រើន។ ដូច្នេះ វាអាចជាអ្វីផ្សេងពីកោះ។ ហើយអ្វីដែលខ្ញុំចង់សួរ គឺឲ្យគាត់មានប្រតិកម្មនូវអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយតែប៉ុណ្ណោះ។ ហើយទោះថា កោះ ឬមិនកោះ វាមិនជាបញ្ហាសំខាន់ទេ គឺចង់ឲ្យសាក្សីនិយាយថា អ្វីដែលលោកស្រីដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយនោះ គឺពិតប្រាកដដែរទេ ដែលថាលោកសាក្សីបានចូលទៅក្នុងសាលនោះ ហើយបានសួរទៅជនដែលនៅជាប់នៅឃុំនៅក្នុងនោះ។ បាទ សូមអរគុណលោកប្រធាន។

[១៥:៥៤:៥៦]

**ប្រធានអង្គជំនុំ៖**

លោកផ្ទៀងផ្ទាត់សិនទៅ ជាលោកមកសួរនោះ ដូចជាអត់មានបានផ្ទៀងផ្ទាត់រវាងអង្គហេតុហ្នឹងទេ។ អង្គហេតុនេះ វាមិនច្បាស់លាស់ ដោយសារសាក្សីនេះមិនស្គាល់ទេ ហើយអង្គហេតុដែលឆ្លើយទាំងនេះ គឺជាសាលារៀន ឬក៏ជាកុដិលោកដែលនៅផ្ទាល់ដី។ ហើយចំណែកឯអង្គហេតុដែល នោ សាទះ ឆ្លើយហ្នឹង គឺនៅលើផ្ទះនេះទេ ផ្ទះឈើមួយខ្ពស់ សង់ផុតពីដី ដូចជាឆ្ងាយពីគ្នា ហើយលោកដែលឆ្លើយ គឺថាវាអាចសួរផ្ទាល់ទៅ ដោយសារមិនបានផ្ទៀងផ្ទាត់អំពីអង្គហេតុដែលលោកសួរនេះ ហើយនិងចម្លើយសក្ខីកម្មរបស់ នោ សាទះ ដែលបានឆ្លើយរួចហើយទេ។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន អាចមានការរៀបរាប់មិនត្រូវគ្នា អំពីបញ្ហាទីកន្លែង ឬក៏ផ្ទះនោះ ក៏ប៉ុន្តែអ្វីដែលខ្ញុំចង់បាន គឺចង់ឲ្យគាត់មានប្រតិកម្មថា តើអ្វីដែលដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយអំពីឈ្មោះគាត់ ឈ្មោះ ហួ ដែលបានសួរគាត់ហ្នឹង ថាតើលោកសាក្សីហ្នឹង មានប្រតិកម្មយ៉ាងដូចម្តេចចំពោះសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ចំពោះបញ្ហាទីតាំង កោះ ឬក៏ផ្ទះ វាជាបញ្ហាបន្ទាប់បន្សំទេ។ សូមលោកប្រធានអនុញ្ញាត។

[១៥:៥៦:៣៣]

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ សូមអញ្ជើញសាក្សីឆ្លើយតបនឹងសំណួរនេះ!

**លោក បាន សៀក៖**

**ឆ៖** បាទ ខ្ញុំបាទមិនបានស្គាល់លោកស្រី សាទះ ទេ។ ហើយខ្ញុំបាទមិនបាននិយាយអ៊ីចឹងផង។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ លោកសាក្សី ខ្ញុំមិនបាននិយាយថា លោកស្គាល់លោកស្រី នោ សាទះ ទេ។ ខ្ញុំអានឡើងវិញ នៅក្នុងម៉ោង ១១:១២:៥០ លោកស្រីបានឆ្លើយសំណួរថា "ចាស ហ្នឹងហើយ តាហូ ហ្នឹង ពួកខ្ញុំឡើងទៅដល់លើផ្ទះហ្នឹង ប្រហែលជាមួយស្របក់ទេ ខ្ញុំសម្រាន្តលក់មួយភ្លេត គេឡើងមក គេសុំពួកខ្ញុំចង។ គេថា ក្មួយៗយើងក្រោកឡើង ពូសុំចង ខ្លាចក្មួយយើងរត់។ អ៊ីចឹង វាពិបាកធ្វើការណាស់។ ដល់គេចងរួច គេសួរចម្លើយពួកខ្ញុំ។ សួរសុទ្ធតែអ្នកនៅពីក្រៅស្រុក ក្រៅភូមិអ៊ីចឹង។ អ្នកមកពីឆ្ងាយៗហ្នឹង សុទ្ធតែចាម សុទ្ធតែបងប្អូនចាមយើង នារីៗទាំងអស់។ អ្នកណាត្រង់ ឆ្លើយថាចាមហ្នឹង គឺថាទៅចុះចាម -- ថាទៅ ចាមចុះៗ។ អ្នកដែលជូនទៅ យោធាម្នាក់មានកាំបិតក្រង៉ុកមួយដើម អាកាស្វ័យបត់មួយដើម រួចសួរមកដល់ពួកខ្ញុំទៀត។ ដល់វាអស់ ពួកហ្នឹងទៅមកដល់។" បាទ សូមអធ្យាស្រ័យ អ្វីដែលលោកស្រី -- អានអ្វីដែលលោកស្រីនិយាយ ដូចជាពិបាកស្តាប់បន្តិច។ ក៏ប៉ុន្តែនៅពេលនោះ លោកស្រីបាននិយាយថា លោក ហូ បានឡើងមកលើផ្ទះ។ អ៊ីចឹងលោកប្រាកដទេ ដែលថាលោកមិនបានទៅសួរអ្នកដែលជាប់ឃុំនៅលើផ្ទះនោះ លោកអាចបញ្ជាក់ឲ្យច្បាស់ទេ?

[១៥:៥៨:៤៨]

**ឆ៖** បាទ ពេលនោះខ្ញុំមិនបានចាំទេ ខ្ញុំមិនបានសួរទេ ព្រោះពេលនោះ ខ្ញុំមិនបានដឹងអីផង។ មិនបានទៅសួរអីសព្វអ៊ីចឹងទេ។

**ស៖** លោកមានប្រសាសន៍ថា មិនបានដឹងហ្នឹង មានន័យថាយ៉ាងដូចម្តេច? មិនបានដឹងពីអ្វីលោកអាចបញ្ជាក់បានទេ?

**ឆ៖** មិនបានដឹងហ្នឹង ខ្ញុំបាទមិនបាននៅកន្លែងសួរចម្លើយនោះ ព្រោះខ្ញុំបាទបានទៅការដ្ឋានហើយ អ៊ីចឹងបានខ្ញុំបាទមិនបាននៅ។ ព្រោះនៅក្នុងហ្នឹង ឱ ជាអនុប្រធានហ្នឹង គាត់នៅហ្នឹង ក៏គាត់ប្រហាក់ប្រហែលគ្នា។ ដូច្នេះបញ្ហាហ្នឹង ចេះតែស្គាល់ ដូចថាស្គាល់ខ្ញុំអ៊ីចឹង ខ្ញុំមិនមែនឈ្មោះហ្នឹងទេ ខ្ញុំទៅនៅភូមិភាគបូព៌ានោះ។ ខ្ញុំអត់មានឈ្មោះទេ។ ឈ្មោះហ្នឹង កាលខ្ញុំនៅឡូត៍នេសាទទេ លោក។

**ស៖** បាទ សូមអរគុណដែលលោកបញ្ជាក់អំពីបញ្ហានេះ ក៏ប៉ុន្តែតំណាងសហព្រះរាជអាជ្ញាបានសួរអំពីបញ្ហាឈ្មោះនេះទៅលោករួចហើយ។ ខ្ញុំមិនសួរអំពីបញ្ហាឈ្មោះនេះទៅលោកតទៅទៀតទេ។ ខ្ញុំមានសំណួរតែពីរសំណួរទៀតទេ។ លោកអាចបញ្ជាក់បានទេ ក្រៅពីក្រុមដែលជាប់ឃុំនៅក្នុងផ្ទះហ្នឹងថា តើមានក្រុមផ្សេងទៀតដែលត្រូវប្រមូល ឬក៏ជាប់ឃុំនៅកន្លែងណាផ្សេងទេ ក្នុងពេលជាមួយគ្នា?

**ឆ៖** បាទ ខ្ញុំមិនចាំទេលោកបញ្ហាហ្នឹង ព្រោះដឹងតែពេលដែលគេយកទៅដាក់កោះផលហ្នឹងបានខ្ញុំដឹង ព្រោះដល់ពេលនេះទៅ មួយរយៈហ្នឹងខ្ញុំបានទៅរៀន ដល់រៀនរួចខ្ញុំទៅការដ្ឋានបណ្តោយ។ ដូច្នេះបើមកក៏តាមទឹក បើទៅខាង ដើរតាមព្រៃកៅស៊ូនោះ ទៅការដ្ឋានបណ្តោយលោក។

[១៦:០០:៥៥]

**ស៖** សូមទោស អម្បាញ់មិញលោកបញ្ជាក់អំពីកោះផលមែនទេលោក?

**ឆ៖** បាទ ខ្ញុំបាទអត់និយាយពីកោះផលទេ។ ខ្ញុំ ខាងលើហៅ មួយរយៈហ្នឹងខាងលើហៅទៅធ្វើការរៀនសូត្រហើយ ខាងលើដាក់ផែនការ ឲ្យប្រមូលប្រជាជនទៅការដ្ឋានហើយ រៀបចំប្រមូលកងទ័ពទៅសមរភូមិមុខ។ ដូច្នេះមិនបានមកគិតគូរពីបញ្ហាហ្នឹងទេលោក។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណ។ ខ្ញុំមិនលើកសំណួរសួរលោកទៀតទេ។ សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាននិងលោក លោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សវនាការនៅថ្ងៃនេះដល់ពេលឈប់សម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី០៦ ខែតុលា ឆ្នាំ២០១៥ ចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី បាន សៀក និងអាចមានសាក្សីបម្រុងមួយរូបគឺ 2-TCW-904 សូមភាគីជ្រាបនិងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក បាន សៀក ដំណើរការសវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោកមកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀតដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយអង្គជំនុំជម្រះក៏សូមអរគុណលោកលោកស្រី សុក សុជាតា មេធាវីប្រឹក្សាសាក្សី មេធាវីអាចសម្រាកបានហើយ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនលោក បាន សៀក ត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញ និងសូមឲ្យអញ្ជើញគាត់ត្រឡប់មកចូលរួមសវនាការវិញនៅថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួនព្រឹក។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ទាំងពីររូបត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកវិញ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*